# មាតិកា

* * *


**អារម្ភកថា**.....i

**អក្សរកាត់**.....iii

**ខ្លឹមសារសង្ខេប**.....vii

**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២៥**

I- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច**.....១

១- បរិស្ថានសេដ្ឋកិច្ចពិភពលោក.....១

២- កំណើនសេដ្ឋកិច្ច.....៣

៣- ស្ថានភាពជញ្ជីងទូទាត់.....១៤

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ.....១៨

៥- ស្ថានភាពអតិផរណា.....១៩

៦- ស្ថានភាពអត្រាប្ដូរប្រាក់.....២៣

II- **ស្ថានភាពរូបិយវត្ថុ**.....២៦

១- ការផ្គត់ផ្គង់រូបិយវត្ថុ.....២៦

២- កូរីដ័រអត្រាការប្រាក់ និងអត្រាការប្រាក់អន្តរធនាគារ.....២៦

៣- អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.....២៧

៤- ប្រតិបត្តិការរូបិយវត្ថុ.....២៩

III- **វឌ្ឍនភាពប្រព័ន្ធធនាគារ**.....៣៣

១- ស្ថានភាពទូទៅ.....៣៣

២- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.....៣៦

៣- ការរៀបចំបទប្បញ្ញត្តិ.....៣៨

៤- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ.....៣៩

៥- កិច្ចការពារអតិថិជន.....៤០

៦- កិច្ចការពារប្រាក់បញ្ញើ.....៤២

៧- ហិរញ្ញវត្ថុប្រកបដោយចីរភាព.....៤៣

៨- ស្ថិរភាពហិរញ្ញវត្ថុ.....៤៤

IV- **ប្រព័ន្ធនិងសេវាទូទាត់សងប្រាក់**.....៤៨

១- ប្រព័ន្ធទូទាត់សងប្រាក់.....៤៨

២- សេវាទូទាត់សងប្រាក់.....៥៥

V- **ការផ្គត់ផ្គង់សេវាធនាគារកណ្តាល** ........ ៥៩
១- សេវាគ្រប់គ្រងគណនី ........ ៥៩
២- សេវាគ្រប់គ្រងមូលបត្រ ........ ៥៩
៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ........ ៦១
VI- **ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ........ ៦៣
១- ការត្រួតពិនិត្យបុគ្គលរាយការណ៍ ........ ៦៤
២- ការវិភាគប្រតិបត្តិការ ........ ៦៤
៣- កិច្ចសហប្រតិបត្តិការ ........ ៦៥
៤- ការពង្រឹងសមត្ថភាព ........ ៦៧
VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** ........ ៦៩
១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ ........ ៦៩
២- កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុ ........ ៧៣
៣- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន ........ ៧៧
៤- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន+៣ ........ ៧៨
VIII- **ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ........ ៨០
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ........ ៨០
២- ការអភិវឌ្ឍធនធានមនុស្ស ........ ៨១
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........ ៨៦
៤- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ........ ៨៨
៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ........ ៨៨
IX- **ទំនាក់ទំនងសាធារណៈ** ........ ៩០
១- ការផ្សព្វផ្សាយតាមបណ្តាញសង្គម ........ ៩០
២- ការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ ........ ៩១
៣- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ ........ ៩៥
៤- ការផ្សព្វផ្សាយប្រព័ន្ធបាគង បាគងទេសចរ និងបាគងយុវនៃ ........ ៩៥
៥- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល ........ ៩៦
៦- ការចូលរួមជាវាគ្មិន និងការទទួលពានរង្វាន់លំដាប់អន្តរជាតិ ........ ៩៧
៧- ការរួមចំណែកក្នុងការងារសង្គម ........ ៩៩
៨- សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន (ស.ស.រ.) ........ ១០១
**សេចក្តីសន្និដ្ឋាន** ........ ១០៤

**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារ**


**I- ទស្សនវិស័យសេដ្ឋកិច្ច** ........ ១០៥

**II- ទិសដៅការងារចម្បងៗនៅឆ្នាំ២០២៦** ........ ១០៧

១- ការអនុវត្តនយោបាយរូបិយវត្ថុ ........ ១០៧

២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........ ១០៧

៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ........ ១០៨

៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១០៨

៥- ការរៀបចំបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ ........ ១០៩

៦- ការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ........ ១០៩

៧- ការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ កិច្ចការពារអតិថិជន និងកិច្ចការពារប្រាក់បញ្ញើ ... ១១០

៨- ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ........ ១១០

៩- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ១១០

១០- ការអភិវឌ្ឍទីផ្សាររូបិយវត្ថុ ........ ១១១

១១- ការផ្ដល់សេវាធនាគារកណ្ដាល ........ ១១១

១២- ការគ្រប់គ្រងសាច់ប្រាក់ ........ ១១២

១៣-សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........ ១១២

១៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ........ ១១៣

១៥- ការអភិវឌ្ឍធនធានមនុស្ស ........ ១១៣

១៦- កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ១១៣

១៧-ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ........ ១១៤

១៨- ការពង្រឹងគុណភាពស្ថិតិ ........ ១១៤

១៩- សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន (ស.ស.រ.) ........ ១១៥

២០- វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ........ ១១៥


**ឧបសម្ព័ន្ធ**


ឧបសម្ព័ន្ធ ១ តារាង ១ - សូចនាករម៉ាក្រូសេដ្ឋកិច្ច ........ ១១៦

ឧបសម្ព័ន្ធ ២ តារាង ២ - សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........ ១១៧

ឧបសម្ព័ន្ធ ៣ តារាង ៣ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ........ ១១៨

ឧបសម្ព័ន្ធ ៤ ប្រអប់ ១ - អត្រាប្ដូរប្រាក់ប្រសិទ្ធភាពនាមនាម និងពិត ........ ១១៩

ឧបសម្ព័ន្ធ ៥ តារាង ៤ - ស្ថិតិស្ថានភាពធនាគារកណ្ដាល ........ ១២១

ឧបសម្ព័ន្ធ ៦ តារាង ៥ - ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត ........ ១២២

ឧបសម្ព័ន្ធ ៧ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ ............................. ១២៣
ឧបសម្ព័ន្ធ ៨ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ......................... ១២៤
ឧបសម្ព័ន្ធ ៩ តារាង ៨ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ.......................................... ១២៥
ឧបសម្ព័ន្ធ ១០ តារាង ៩ -ឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ...... ១២៦
ឧបសម្ព័ន្ធ ១១ តារាង ១០ -ឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ...១២៧
ឧបសម្ព័ន្ធ ១២ តារាង ១១ -ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ.......................................... ១២៨
ឧបសម្ព័ន្ធ ១៣ តារាង ១២ -ជញ្ជីងទូទាត់កម្ពុជា ........................................................... ១២៩
ឧបសម្ព័ន្ធ ១៤ តារាង ១៣ -បណ្ដាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ...........១៣០
ឧបសម្ព័ន្ធ ១៥ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ......................................................................... ១៣២

# អារម្ភកថា

ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៥ នៅតែស្ថិតក្រោមភាពមិនប្រាកដប្រជាខ្ពស់ ដោយសារស្ថានភាពភូមិសាស្ត្រនយោបាយដែលបន្តមានសភាពតានតឹង លក្ខខណ្ឌហិរញ្ញវត្ថុសកល ដែលតឹងរឹង និងអត្រាកំណើនសេដ្ឋកិច្ចសម្រេចបានក្នុងល្បឿនទិសដៅផ្សេងគ្នា។ ការណ៍នេះបាន បង្កើតសម្ពាធលើពាណិជ្ជកម្ម និងលំហូរវិនិយោគអន្តរជាតិ ព្រមទាំងទីផ្សារហិរញ្ញវត្ថុ ដែលបង្កជា បញ្ហាប្រឈមសម្រាប់ទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ។ ក្នុងបរិបទនេះ សេដ្ឋកិច្ចកម្ពុជា បានបន្តការស្តារឡើងវិញសន្សឹមៗ ដោយទទួលបានការគាំទ្រពីតម្រូវការក្នុងស្រុកដែលមានភាពធន់ និងប្រក្រតីភាពបន្តបន្ទាប់នៃវិស័យសំខាន់ៗ។ ទោះជាយ៉ាងណា ការស្តារឡើងវិញនេះក៏ត្រូវប្រឈមនឹង ការរីករាលដាលជាសកលនៃឧក្រិដ្ឋកម្មសាយប័រ ដូចជា ការកើនឡើងនៃសកម្មភាពធនាគារស្រមោល និងការកើនឡើងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលបានធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ប្រទេស ហើយអាចបង្កហានិភ័យដល់ប្រព័ន្ធធនាគារ។ ស្របពេលជាមួយគ្នានេះ ការផ្ទុះអាវុធកម្ពុជា-ថៃ សាជាថ្មី បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃនៅទីក្រុងកូឡាឡាំពួ បានបន្ថែមភាពមិនប្រាកដប្រជា ទៅលើសេដ្ឋកិច្ច និងមានផលប៉ះពាល់ដល់ពាណិជ្ជកម្មឆ្លងដែន ផលិតកម្ម សេវាកម្ម និងទំនុកចិត្ត វិនិយោគិន។ ទន្ទឹមនេះ សេដ្ឋកិច្ចក៏នៅតែប្រឈមនឹងហានិភ័យពីបរិយាកាសខាងក្រៅរួមមានតម្រូវការ ពិភពលោកដែលនៅតែទាប ការផ្លាស់ប្តូរនិន្នាការពាណិជ្ជកម្ម និងភាពងាយរងផលប៉ះពាល់ពីហានិភ័យ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ការការពារស្ថិរភាពថ្លៃ និងការពង្រឹងភាពធន់នៃសេដ្ឋកិច្ច នៅតែជាគោលដៅសំខាន់ សម្រាប់ធនាគារជាតិនៃកម្ពុជា។

ចំពោះទស្សនវិស័យនៅឆ្នាំ២០២៦ កម្ពុជានឹងត្រូវខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈម និងទាញយកអត្ថប្រយោជន៍ពីឱកាសថ្មីៗ។ ពហុភាគីកម្មសេដ្ឋកិច្ច ការវិនិយោគបន្តបន្ទាប់លើហេដ្ឋា-រចនាសម្ព័ន្ធ និងការជ្រៀតចូលកាន់តែស៊ីជម្រៅទៅក្នុងតំបន់ និងសេដ្ឋកិច្ចពិភពលោក បានផ្តល់ជា មូលដ្ឋានរឹងមាំ សម្រាប់កំណើនរយៈពេលមធ្យម។ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា កិច្ចខិតខំប្រឹងប្រែងបន្តក្នុងការលើកកម្ពស់ផលិតភាព ការពង្រឹងធនធាន មនុស្ស ការកែលម្អបរិយាកាសអាជីវកម្មនិងវិនិយោគ និងការធ្វើទំនើបកម្មស្ថាប័នសេដ្ឋកិច្ច នឹងជួយ គាំទ្រដល់ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចដែលមានតម្លៃបន្ថែមខ្ពស់ និងកំណើនដែលមានភាពធន់ កាន់តែខ្លាំង។ ធនាគារជាតិនៃកម្ពុជានឹងបន្តដាក់ចេញគោលនយោបាយនិងវិធានការបុរេសកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ សំដៅរួមចំណែកសម្រេចបាន នូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ក្នុងទិសដៅនេះ ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការពង្រឹង ភាពរឹងមាំប្រព័ន្ធធនាគារនិងប្រសិទ្ធភាពប្រព័ន្ធទូទាត់ ការលើកកម្ពស់បរិយាបន្ននិងនវានុវត្តន៍ហិរញ្ញវត្ថុ និងការអភិវឌ្ឍហិរញ្ញប្បទានបៃតង នឹងត្រូវបន្តយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ដើម្បីគាំទ្រ

កំណើនសេដ្ឋកិច្ចប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាក៏នឹងបន្តពង្រឹងក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ ព្រមទាំងការផ្សព្វផ្សាយនិងបណ្តុះបណ្តាល ក្នុងគោលដៅពង្រឹងការយល់ដឹងជុំវិញការចូលរួមទប់ស្កាត់និងបង្ការ ក៏ដូចជា បង្កើនប្រសិទ្ធភាពនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ព្រមទាំងភាគីពាក់ព័ន្ធនានា នឹងបន្តគាំទ្រនិងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

**ទេសាភិបាល**

ជា សិរី

# អក្សរកាត់

| | | |
|---|---|---|
| គ.ល.ក. | អគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | General Secretariat of Commercial Gambling Management Commission of Cambodia |
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Coordination Committee on Anti-Money Laundering and Combating of Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ម.ធ | សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា | |
| ស.ស.យ.ក. | សហភាពសហព័ន្ធយុវជនកម្ពុជា | Union Youth Federations of Cambodia |
| ស.ស.រ. | សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បសានវ៉េន | SOSORO – Cambodia's Museum of Economy and Money |
| ស.ហ.ក. | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| វ.ប.ធ. | វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ | Institute for Banking Studies |
| អ.ស.ហ. | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | Non-Bank Financial Services Authority |
| ACCA | សមាគមគណនេយ្យករជំនាញ | Association of Chartered Certified Accountants |
| ACGM | កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Central Banking Governor Meeting |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន | ASEAN Economic Community |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| AFMGM | កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Finance Minister and Central Bank Governor Meeting |
| AFTN | បណ្តាញអ្នកជំនាញហិរញ្ញវត្ថុអាស៊ាន+៣ | ASEAN+3 Finance Think-Tank Network |
| AI | បញ្ញាសិប្បនិម្មិត | Artificial Intelligence |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| AREO | របាយការណ៍សេដ្ឋកិច្ចប្រចាំតំបន់អាស៊ាន+៣ | The ASEAN+3 Regional Economic Outlook |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| Bakong LVPS | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |

| | | |
|---|---|---|
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| CAMEL | វិធីសាស្ត្រវាយតម្លៃសុខភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | Capital adequacy, Asset quality, Management, Earnings, Liquidity |
| CBDC | រូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល | Central Banking Digital Currency |
| CBI | វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈធនាគារដ៏ល្បីល្បាញ មានមូលដ្ឋាននៅចក្រភពអង់គ្លេស | Chartered Banker Institute |
| CDOT | ការិយាល័យអភិវឌ្ឍន៍សមត្ថភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ | IMF Capacity Development Office in Thailand |
| CIFRS | ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | Cambodian International Financial Reporting Standards |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CSES | លទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា | Cambodia Socio-Economic Survey |
| CTR | របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ | Cash Transaction Report |
| ECOFEL | កម្មវិធីសិក្សា Egmont Certificate of FIU Excellence and Leadership | Egmont Certificate of FIU Excellence and Leadership |
| EIA | រដ្ឋបាលព័ត៌មានអំពីថាមពលរបស់សហរដ្ឋអាមេរិក | US Energy Information Administration |
| e-KYC | មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក | Electronic Know Your Customer |
| ERIA | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា | Economic Research Institute for ASEAN and East Asia |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social, and Governance |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| Fed | ធនាគារកណ្តាលសហរដ្ឋអាមេរិក | US Federal Reserve |
| FICG | ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| FSIs | សូចនាករភាពរឹងមាំហិរញ្ញវត្ថុ | Financial Soundness Indicators |
| FTC | គម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ | Financial Transparency Corridor |
| HKMA | អាជ្ញាធររូបិយវត្ថុហុងកុង | Hong Kong Monetary Authority |
| IBS | វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ | Institute for Banking Studies |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |

| | | |
|---|---|---|
| JFY | ឆ្នាំសារពើពន្ធជប៉ុន | Japanese Fiscal Year |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន | Japan International Cooperation Agency |
| KAMCO | ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មកូរ៉េ | Korea Asset Management Corporation |
| KTI | អាកាសយានដ្ឋានអន្តរជាតិតេជោ | Techo International Airport |
| KYC | មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន | Know Your Customer |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit-Taking Institutions |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Microfinance Institutions |
| MIT | វិទ្យាស្ថានបច្ចេកវិទ្យា Massachusetts | Massachusetts Institute of Technology |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម | Micro, Small and Medium Enterprises |
| NBCP | ថ្នាលធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| OBS | ប្រព័ន្ធធនាគារអេឡិចត្រូនិក | Online Banking System |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ | Official Development Aid |
| PED | សមិទ្ធផលអាទិភាពសេដ្ឋកិច្ច | Priority Economic Development |
| PFMI | គោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ | Principles for Financial Market Infrastructures |
| RFF | ឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស (RFF) | Rapid Financing Facility |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPC | ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់ | Regional Payment Connectivity |
| RPG | លេខាធិការដ្ឋាន នៃក្រុមការងារត្រួតពិនិត្យឡើងវិញ | Review Panel Group |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SDR | ធនធានជាសិទ្ធិដកពិសេស | Special Drawing Rights |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| SEAVG | ក្រុមការងារមណ្ឌលបោះឆ្នោតប្រចាំតំបន់អាស៊ីអាគ្នេយ៍ | Southeast Asia Voting Group |
| SMEs | សហគ្រាសធុនតូច និងមធ្យម | Small and Medium Enterprises |

| | | |
|---|---|---|
| SPIRIT | គម្រោងជំនួយបច្ចេកទេសរបស់ AMRO | Structural Policy Improvement and Review Instrument with Technical Assistance |
| SREP | វិធីសាស្ត្រត្រួតពិនិត្យស្រប | Supervisory Review and Evaluation Process |
| STR | របាយការណ៍ប្រតិបត្តិការសង្ស័យ | Suspicious Transaction Report |
| UMS | ប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ | University Management System |
| UN | អង្គការសហប្រជាជាតិ | United Nations |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ | United Nations Development Programme |
| UPI | ក្រុមហ៊ុនអន្តរជាតិយូញៀនផេ | UnionPay International |
| UTC | គម្រោង Universal Trusted Credentials | Universal Trusted Credentials |
| WB | ធនាគារពិភពលោក | World Bank |
| WEDC | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពជាស្ត្រី | Women's Enterprise Development Center |
| WEO | របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក | World Economic Outlook |

# ខ្លឹមសារសង្ខេប

**សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងភាពមិនប្រាកដប្រជាខ្ពស់ ជាពិសេសពីបញ្ហាភូមិសាស្ត្រនយោបាយសេដ្ឋកិច្ច និងការដាក់ចេញពន្ធគយបដិការរបស់សហរដ្ឋអាមេរិក។** ប្រឈមនឹងបញ្ហាទាំងនេះ កំណើនសេដ្ឋកិច្ចពិភពលោកនាឆ្នាំ២០២៥ត្រូវបានព្យាករថាមានកម្រិត ៣,២% (៣,៣% នាឆ្នាំ២០២៤) ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មានកំណើន ១,៦% និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ ៤,២%។ រីឯក្នុងតំបន់ សេដ្ឋកិច្ចអាស៊ានបានថមថយបន្តិចមកត្រឹម ៤,៣%។ អត្រាអតិផរណាពិភពលោកបានថមថយមកត្រឹម ៤,២% ដែលបានអនុញ្ញាតឱ្យធនាគារកណ្តាលនៃប្រទេសចម្បងៗបន្ធូរបន្ថយអត្រាការប្រាក់គោល ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ទន្ទឹមនេះ ការពន្លឿនការបញ្ជាទិញមុនសុពលភាពនៃពន្ធគយបដិការ បានជំរុញឱ្យទំហំពាណិជ្ជកម្មអន្តរជាតិមានកំណើន ៣,៦%។

**ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាបន្តរក្សាបានស្ថិរភាព ដែលឆ្លុះបញ្ចាំងតាមរយៈតុល្យភាពខាងក្នុង និងខាងក្រៅ។** សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាអាចសម្រេចបានកំណើន ៥% នាឆ្នាំ២០២៥ ដែលគាំទ្រជាចម្បងដោយកំណើនការនាំចេញវិស័យកម្មន្តសាល។ យ៉ាងណាមិញ អត្រានេះមានកម្រិតទាបជាងការរំពឹងទុក ដោយសារការធ្លាក់ចុះនៃចំនួនទេសចរ។ អត្រាអតិផរណាមានកម្រិត ២,៥% ដែលបណ្តាលមកពីមូលដ្ឋានគណនាទាប និងការកើនឡើងនៃថ្លៃម្ហូបអាហារ ខណៈថ្លៃប្រេងនៅពិភពលោកបានបន្តថយចុះ។ អត្រាប្តូរប្រាក់មានស្ថិរភាពល្អប្រសើរ ក្នុងកម្រិតមធ្យម ៤.០១១ រៀល ក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានឡើងថ្លៃជាមធ្យម ១,៥% ធៀបនឹងឆ្នាំ២០២៤។ សមតុល្យជញ្ជីងទូទាត់មានអតិរេក ៨៨១,៣ លានដុល្លារអាមេរិក ដែលត្រូវបានគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២៧,៥ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៨ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។

**ក្របខណ្ឌនយោបាយរូបិយវត្ថុត្រូវបានធ្វើទំនើបកម្ម ដោយការអភិវឌ្ឍកូរីដ័រអត្រាការប្រាក់ និងការគ្រប់គ្រងសន្ទនីយភាព ដើម្បីពង្រឹងយន្តការចម្លងនយោបាយរូបិយវត្ថុ។** ការអនុវត្តកូរីដ័រអត្រាការប្រាក់បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាអាចកំណត់អត្រាការប្រាក់យោងមួយ ដែលនឹងមានឥទ្ធិពលដល់ការកំណត់អត្រាការប្រាក់នៅលើទីផ្សារ។ អត្រាការប្រាក់អន្តរធនាគារជាប្រាក់រៀលមានកម្រិតជាមធ្យម ៣,០៧% សម្រាប់ឥណប្រតិទានពី ១-៣០ថ្ងៃ។ ការស្រូបសន្ទនីយភាពជាប្រាក់រៀលតាមរយៈមូលបត្រអាចជួញដូរ (NCD) បានមានទំហំ ៤៩,៤ ទ្រីលានរៀល ខណៈប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា មានទំហំ ១,៧ ប៊ីលានរៀល និង ៤,១ ទ្រីលានរៀល រៀងគ្នា។ គួររំលេចថា កម្រិតដុល្លារូបនីយកម្មខ្ពស់បន្តរារាំងដល់ការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅមានកម្រិត ៨៥%។

**ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ ខណៈទទួលរងផលប៉ះពាល់ដោយប្រយោលពីភាពមិនប្រាកដប្រជានៃកត្តាខាងក្រៅ និងបញ្ហាប្រឈមក្នុងស្រុក។** ទ្រព្យសកម្មប្រព័ន្ធធនាគារបានកើនឡើង ៩,៥% ប៉ុន្តែឥណទានបន្តមានកំណើនយឺត ៤,១%។ ប្រាក់បញ្ញើរក្សាបានកំណើនរឹងមាំក្នុងអត្រា ១៤,៧% ដែលឆ្លុះបញ្ចាំងពីជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារ។ ឥណទានមិនដំណើរការបន្តនិន្នាការកើនឡើងដល់ ៨,៩% ប៉ុន្តែត្រូវបានធ្វើសំវិធានធនប្រមាណ ៦៧,៥%។ ម្យ៉ាងទៀត ដើមទុននិងសន្ទនីយភាពក៏ត្រូវបានរក្សានៅកម្រិតខ្ពស់ជាងបទប្បញ្ញត្តិ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិត ២១,៩% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣១,៤% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ហើយអនុបាតសន្ទនីយភាពមានកម្រិត ១៧៧,៣% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ទន្ទឹមនេះ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ

និងហិរញ្ញវត្ថុត្រូវបានពង្រឹងជាប្រចាំដោយផ្អែកលើហានិភ័យនិងទស្សនៈអនាគត ហើយការចុះត្រួតពិនិត្យដល់ទីកន្លែងត្រូវបានធ្វើឡើងចំពោះ ៥៥ គ្រឹះស្ថាន។

**បទប្បញ្ញត្តិត្រូវបានកែសម្រួលនិងដាក់ចេញជាបន្តបន្ទាប់ ដើម្បីធានាវឌ្ឍនភាពនៃប្រព័ន្ធធនាគារនិងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។** ស្របតាមការវិវត្តនៃប្រព័ន្ធធនាគារនិងស្តង់ដាអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិពាក់ព័ន្ធនឹងការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ការកំណត់ទ្រនាប់ដើមទុន និងវិធានការបុរេសកម្ម ព្រមទាំងកំពុងរៀបចំនិងកែសម្រួលប្រកាសនិងសេចក្តីណែនាំមួយចំនួនពាក់ព័ន្ធនឹងការផ្តល់សន្ទនីយភាព ការកំណត់ពិតានអត្រាការប្រាក់ ក្របខណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ការគួបសរុបផ្នែកបទប្បញ្ញត្តិ និងការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមតែរមិន។ លើសពីនេះ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២៥-២០៣០ ត្រូវបានដាក់ចេញក្នុងគោលដៅរក្សាស្ថិរភាព ពង្រឹងទំនើបកម្ម ជំរុញនវានុវត្តន៍ និងលើកកម្ពស់បរិយាប័ន្ននៅក្នុងវិស័យហិរញ្ញវត្ថុ។

**បរិយាបន្នហិរញ្ញវត្ថុត្រូវបានបន្តលើកកម្ពស់និងមានវឌ្ឍនភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។** ចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនដល់ ១៨,៦ លាននាក់ និងចំនួនអ្នកប្រើប្រាស់សេវាឥណទានកើនដល់ ៤,៣ លាននាក់។ លើសពីនេះ ចំនួនស្ត្រីដែលបានប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការក្នុងវិស័យធនាគារមានប្រមាណ ៥៣% សម្រាប់សេវាឥណទាន និង ៥១% សម្រាប់សេវាប្រាក់បញ្ញើ។ ប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងបានកើនឡើង ១,២ ដង ដល់ ១.៣២៥,៦៥ លានប្រតិបត្តិការ ដែលក្នុងនោះ ៧៧១,២ លានប្រតិបត្តិការជាប្រាក់រៀល និង ៥៥៤,៥ លានប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក ខណៈដែលចំនួនគណនីកាបូបអេឡិចត្រូនិកមានប្រមាណ ១៨,៩ លានគណនី។ ជាមួយគ្នានេះ យុទ្ធសាស្រ្តជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ កំពុងត្រូវបានធ្វើបច្ចុប្បន្នកម្មសម្រាប់ឆ្នាំ២០២៦-២០៣០ ដើម្បីបន្តធានាបានការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ននិងចីរភាព។ ចំពោះកិច្ចការពារអតិថិជន ធនាគារជាតិនៃកម្ពុជាបានទទួលបណ្តឹងអតិថិជនតាមរយៈប្រព័ន្ធហាតឡាញចំនួន ៧២១ ករណី ក្នុងនោះ ៦៨៣ ករណី ត្រូវបានដោះស្រាយរួចរាល់ ១២ ករណី កំពុងត្រូវបានដោះស្រាយ និង ២៦ ករណី ស្ថិតក្នុងនីតិវិធីតុលាការ។

**កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ត្រូវបានបន្តពង្រឹងនិងពង្រីក តាមរយៈការចុះអនុស្សរណៈនៃការយោគយល់ ការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធ និងការអនុវត្តគម្រោងជំនួយបច្ចេកទេស។** ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និងអាស៊ាន+៣ ព្រមទាំងចុះអនុស្សរណៈយោគយល់ និងសហការជាមួយស្ថាប័នអន្តរជាតិនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការតភ្ជាប់ប្រព័ន្ធទូទាត់ទាំងក្នុងនិងក្រៅតំបន់ ហិរញ្ញប្បទានឌីជីថលបៃតង និងការគ្រប់គ្រងវិបត្តិ ជាដើម។ កិច្ចសហប្រតិបត្តិការទាំងនេះក៏បានលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញស្របតាមការវិវត្តនៃវិស័យហិរញ្ញវត្ថុនិងបច្ចេកវិទ្យាជាសកល និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារ ជាពិសេសពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុទាំងក្នុងស្រុកនិងតំបន់។

**អភិបាលកិច្ចត្រូវបានពង្រឹងជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និងគ្រប់គ្រងហានិភ័យ ខណៈការអភិវឌ្ឍធនធានមនុស្សបន្តជាការងារអាទិភាព។** ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចត្រូវបានអនុវត្តប្រកបដោយភាពយកចិត្តទុកដាក់ ទាំងនៅស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត ដោយបានផ្តោតសំខាន់លើការការពារហានិភ័យ ធានាសុវត្ថិភាពសាច់ប្រាក់ក្នុងឃ្លាំង និងការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីការងារ និងសេចក្តីណែនាំផ្សេងៗ។ បច្ចុប្បន្ន មន្ត្រី-បុគ្គលិកសរុបរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន ២.១២៦រូប (ស្រី ៤៩%) ស្របពេលដែលសមត្ថភាពជំនាញនិងឯកទេសកម្ម ត្រូវបានយកចិត្តទុកដាក់អភិវឌ្ឍជាលំដាប់ តាមរយៈការបណ្តុះបណ្តាល

ទាំងក្នុងនិងក្រៅប្រទេស និងតាមប្រព័ន្ធអនឡាញ។ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍចំណេះដឹងនិងជំនាញក្នុងវិស័យធនាគារសម្រាប់និស្សិត ដោយចាប់ផ្តើមដំណើរការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំ២០២៥។

**ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ត្រូវបានអនុវត្តយ៉ាងសកម្ម។** ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ សិក្ខាសាលា ការតាំងពិព័រណ៍នៅតាមរាជធានី-ខេត្ត និងសហការជាមួយភាគីពាក់ព័ន្ធ ជាដើម។ ការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ និងការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកជូនសាធារណជន ត្រូវបានបន្តពង្រឹង ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ប្រាក់រៀលនិងការពារការខាតបង់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ សារមន្ទីរ ស.ស.រ. បានរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ចំណេះដឹងអំពីប្រវត្តិសាស្ត្រនៃសេដ្ឋកិច្ចនិងរូបិយវត្ថុ ដោយបានស្វាគមន៍ភ្ញៀវមកទស្សនាចំនួន ៩៣.៥៨៥ នាក់។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបំពេញមុខងារ-ភារកិច្ចប្រកបដោយការទទួលខុសត្រូវ និងបុរេសកម្ម ដើម្បីរួមចំណែកពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការវិវត្តយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យា និងនិន្នាការថ្មីៗ។** ស.ហ.ក. បានពង្រឹងការអនុវត្តការងារដូចជា៖ i/-ការបន្តទទួលរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ ii/-ការត្រួតពិនិត្យនូវអនុលោមភាពរបស់បុគ្គលរាយការណ៍ iii/- ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ និង iv/- ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបុគ្គលរាយការណ៍។ ជាមួយគ្នានេះ ស.ហ.ក. បានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធយ៉ាងយកចិត្តទុកដាក់ក្នុងការបំពេញការងារវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**សម្រាប់ទស្សនវិស័យឆ្នាំ២០២៦ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងអាចសម្រេចបានក្នុងរង្វង់ ៥% និងអត្រាអតិផរណា ២,៣%។** នយោបាយរូបិយវត្ថុនឹងត្រូវបន្តអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្ន ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់ ដែលនឹងគាំទ្រដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងភាពធន់ប្រព័ន្ធធនាគារ តាមរយៈការពង្រឹងក្របខណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដើម្បីបន្តការពារស្ថិរភាពហិរញ្ញវត្ថុ។ លើសពីនេះ ប្រព័ន្ធទូទាត់នឹងត្រូវបានធ្វើទំនើបកម្មជាលំដាប់ សំដៅរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ប្រព័ន្ធការពារប្រាក់បញ្ញើក៏កំពុងត្រូវបានអភិវឌ្ឍ ដើម្បីពង្រឹងបន្ថែមទៀតនូវជំនឿទុកចិត្តលើប្រព័ន្ធធនាគារ ស្របពេលដែលសេចក្តីព្រាងប្រព័ន្ធវដ្តករសាស្ត្រស្តីពីហិរញ្ញវត្ថុប្រកបដោយចីរភាព និងផែនទីចង្អុលទិសហិរញ្ញវត្ថុប្រកបដោយចីរភាព គ្រោងនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលឆាប់ៗ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព។ ទោះយ៉ាងណា សេដ្ឋកិច្ចបន្តប្រឈមនឹងហានិភ័យពីខាងក្រៅ ជាពិសេសភាពតានតឹងភូមិសាស្ត្រនយោបាយ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងការឆបោកតាមប្រព័ន្ធអនឡាញ ខណៈដែលទទួលរងសម្ពាធពីកត្តាខាងក្នុងមួយចំនួនដូចជា ភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ និងផលប៉ះពាល់ពីការអូសបន្លាយជម្លោះព្រំដែនកម្ពុជា-ថៃ ជាដើម។

# ផ្នែកទី១-របាយការណ៍ប្រចាំឆ្នាំ២០២៥

# I- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

## ១- បរិស្ថានសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារបញ្ហាភូមិសាស្ត្រនយោបាយសេដ្ឋកិច្ច ជម្លោះប្រដាប់អាវុធ និងការដាក់ចេញនូវពន្ធគយបដិការរបស់សហរដ្ឋអាមេរិក។ ភាពផុយស្រួយនៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ការព្រួយបារម្ភពីចីរភាពសារពើពន្ធ និងការកើនឡើងហានិភ័យពីការប្រែប្រួលអាកាសធាតុ នៅតែជាបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោកនាពេលអនាគត។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**

(គិតជាភាគរយ, ឆ្នាំ២០២៤ - ឆ្នាំ២០២៦ព)




ប្រភព៖ របាយការណ៍ WEO និង REO របស់ IMF

សម្គាល់៖ ប = ប៉ាន់ស្មាន, ព = ព្យាករណ៍

នាឆ្នាំ២០២៥ មូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ស្មានថា កំណើនសេដ្ឋកិច្ចពិភពលោកមានកម្រិត ៣,២% (ថមថយបន្តិចពី ៣,៣% នាឆ្នាំ២០២៤) ជាចម្បងដោយសារភាពមិនប្រាកដប្រជា និងនយោបាយគាំពារនិយម ទោះបីជាផលប៉ះពាល់ពន្ធគយបដិការមានទំហំតូចជាងការរំពឹងទុកក៏ដោយ។ ទោះយ៉ាងណា សេដ្ឋកិច្ចពិភពលោក នៅតែប្រឈមនឹងការអូសបន្លាយនៃភាពមិនប្រាកដប្រជានៃគោលនយោបាយ ដែលអាចកាត់បន្ថយចំណាយប្រើប្រាស់និងចំណាយវិនិយោគ។ ការកើនឡើងនៃវិធានការគាំពារនិយមដូចជាការដាក់របាំងមិនមែនពន្ធគយ ក៏អាចនឹងកាត់បន្ថយការវិនិយោគ បង្អាក់ខ្សែច្រវាក់ផ្គត់ផ្គង់ និងរារាំងកំណើនផលិតភាព។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មានកំណើន ១,៦%[១] (១,៨% នាឆ្នាំ២០២៤) និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ ៤,២%[២] (៤,៣% នាឆ្នាំ២០២៤)។ សេដ្ឋកិច្ចតំបន់អាស៊ានក៏បានថមថយបន្តិចមកត្រឹម ៤,៣% (៤,៨% នាឆ្នាំ២០២៤) ជាចម្បងដោយសារពន្ធគយបដិការ និងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុក។

**ក្រាហ្វ ២៖ សមាមាត្រ ផ.ស.ស. ពិភពលោក**

(ឆ្នាំ២០២៤)




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

**កំណើនសេដ្ឋកិច្ចពិភពលោក**



ផ.ស.ស. ពិភពលោក

▲ ៣,២%

*(៣,៣% ឆ្នាំមុន)*



អត្រាអតិផរណាពិភពលោក

▲ ៤,២%

*(៥,៨% ឆ្នាំមុន)*

---

[១] សហរដ្ឋអាមេរិក ២% (២,៨% ឆ្នាំ២០២៤) តំបន់អឺរ៉ូ ១,២% (០,៩% ឆ្នាំ២០២៤) ជប៉ុន ១,១% (០,១% ឆ្នាំ២០២៤) អង់គ្លេស ១,៣% (១,១% ឆ្នាំ២០២៤) កាណាដា ១,២% (១,៦% ឆ្នាំ២០២៤) និងប្រទេសអភិវឌ្ឍន៍ផ្សេងទៀត ១,៨% (២,៣% ឆ្នាំ២០២៤)។

[២] ប្រទេសចិន ៤,៨% (៥% ឆ្នាំ២០២៤) ឥណ្ឌា ៦,៦% (៦,៥% ឆ្នាំ២០២៤) ប្រេស៊ីល ២,៤% (៣,៤% ឆ្នាំ២០២៤) រុស្ស៊ី ០,៦% (៤,៣% ឆ្នាំ២០២៤) និងម៉ិកស៊ិក ១% (១,៤% ឆ្នាំ២០២៤)។

អតិផរណាសកលបានបន្តថយចុះជាលំដាប់ ដែលជាចម្បងបណ្តាលមកពីការថយចុះថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារ ខណៈដែលការអនុវត្តគោលនយោបាយគាំពារនិយមមិនមានឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់ស្ថានភាពថ្លៃនៅឡើយ។ អត្រាអតិផរណាពិភពលោកបានថមថយមក ៤,២%[៣] (៥,៨% នាឆ្នាំ២០២៤) ដែលក្នុងនោះ ប្រទេសអភិវឌ្ឍន៍មានកម្រិត ២,៥%[៤] (២,៦% នាឆ្នាំ២០២៤) និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ ៤,៩% (៦,៧% នាឆ្នាំ២០២៤)។ កម្រិតទាបនៃអតិផរណានេះបានអនុញ្ញាតឱ្យធនាគារកណ្តាលនៃប្រទេសចម្បងៗបន្ទាបអត្រាការប្រាក់គោលដើម្បីជំរុញកំណើនសេដ្ឋកិច្ច។

នៅក្នុងប្រទេសអាស៊ាន-៥[៥] អតិផរណាបន្តមានកម្រិតទាបនិងអាចគ្រប់គ្រងបាន ដែលស្ថិតនៅក្រោម ៤% ហើយអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលភាគច្រើនត្រូវបានបន្ទាបដោយប្រុងប្រយ័ត្ន។

**ក្រាហ្វ ៣៖ អតិផរណា**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៦ព)




ប្រភព៖ របាយការណ៍ WEO របស់ IMF

សម្គាល់៖ ប = ប៉ាន់ស្មាន, ព = ព្យាករណ៍

**ក្រាហ្វ ៤៖ អត្រាការប្រាក់គោលនៃប្រទេសចម្បងៗ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ គេហទំព័រ Trading Economics

**ក្រាហ្វ ៥៖ អតិផរណានៃប្រទេសអាស៊ាន-៥**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ គេហទំព័រ Trading Economics

**ក្រាហ្វ ៦៖ អត្រាការប្រាក់គោលនៃប្រទេសអាស៊ាន-៥**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ គេហទំព័រ Trading Economics

[៣] ការថមថយនៃកម្រិតអតិផរណាពិភពលោកជាចម្បងបណ្តាលមកពីការថយចុះនៃតម្រូវការក្នុងស្រុកនិងតម្លៃប្រេងឆៅ គួបផ្សំនឹងកម្រិតខ្ពស់នៅឡើយនៃអត្រាការប្រាក់គោល។

[៤] អតិផរណាប្រទេសអភិវឌ្ឍន៍ត្រូវបានព្យាករថានឹងបន្តថយចុះខិតកៀកមករកអត្រាគោលដៅ ២% ក្នុងឆ្នាំ២០២៦។

[៥] ប្រទេសអាស៊ាន-៥ រួមមាន ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី វៀតណាម ហ្វីលីពីន និងថៃ។

ទំហំពាណិជ្ជកម្មនៃទំនិញនិងសេវាកម្មអន្តរជាតិត្រូវបានព្យាករថាមានកំណើន ៣,៦% (កើនបន្តិចពី ៣,៥% នាឆ្នាំ២០២៤) ដែលបណ្តាលមកពីការពន្លឿននៃការបញ្ជាទិញឱ្យបានមុនសុពលភាពនៃពន្ធគយបដិការ ស្របពេលដែលសេវាកម្មដឹកជញ្ជូននិងសេវាកម្មដំណើរកម្សាន្តមានកំណើនទាប។ ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្ម និងការកើនឡើងនៃវិធានការគាំពារនិយមតាមរយៈវិធានការពន្ធគយនិងមិនមែនពន្ធគយនៅតែជាបញ្ហាប្រឈមដល់ពាណិជ្ជកម្មអន្តរជាតិ ដែលអាចនាំឱ្យរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់។

**ក្រាហ្វ ៧៖ កំណើនទំហំពាណិជ្ជកម្មទំនិញនិងសេវាកម្មអន្តរជាតិ**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៦ព)




ប្រភព៖ របាយការណ៍ WEO របស់ IMF, សម្គាល់៖ ប = ប៉ាន់ស្មាន , ព = ព្យាករណ៍

## ២- កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២៥ ត្រូវបានប៉ាន់ស្មានថាអាចសម្រេចបានកំណើនក្នុងអត្រា ៥% ជាចម្បងគាំទ្រដោយកំណើនការនាំចេញវិស័យកម្មន្តសាល ជាពិសេសការពន្លឿនការនាំចេញនាឆមាសទី១ មុនពេលដែលពន្ធគយបដិការរបស់សហរដ្ឋអាមេរិកចូលជាធរមាន ដែលដំបូងឡើយបានប្រកាសកាលពីខែមេសា មានកម្រិត ៤៩% និងគ្រោងអនុវត្តនាដើមឆមាសទី២ ឆ្នាំ២០២៥។ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការចរចាជាមួយសហរដ្ឋអាមេរិក ពន្ធគយបដិការត្រូវបានបន្ថយជាបន្តបន្ទាប់មក ៣៦% នាថ្ងៃទី៧ ខែកក្កដា ហើយថយមកត្រឹម ១៩% នាថ្ងៃទី១ ខែសីហា។ ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចនេះមានកម្រិតទាបជាងការរំពឹងទុក ដោយសារការធ្លាក់ចុះនៃចំនួនទេសចរ។

ក្រាហ្វ ៨៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ

(គិតជាភាគរយ, ឆ្នាំ២០១៩-២០២៥ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន



**វិស័យកម្មន្តសាល**

▲ ៨,៥%

*(១១,៦% ក្នុងឆ្នាំ២០២៤)*

វិស័យកម្មន្តសាលនៅតែបន្តជាសសរស្តម្ភយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាដែលត្រូវបានប៉ាន់ស្មានថាមានកំណើនល្អក្នុងអត្រា ៨,៥% បើទោះបីជាមានកំណើនទាបជាងកាលពីឆ្នាំ២០២៤ (១១,៦%) ក៏ដោយ។ ផលិតផលកម្មន្តសាលកាត់ដេរត្រូវបានប៉ាន់ស្មានថាកើនឡើង ៧,១% (១៥,៨% នាឆ្នាំ២០២៤) ស្របពេលដែលផលិតផលកម្មន្តសាលមិនមែនកាត់ដេរកើនឡើង ១០% (៦,៩% នាឆ្នាំ២០២៤) ដែលក្នុងនោះផលិតផលមួយចំនួនដែលកំពុងមានកំណើនឆាប់រហ័សមានដូចជាសំបកកង់រថយន្ត អំពូលភ្លើង ផលិតផលធ្វើពីឈើ និងខ្សែភ្លើងនិងបង្គុំខ្សែភ្លើងជាដើម។ ការបន្តកើនឡើងនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរបានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែង និងផ្លែផ្កានៃការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ គួររំលេចថាការផ្ទុះអាវុធកម្ពុជា-ថៃទាំងពីរលើក[៦] បានបង្កឱ្យមានផលប៉ះពាល់មួយចំនួនតូចដល់រោងចក្រសហគ្រាសដែលស្ថិតនៅជាប់ព្រំដែន ប៉ុន្តែក៏បានជួយជំរុញការបង្កើនផលិតកម្មក្នុងស្រុកជាពិសេសសម្រាប់សហគ្រាសធុនតូចនិងមធ្យមដែលនឹងក្លាយជាប្រភពថ្មីមួយសម្រាប់គាំទ្រកំណើនសេដ្ឋកិច្ច និងជួយពន្លឿនដំណើរការពិពិធកម្មសេដ្ឋកិច្ចផងដែរ។

ក្រាហ្វ ៩៖ តម្លៃនិងកំណើនផលិតផលកម្មន្តសាលសរុប

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន

[៦] ការផ្ទុះអាវុធកម្ពុជា-ថៃលើកទី១ (ចាប់ពីថ្ងៃទី២៤-២៨ ខែកក្កដា ឆ្នាំ២០២៥) និង ការផ្ទុះអាវុធកម្ពុជា-ថៃលើកទី២ (ចាប់ពីថ្ងៃទី៧-២៧ ខែធ្នូ ឆ្នាំ២០២៥)។



រូបភាព៖ សកម្មភាពផ្គុំ និងដំឡើងបន្ទះសូឡារបស់ក្រុមហ៊ុន Zhongqi Photovoltaic Technology (Cambodia) Co., Ltd. នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល ខេត្តក្រចេះ
ប្រភព៖ Fresh News



រូបភាព៖ សកម្មភាពផលិតសម្បកកង់យានយន្តរបស់ក្រុមហ៊ុន Newbustar (Cambodia) Tire Co.,Ltd. នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ីស្នួល ខេត្តក្រចេះ
ប្រភព៖ ក្រសួងព័ត៌មាន





**វិស័យទេសចរណ៍**

**▲ ៥,១%**

*(១៣,២% ក្នុងឆ្នាំ២០២៤)*

វិស័យទេសចរណ៍បានបន្តងើបឡើងវិញនាឆមាសទី១ ឆ្នាំ២០២៥ ដែលគាំទ្រដោយការធ្វើពិពិធកម្មទិសដៅទេសចរណ៍ និងការបង្កើនការតភ្ជាប់ជើងហោះហើរត្រង់ គួបផ្សំនឹងការដាក់ឱ្យដំណើរការអាកាសយានដ្ឋានអន្តរជាតិថ្មីៗ ដែលជាសក្តានុពលក្នុងការទាក់ទាញភ្ញៀវអន្តរជាតិ។ ទោះជាយ៉ាងណាចាប់ពីដើមឆមាសទី២ ឆ្នាំ២០២៥ ការផ្ទុះអាវុធកម្ពុជា-ថៃទាំងពីរលើក[៧]និងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានៅក្នុងតំបន់បានធ្វើឱ្យវិស័យទេសចរណ៍ទទួលរងផលប៉ះពាល់ដែលធ្វើឱ្យកំណើនក្នុងវិស័យនេះថមថយមកត្រឹម ៥,១% (១៣,២% នាឆ្នាំ២០២៤)។ ភ្ញៀវអន្តរជាតិសរុបបានធ្លាក់ចុះ -១៦,៩% មក ៥,៦ លាននាក់ (៦,៧ លាននាក់ នាឆ្នាំ២០២៤) ដែលក្នុងនោះ ភ្ញៀវវៀតណាមឈរនៅលំដាប់ទី១ (សមាមាត្រ ២១,៩% នៃភ្ញៀវអន្តរជាតិសរុប) បន្ទាប់មកភ្ញៀវចិន (២១,៦%) និងភ្ញៀវថៃ (១៨,៤%)។ គួរបញ្ជាក់ថា ភ្ញៀវចិន និងភ្ញៀវមកពីតំបន់អឺរ៉ុបក៏មានកំណើនល្អធៀបនឹងឆ្នាំមុនផងដែរ។

គួររំលេចថា ភ្ញៀវអន្តរជាតិតាមផ្លូវអាកាសបានកើនឡើង ១៩,២% ខណៈតាមផ្លូវគោកនិងផ្លូវទឹកធ្លាក់ចុះ -៣៧% ដែលធ្វើឱ្យសមាមាត្រនៃភ្ញៀវអន្តរជាតិតាមផ្លូវអាកាសឡើងដល់ ៥១,៣% នៃភ្ញៀវអន្តរជាតិសរុប (៣៥,៨% នាឆ្នាំ២០២៤) និងសមាមាត្រនៃភ្ញៀវធ្វើដំណើរតាមផ្លូវគោកនិងផ្លូវទឹកធ្លាក់មក ៤៨,៧% (៦៤,២% នាឆ្នាំ២០២៤)។

[៧] ការផ្ទុះអាវុធកម្ពុជា-ថៃលើកទី១ (ចាប់ពីថ្ងៃ២៤-២៨ ខែកក្កដា ឆ្នាំ២០២៥) និង ការផ្ទុះអាវុធកម្ពុជា-ថៃលើកទី២ (ចាប់ពីថ្ងៃ៧-២៧ ខែធ្នូ ឆ្នាំ២០២៥)។

ចំណូលទេសចរណ៍អន្តរជាតិសរុបត្រូវបានប៉ាន់ស្មានថាទទួលបានប្រមាណ ៣,៧ ប៊ីលានដុល្លារអាមេរិកដែលកើន ៣% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ខណៈដែលចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរថយចុះ -៦,៥% មក ៥៤,៧ លានដុល្លារអាមេរិក[៨]។

ទេសចរក្នុងស្រុកបន្តមានកំណើន ១១,៧% ដល់ ២៥,២ លាននាក់។ រាជធានីភ្នំពេញឈរនៅលំដាប់ទី១ ដែលជាតំបន់ទទួលទេសចរច្រើនជាងគេ ដោយមានសមាមាត្រ ៣៩,៧% នៃទេសចរក្នុងស្រុកសរុប និងតំបន់ឆ្នេរជាប់លំដាប់ទី២ (៣៧,៩%) បន្ទាប់មកខេត្តសៀមរាបនៅលំដាប់ទី៣ (១២,៩%) និងតំបន់អេកូទេសចរណ៍នៅលំដាប់ទី៤ (២,២%)។

**ក្រាហ្វ ១០៖ ភ្ញៀវអន្តរជាតិ**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងទេសចរណ៍

**ក្រាហ្វ ១១៖ ទេសចរក្នុងស្រុក**

(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងទេសចរណ៍

**ក្រាហ្វ ១២៖ ចំណូលភ្ញៀវអន្តរជាតិ**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងទេសចរណ៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)



រូបភាព៖ អាកាសយានដ្ឋានអន្តរជាតិតេជោ (KTI) ដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥

ប្រភព៖ គេហទំព័រ កម្ពុជាថ្មី




រូបភាព៖ ផ្លូវថ្មើរជើងចតុមុខ (Walk Street) ដែលបានបើកសម្ពោធជាផ្លូវការនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៥

ប្រភព៖ គេហទំព័រ BTV News

[៨] ប្រភពពីគ្រឹះស្ថានអង្គរ។

វិស័យកសិកម្មបន្តរក្សាបានកំណើន ០,៧៣% ប្រហាក់ប្រហែលនឹងឆ្នាំមុន (០,៩៦%) បើទោះបីជាប្រឈមនឹងបញ្ហាតម្លៃស្រូវសកល និងការផ្ទុះអាវុធកម្ពុជា-ថៃ ជាពិសេសការផ្ទុះអាវុធលើកទី២។ ផលស្រូវបានកើន ៩,៧% ដល់ប្រមាណ ១៥,៣ លានតោន ដែលក្នុងនោះផលស្រូវរដូវប្រាំងបានកើន ១០,៩% ដល់ ៤,៣ លានតោន និងផលស្រូវរដូវវស្សាកើន ៩,២% ដល់ ១១ លានតោន។ បើទោះជាបរិមាណផលស្រូវបន្តមានកំណើនក្នុងឆ្នាំនេះក៏ដោយ តម្លៃស្រូវបានទទួលរងសម្ពាធធ្លាក់ចុះ ដោយសារការកើនឡើងនៃការផ្គត់ផ្គង់និងការបង្កើនការនាំចេញអង្ករពីបណ្ដាប្រទេសផលិតធំៗ គួបផ្សំនឹងការផ្អាកការនាំចូលអង្ករនៃប្រទេសមួយចំនួន។ ទន្ទឹមនេះ ការផ្ទុះអាវុធលើកទី២ បានធ្វើឱ្យមានផលប៉ះពាល់តិចតួចផងដែរដល់ការប្រមូលផលស្រូវចុងឆ្នាំនៅតំបន់មួយចំនួនតាមតំបន់ជាប់ព្រំដែន ដោយសារប្រជាពលរដ្ឋបានភៀសខ្លួនចេញពីតំបន់ផ្ទុះអាវុធ។



**វិស័យកសិកម្ម**

**▲ ០,៧៣%**

*(០,៩៦% ក្នុងឆ្នាំ២០២៤)*

គួររំលេចថា អង្ករក្រអូបប្រណីតកម្ពុជាបន្តជាប់ពានរង្វាន់ជាអង្ករប្រណីតល្អបំផុតលើពិភពលោក លើកទី៧ នៅក្នុងកម្មវិធីសន្និសីទស្រូវអង្ករពិភពលោកឆ្នាំ២០២៥ ដែលរៀបចំដោយ The Rice Trader នៅព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ គ្រាប់ស្វាយចន្ទីដែលបានដើរតួនាទីសំខាន់ក្នុងការជំរុញការនាំចេញផលិតផលកសិកម្មក៏ទទួលបានផលប្រមាណ ៩០០ ពាន់តោន ក្នុងឆ្នាំ២០២៥ ដោយបានកើន ១,៦% ដែលរួមចំណែកជាចម្បងដោយកំណើនតម្រូវការខាងក្រៅ។

**ក្រាហ្វ ១៣៖ ផលស្រូវ**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ១៤៖ ផលគ្រាប់ស្វាយចន្ទី**

(ឆ្នាំ២០២១ - ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា)

ជាមួយគ្នានេះ ផលជ័រកៅស៊ូបានកើន ២,២% ដល់ ៤១៨,២ ពាន់តោន ស្របពេលដែលតម្លៃកៅស៊ូជាមធ្យមបានបន្តកើនឡើង ៩,១% ដល់ ១.៨១៤ ដុល្លារអាមេរិក/តោន។ ធនធានជលផលសរុបបានកើនប្រមាណ ១០,៦% ដែលក្នុងនោះផលនេសាទទឹកសាបនិងសមុទ្រកើន ១៣,៦% ស្របពេលដែលផលវារីវប្បកម្ម[១០]ក៏បានកើន ៥% ដោយសារការបន្តបង្ក្រាបបទល្មើសនេសាទខុសច្បាប់ និងការវិនិយោគក្នុងវិស័យវារីវប្បកម្ម។

[១០] វារីវប្បកម្ម សំដៅលើការចិញ្ចឹមត្រី បង្កង បង្គា និងកង្កែបៗល។

**ក្រាហ្វ ១៥៖ ផលនិងតម្លៃជ័រកៅស៊ូ**

(ឆ្នាំ២០១៩ -ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ១៦៖ អនុវិស័យជលផល**

(គិតជាភាគរយ, ឆ្នាំ២០១៩ -ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)




រូបភាព៖ អង្គរក្រអូបម៉ាកវិញ្ញាតកម្ម "ម្លិះអង្គរ" ពូជស្រូវផ្ការំដួល បានឈ្នះពានរង្វាន់ World Best Rice ជាលើកទី៧ នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៥
ប្រភព៖ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម



រូបភាព៖ ចម្ការចន្ទីនិងគ្រាប់ស្វាយចន្ទី ខេត្តកំពង់ធំ

វិស័យសំណង់មានកំណើនទាបត្រឹម ០,៤% ធៀបនឹង ១,២% នាឆ្នាំ២០២៤ ដោយសារភាពទន់ខ្សោយនៃតម្រូវការគួបផ្សំភាពលើសនៃការផ្គត់ផ្គង់នាពេលកន្លងមក។ ទោះជាតម្រូវការនៅមានកម្រិតទាប ការផ្គត់ផ្គង់សំណង់ថ្មីៗនៅតែបន្តជ្រៀតចូលក្នុងទីផ្សារតាមរយៈការអនុម័តគម្រោងសំណង់ថ្មីៗ និងកំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ដែលបានកើន ៤០,១% ធៀបនឹង ៣៣,២% ឆ្នាំមុន។



**វិស័យសំណង់**

▲ ០,៤%

*(១,២% ក្នុងឆ្នាំ២០២៤)*

តម្លៃគម្រោងសំណង់ទទួលបានការអនុម័តបានកើនឡើង ៤៨,៣% ដែលក្នុងនោះ សំណង់ក្នុងវិស័យកម្មន្តសាល (សមាមាត្រ ៤៨,៩% នៃតម្លៃគម្រោងសំណង់សរុប) កើនជាង ១ដង សំណង់លំនៅឋាន (សមាមាត្រ ៣២,៥%) កើន ៦៦,៥% និងសំណង់ក្នុងវិស័យទេសចរណ៍ (សមាមាត្រ ៥,១%) កើន ៧២,១% ខណៈសំណង់ក្នុងវិស័យពាណិជ្ជកម្ម (សមាមាត្រ

១១,១%) និងសំណង់សាធារណៈ (សមាមាត្រ ២,៩%) ថយចុះ -៤២,៥% និង -៣៩,៤% រៀងគ្នា។ គួររំលេចថា គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មីចំនួន ៦ ត្រូវបានអនុម័តដែលឆ្លុះបញ្ចាំងពីកំណើនសកម្មភាពសំណង់ក្នុងវិស័យកម្មន្តសាលនាពេលខាងមុខ។

វិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់ត្រូវបានប៉ាន់ស្មានថាបន្តថយចុះ -៧,៧% ប៉ុន្តែក្នុងកម្រិតទាបជាង -២៥,៨% នាឆ្នាំ២០២៤ ស្របពេលដែលឥណទានទៅកាន់វិស័យសំណង់បានកើនឡើងក្នុងល្បឿនយឺត ៧% គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥ (១៥,៤% ក្នុងរយៈពេលដូចគ្នាឆ្នាំមុន)។ ទន្ទឹមនេះ ការផ្ទុះអាវុធកម្ពុជា-ថៃទាំងពីរលើក ក៏បានជះឥទ្ធិពលមួយចំនួនតូចទៅលើទំនុកចិត្តវិនិយោគិននៅក្នុងវិស័យនេះផងដែរ។

**ក្រាហ្វ ១៧៖ ការនាំចូលសម្ភារនិងបរិក្ខារសំណង់**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

**ក្រាហ្វ ១៨៖ តម្លៃនិងកំណើនតម្លៃគម្រោងសំណង់**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

វិស័យអចលនទ្រព្យត្រូវបានប៉ាន់ស្មានថាបន្តមានកំណើនយឺតត្រឹម ០,៥% ធៀបនឹង ០,៩% នាឆ្នាំ២០២៤ ដែលរួមចំណែកគាំទ្រដោយការកើនឡើងសកម្មភាពលក់ផ្ទះ[១១] និងការផ្គត់ផ្គង់ខុនដូដែលមានតម្លៃសមរម្យក្នុងទីផ្សារ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ[១២] ខណៈដែលថ្លៃអចលនទ្រព្យមានការថមថយ។




**វិស័យអចលនទ្រព្យ**

**▲ ០,៥%**

*(០,៩% ក្នុងឆ្នាំ២០២៤)*

ការលក់ផ្ទះ[១៣] បានកើនឡើង ៣០,៥% ក្នុងឆ្នាំ២០២៥ (-១៨% នាឆ្នាំ២០២៤) ដែលជំរុញដោយតម្រូវការអចលនទ្រព្យដែលមានតម្លៃសមរម្យ និងភាពងាយស្រួលជាងមុនក្នុងការកក់ប្រាក់ដំបូង ខណៈការលក់ខុនដូថយចុះ -១៩,៦% (៣៥,៦% ឆ្នាំមុន)។

[១១] ផ្ទះសំដៅលើ ផ្ទះល្វែង វីឡាទោល និងវីឡាភ្លោះ។

[១២] ក្រុមហ៊ុនសេវាកម្មអចលនទ្រព្យ CBRE បានប៉ាន់ស្មានថាចំនួនផ្ទះនិងខុនដូកើនឡើងប្រមាណ ៦.០០០ខ្នង និង ៩.៧០០យូនីត ក្នុងឆ្នាំ២០២៥នេះ។

[១៣] ក្នុងរយៈពេល ១១ខែដើមឆ្នាំនេះ ការលក់លំនៅឋានសរុបកើនឡើង ១,៨% (ការលក់ផ្ទះកើនឡើង ៣១,៩% ខណៈដែលខុនដូថយចុះ -២០,៩%) និងរំពឹងថានឹងកើនឡើងក្នុងត្រីមាសបន្ទាប់ ដែលនាំឱ្យមានកំណើន ២,២% ក្នុងឆ្នាំ២០២៥។

ស្របពេលជាមួយគ្នានេះ សន្ទស្សន៍ថ្លៃលំនៅឋាន (RPPI) បានថយចុះជាមធ្យម -៣,៤% ដែលក្នុងនោះនៅរាជធានីភ្នំពេញបានថយចុះ -៣,៦% និងនៅតាមបណ្តាខេត្តថយចុះ -១,៩%។ លើសពីនេះ ឥណទានពីប្រព័ន្ធធនាគារសម្រាប់ទិញលំនៅឋានជាកម្មសិទ្ធិផ្ទាល់ខ្លួនត្រូវបានប៉ាន់ស្មានថានឹងបន្តថយចុះមកត្រឹម -៩%[១៤] (-៥% ក្នុងគ្រាដូចគ្នាឆ្នាំមុន)។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានលើកទឹកចិត្តឱ្យអតិថិជនដែលបង់រំលស់ដោយផ្ទាល់ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ក្នុងការធ្វើបុនហិរញ្ញប្បទានជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលអាចផ្តល់ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនដែលមានលក្ខខណ្ឌសមស្រប។ គួររំលេចថា មុនការផ្ទុះអាវុធកម្ពុជា-ថៃ វិស័យអចលនទ្រព្យនៅតំបន់រងផលប៉ះពាល់ ជាពិសេសខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប មានកំណើនគួរឱ្យកត់សម្គាល់។ ទោះយ៉ាងណាសមាមាត្រនៃសកម្មភាពវិស័យអចលនទ្រព្យនៅតំបន់នេះ ធៀបនឹងសកម្មភាពសរុបមានសមាមាត្រទាបនៅឡើយ ដែលធ្វើឱ្យកំណើនជារួមក្នុងវិស័យនេះ មានការប៉ះពាល់តិចតួចប៉ុណ្ណោះ។

**ក្រាហ្វ ១៩៖ កំណើនសន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា**

(កំណើនជាមធ្យម គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០២១ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ២០៖ កំណើនឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន**

(ឆ្នាំ២០២១ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ២១៖ ចំនួនសកម្មភាពនិងកំណើននៃការលក់លំនៅឋាន**

(ឆ្នាំ២០២១ - ឆ្នាំ២០២៥ប)




ប្រភព៖ និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងការប៉ាន់ស្មានរបស់ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងត្រឹមខែវិច្ឆិកា)

[១៤] ឥណទាននាខែកញ្ញា ឆ្នាំ២០២៥ មិនរួមបញ្ចូលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយសារពុំមានទិន្នន័យការខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន។

## ប្រអប់ ១៖ ការពង្រឹងការងារតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា ឆ្នាំ២០២៥

នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយដោយផ្អែកលើមូលដ្ឋានទិន្នន័យ ធនាគារជាតិនៃកម្ពុជាបានធ្វើអង្កេតមួយចំនួន ដូចជា៖

**១. អង្កេតទំនុកចិត្តធុរកិច្ច**

ការធ្វើអង្កេតទំនុកចិត្តធុរកិច្ចត្រូវបានធ្វើឡើងក្នុងគោលបំណងបង្កើតសន្ទស្សន៍ទំនុកចិត្តធុរកិច្ច សម្រាប់តាមដានការវិវត្តនៃបរិយាកាសសេដ្ឋកិច្ចនិងវិនិយោគ។ លទ្ធផលអង្កេតនេះក៏ត្រូវបានប្រើប្រាស់ជាធាតុចូលសំខាន់ក្នុងការរៀបចំនិងអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ នាឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការអង្កេតទំនុកចិត្តធុរកិច្ចចំនួន ២ លើក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តចំនួន ១៨៖

- ឆមាសទី១ ឆ្នាំ២០២៥៖ ការអង្កេតបានចាប់ផ្តើមអនុវត្តពីថ្ងៃទី១៩ ខែឧសភា ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ ដោយមានការចូលរួមពីក្រុមហ៊ុន-សហគ្រាសដែលបានចុះបញ្ជី (វិស័យក្នុងប្រព័ន្ធ) ចំនួន ៦៦២ និងអាជីវកម្មដែលមិនបានចុះបញ្ជី (វិស័យក្រៅប្រព័ន្ធ) ចំនួន ១.៧៦៨ នាក់ និង
- ឆមាសទី២ ឆ្នាំ២០២៥៖ ការអង្កេតបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ដោយមានការចូលរួមពីក្រុមហ៊ុន-សហគ្រាសក្នុងប្រព័ន្ធចំនួន ៦០៣ និងអាជីវករក្រៅប្រព័ន្ធចំនួន ១.៨០១ នាក់។

**២. អង្កេតទំនុកចិត្តអ្នកប្រើប្រាស់**

ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមធ្វើអង្កេតទំនុកចិត្តអ្នកប្រើប្រាស់សាកល្បងលើកទី១ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តចំនួន ១៨ ដោយបានចុះសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋជាង ៥០០ គ្រួសារ (៥០ គ្រួសារនៅរាជធានីភ្នំពេញ និង ៤៥០ គ្រួសារនៅតាមបណ្តាខេត្ត)។ អង្កេតនេះមានសារៈសំខាន់ក្នុងការស្វែងយល់ពីសុខភាពសេដ្ឋកិច្ច និងវាស់ស្ទង់សុខុមាលភាពហិរញ្ញវត្ថុនៃគ្រួសារ។ លើសពីនេះ អង្កេតនេះនឹងផ្តល់ទិន្នន័យបន្ថែមពីផ្នែកតម្រូវការដែលអាចប្រើប្រាស់ជាសូចនាករសម្រាប់វាយតម្លៃស្ថានភាពនៃការប្រើប្រាស់វិស័យឯកជន ព្រមទាំងជាធាតុចូលបន្ថែមដ៏សំខាន់ដល់ការវាយតម្លៃ វិភាគ និងព្យាករសេដ្ឋកិច្ច និងអតិផរណា។

**៣. អង្កេតថ្លៃទំនិញប្រើប្រាស់រាជធានី-ខេត្ត**

ធនាគារជាតិនៃកម្ពុជាបានធ្វើការសិក្សាតាមដានសន្ទស្សន៍ថ្លៃទំនិញតាមបណ្តារាជធានី-ខេត្ត ក្នុងគោលបំណងប្រើប្រាស់ជាធាតុចូលដ៏សំខាន់មួយ ដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តនយោបាយរូបិយវត្ថុ ផ្តល់លទ្ធភាពក្នុងការវិភាគនិងវាយតម្លៃវឌ្ឍនភាពនិងហានិភ័យនៃការប្រែប្រួលថ្លៃដែលមានឥទ្ធិពលលើនយោបាយរូបិយវត្ថុ។

ការប្រមូលទិន្នន័យចាប់ផ្តើមដំបូងពីខែសីហា ឆ្នាំ២០១៨ ជាប្រចាំថ្ងៃតាមរយៈ Google Sheet ដែលបែងចែកជា ១២ ក្រុម និងមានមុខទំនិញសរុបចំនួន ២៣ មុខទំនិញ។ ដើម្បីធានាដល់ដំណើរការនៃការចងក្រងសន្ទស្សន៍ថ្លៃទំនិញ ប្រកបដោយប្រសិទ្ធភាព សង្គតិភាព និងសុក្រឹត្យភាព នាឆ្នាំ២០២៣ ក្រុមមន្ត្រីជំនាញនៃនាយកដ្ឋានស្ថិតិ សហការជាមួយនឹងនាយកដ្ឋានព័ត៌មានវិទ្យាបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធប្រមូលទិន្នន័យសន្ទស្សន៍ថ្លៃទំនិញជាប្រចាំសប្តាហ៍ដែលបានកែសម្រួលជាថ្មីលើតារាងទិន្នន័យចាស់ដោយបង្កើនមុខទំនិញសរុបដល់ចំនួន ៨០ មុខទំនិញ និងក្រុមមុខទំនិញសំខាន់ៗត្រូវបានបែងចែកជាថ្មីម្តងទៀតមកត្រឹម ៧ ក្រុម ដោយប្រមូលពីសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ១៩។ លើសពីនេះ ក្រុមការងារបានសិក្សា និងកំណត់គ្រាគោលថ្មីមកឆ្នាំ២០២៤ ដោយប្តូរពីគ្រាគោលចាស់ (ឆ្នាំ២០១៨) ចំណែកឯមេគុណ (Weight) ក៏ត្រូវបានគណនាដោយផ្អែកតាមលទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០១៩ ដោយប្តូរពីមេគុណចាស់ (ឆ្នាំ២០១៣) ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពថ្លៃជាក់ស្តែងតាមបណ្តារាជធានី-ខេត្ត។

### ៤. អង្កេតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

អង្កេតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានរៀបចំឡើងក្នុងគោល-បំណងតាមដានពីការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថាន ដើម្បីពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុ និងការគ្រប់គ្រងសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ។

នាឆ្នាំ២០២៥ ការអង្កេតនេះត្រូវបានធ្វើឡើងចំនួន ២ដង ដែលមានគ្រឹះស្ថានចូលរួម លើកទី១ ចំនួន ៤៨ និងលើកទី២ ចំនួន ១៧។

### ៥. អង្កេតស្ថានភាពប្តូរប្រាក់បាតថៃ

ធនាគារជាតិនៃកម្ពុជាបានធ្វើការសិក្សាលើស្ថានភាពប្តូរប្រាក់បាតថៃអំឡុងពេលមានការវិលត្រលប់មកវិញរបស់ពលករពីប្រទេសថៃក្នុងពេលមានជម្លោះព្រំដែនកម្ពុជា-ថៃ។ ទិន្នន័យត្រូវបានប្រមូលពីគ្រឹះស្ថានធនាគារចំនួន ៣ និងអាជីវករទទួលអាជ្ញាបណ្ណប្តូរប្រាក់ និងភ្នាក់ងារប្តូរប្រាក់បាតថៃធំៗចំនួន ៣ នៅតាមបណ្តារាជធានី-ខេត្ត។ ក្រោយពីមានការផ្ទុះអាវុធតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ប្រាក់បាតថៃថយថ្លៃគួរឱ្យកត់សម្គាល់ធៀបនឹងប្រាក់រៀលក៏ដូចជាប្រាក់ដុល្លារអាមេរិក ដោយសារការឆ្លៀតឱកាសកេងចំណេញពីការប្តូរប្រាក់។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីណែនាំឱ្យគ្រឹះស្ថានទាំងអស់ទទួលការដូរប្រាក់បាតថៃ ដោយយកអត្រាទីផ្សារ ដោយធនាគារជាតិនៃកម្ពុជាធានាទិញប្រាក់បាតថៃនេះពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ ក្នុងថ្ងៃវិញក្នុងអត្រាទីផ្សារ។ ការណ៍នេះបានសម្រួលដល់ប្រជាជនខ្មែរដែលត្រឡប់ពីថៃបានយ៉ាងច្រើន និងចៀសវាងការកេងប្រវ័ញ្ចពីឈ្មួញមួយចំនួនដែលបង្អាប់អត្រាប្រាក់បាតថៃ និងធ្វើឱ្យពលករខ្មែរខាតបង់។

### ៦. អង្កេតថ្លៃទំនិញប្រើប្រាស់ក្នុងបរិការណ៍ជម្លោះព្រំដែនកម្ពុជា-ថៃ

នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានធ្វើអង្កេតថ្លៃទំនិញប្រើប្រាស់នៅតាមផ្សារចំនួន៤ ដើម្បីពិនិត្យមើលការប្រែប្រួលថ្លៃបន្ទាប់ពីការផ្ទុះអាវុធកម្ពុជា-ថៃលើកទី១ទើបត្រូវបានបញ្ចប់។ ផ្សារទាំង៤រួមមាន៖ ផ្សារដើមគ ផ្សារអូរឫស្សី ផ្សារធំថ្មី និងផ្សារច្បារអំពៅ។ លទ្ធផលពីការអង្កេតនេះបានបង្ហាញថា ជាទូទៅ ទំនិញនៅលើទីផ្សារមិនមានការឡើងថ្លៃគួរឱ្យកត់សម្គាល់នោះទេ ដែលក្នុងនោះកំណើនថ្លៃបន្លែ ផ្លែឈើ និងត្រីបណ្ដាលមកពីកត្តារដូវកាល។ ដោយឡែក មានតែទំនិញនាំចូលតិចតួចតែប៉ុណ្ណោះបានឡើងថ្លៃដោយសារជម្លោះនេះដែលរួមមាន៖ i/-ផ្លែឈើមួយចំនួនតូច ដូចជា ផ្លែប៉ោម និងផ្លែសារី ដែលធ្លាប់ត្រូវបាននាំចូលពីថៃហើយដែលត្រូវបានជំនួសដោយការបង្កើនការនាំចូលពីចិន ដោយសារថ្លៃដឹកជញ្ជូនកើនឡើង និង ii/-គ្រឿងឧបភោគបរិភោគដូចជា ទឹកដោះគោ គ្រឿងកំប៉ុង គ្រឿងទេស និងត្រីងៀត ដោយសារកំណើនតម្រូវការសម្រាប់ធ្វើជាជំនួយដល់កងទ័ពនិងជនភៀសសឹក។

### ៧. អង្កេតពលករដែលត្រលប់មកពីថៃ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃកម្លាំងពលកម្ម ដែលទាក់ទងនឹងជម្លោះព្រំដែនកម្ពុជា-ថៃ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំធ្វើអង្កេតលើពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃវិញ។ ការអង្កេតនេះបានធ្វើឡើងជាមួយពលករចំនួន ២.៦៥០នាក់ តាមបណ្ដាខេត្តចំនួន ២២ ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ តាមរយៈការសម្ភាសន៍ផ្ទាល់របស់ក្រុមការងារអង្កេតរបស់ធនាគារជាតិនៃកម្ពុជា។ គោលបំណងនៃការអង្កេតនេះគឺដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្ដែងរបស់ពលករ ជាពិសេស ជំនាញបច្ចេកទេស ចំណូល ប្រាក់បង្វែរ និងស្ថានភាពបំណុល ដើម្បីរៀបចំគោលនយោបាយនិងវិធានការឆ្លើយតបឱ្យបានទាន់ពេលវេលា។

### ៨. អង្កេតស្ថានភាពផ្ដល់ឥណទាន

ធនាគារជាតិនៃកម្ពុជាបានបន្តតាមដានស្ថានភាពឥណទាននិងវឌ្ឍនភាពប្រព័ន្ធធនាគារយ៉ាងយកចិត្តទុកដាក់ តាមរយៈការរៀបចំការអង្កេតស្ថានភាពផ្ដល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៧៣ (ធនាគារពាណិជ្ជ ៥៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ១០) កាលពីខែកញ្ញា ឆ្នាំ២០២៥។ លទ្ធផលអង្កេតនេះក៏ត្រូវបានប្រើប្រាស់សម្រាប់ជាធាតុចូលសំខាន់ក្នុងការព្យាករនិងវិភាគពីស្ថានភាពប្រព័ន្ធធនាគារនិងការដាក់ចេញគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។

**លទ្ធផលនៃអង្កេតទាំងនេះត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយនិងវិធានការនានារបស់ធនាគារជាតិនៃកម្ពុជាប៉ុណ្ណោះ ដូច្នេះលទ្ធផលមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ។**

## ៣- ស្ថានភាពជញ្ជីងទូទាត់



ប្រភព៖ ធនាគារជាតិនៃកម្ពុជា,សម្គាល់៖ ប=ប៉ាន់ស្មាន

សមតុល្យជញ្ជីងទូទាត់កម្ពុជាមានអតិរេក ៨៨១,៣ លានដុល្លារអាមេរិក ខ្ពស់ជាងឆ្នាំមុនទ្វេដង (អតិរេក ៤៣២,៨ លានដុល្លារអាមេរិក)។ អតិរេកនេះត្រូវបានគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ បើទោះបីជាគណនីចរន្តនិងដើមទុន បានប្តូរពីអតិរេកមកឱនភាពក្តី។ អតិរេកជញ្ជីងទូទាត់បានគាំទ្រដល់ការគរពូនទុនបម្រុងអន្តរជាតិនិងតម្លៃរបស់ប្រាក់រៀល។

### ក- គណនីចរន្តនិងដើមទុន



ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

សមតុល្យគណនីចរន្តនិងដើមទុនមានឱនភាព ១,៣ ប៊ីលានដុល្លារអាមេរិក (២,៧% នៃផ.ស.ស.) ធៀបនឹងអតិរេក ៣៥៣,៧ លានដុល្លារអាមេរិក (០,៨% នៃផ.ស.ស.) គ្រាដូចគ្នាឆ្នាំមុន។ ការប្តូរពីអតិរេកទៅជាឱនភាពនេះ ជាចម្បងបណ្តាលមកពីការថយចុះអតិរេកចំណូលបន្ទាប់បន្សំ គួបផ្សំនឹងការកើនឡើងឱនភាពចំណូលបឋមនិងពាណិជ្ជកម្មទំនិញ ខណៈដែលអតិរេកគណនីសេវាកើនឡើង។

សមតុល្យពាណិជ្ជកម្មទំនិញមានឱនភាព ៤,៩ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៨,៦% ដោយសារការកើនឡើងគួរឱ្យកត់សម្គាល់នៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ យានយន្ត និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ។ ការនាំចេញមានទំហំ ៣១,៣ ប៊ីលានដុល្លារអាមេរិក (កើន ១៧,១%) ដែលក្នុងនោះការនាំចេញផលិតផលកាត់ដេរ[១៥] កើន ១៨,៤% ផលិតផលកសិកម្ម ៧,៤%[១៦] និងផលិតផលផ្សេងៗ ២០,៤% (សំបកកង់រថយន្តកើន ៥៧,៦% និងទោចក្រយានកើន ៤៧,៩% ខណៈគ្រឿងអេឡិចត្រូនិកមិនរាប់បញ្ចូលផ្ទាំងសូឡាថយ -៤,៣%)។ សហរដ្ឋអាមេរិកនៅតែជាទីផ្សារនាំចេញលំដាប់ទី១របស់កម្ពុជា ដែលមានសមាមាត្រ ៤០% នៃការនាំចេញសរុប បន្ទាប់មកសហភាពអឺរ៉ុប ១៦% វៀតណាម ១២% ចិន[១៧] ៦% និងជប៉ុន ៥% ។

[១៥] ក្នុងនោះ ការនាំចេញសម្លៀកបំពាក់កើន ១៩,៦% ស្បែកជើងកើន ២០,២% និងសម្ភារសម្រាប់ធ្វើដំណើរនិងផលិតផលវាយនភ័ណ្ឌផ្សេងទៀតកើន ១២%។

[១៦] ក្នុងនោះ អង្ករកើន ១៥,៦% និងផលិតផលកសិកម្មផ្សេងៗកើន ៩,១% ខណៈដែលកៅស៊ូថយចុះ -៩,៧%។

[១៧] រាប់បញ្ចូលទាំង ហុងកុង តៃវ៉ាន់ និងម៉ាកាវ។

**ពាណិជ្ជកម្មទំនិញរបស់ប្រទេសកម្ពុជា**

(ឆ្នាំ២០២៥ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ការនាំចូលមានទំហំ ៣៦,២ ប៊ីលានដុល្លារអាមេរិក (កើន ១៥,៩%) ដែលក្នុងនោះ ការនាំចូលយានយន្តកើន ៤៨,៣% សម្ភារនិងបរិក្ខារសំណង់កើន ៣៩,២% ម្ហូបអាហារនិងភេសជ្ជៈកើន ១៣,៤% និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរកើន ៥,៧%។ កម្ពុជានាំចូលទំនិញច្រើនជាងគេពីប្រទេសចិន ដែលមានសមាមាត្រ ៥៦% នៃការនាំចូលសរុប បន្ទាប់មកវៀតណាម ១២% ថៃ ៩% និងសិង្ហបុរី ៣%។

**ក្រាហ្វ ២២៖ ការនាំចេញទំនិញ**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ២៣៖ ការនាំចូលទំនិញ**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ២៤៖ សមាមាត្រការនាំចូលទំនិញ បែងចែកតាមប្រទេស**

(ឆ្នាំ២០២៥ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

**ក្រាហ្វ ២៥៖ សមាមាត្រការនាំចេញទំនិញ បែងចែកតាមប្រទេស**

(ឆ្នាំ២០២៥ប)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប = ប៉ាន់ស្មាន

គណនីសេវាមានអតិរេក ២ ប៊ីលានដុល្លារអាមេរិក (កើន ៧%) ដែលក្នុងនោះចំណូលពីសេវាធ្វើដំណើរកើន ៣% ខណៈដែលការចំណាយលើសេវាធ្វើដំណើរថយចុះ -១៦,៩%។ ទន្ទឹមនេះ គណនីចំណូលបន្ទាប់បន្សំមានអតិរេក ២,៣ ប៊ីលានដុល្លារអាមេរិក ដោយបានថយចុះ -២៧,៦% ដែលជាចម្បងបណ្តាលមកពីការថយចុះប្រាក់បង្វែរឯកជនពីក្រៅប្រទេស[១៨] -២៩,៧% ស្របពេលដែលជំនួយរបស់រាជរដ្ឋាភិបាលថយចុះ -១៤,៥%។ ចំណែក គណនីចំណូលបឋមមានឱនភាព ៨០២,៩ លានដុល្លារអាមេរិក ដែលបានកើនឡើង ១,២ ដង ដោយសារការទូទាត់ផ្នែកឥណពន្ធ[១៩]កើន ៤២,៩% ស្របពេលដែលការទូទាត់ផ្នែកឥណទានថយចុះ -៤,៨%។

## ខ- គណនីហិរញ្ញវត្ថុ

សមតុល្យគណនីហិរញ្ញវត្ថុបង្ហាញលំហូរចូលសុទ្ធ ២,២ ប៊ីលានដុល្លារអាមេរិក ធៀបនឹងឆ្នាំមុន (៧៩,១ លានដុល្លារអាមេរិក)។ ការកើនឡើងលំហូរចូលសុទ្ធនេះជាចម្បងបណ្តាលមកពីការកើនឡើងលំហូរចូលសុទ្ធនៃវិនិយោគផ្ទាល់ ខណៈដែលលំហូរចេញសុទ្ធផ្នែកវិនិយោគផ្សេងទៀតបានកើនឡើង។

**ក្រាហ្វ ២៦៖ គណនីហិរញ្ញវត្ថុ**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន

[១៨] ក្នុងនោះ ប្រាក់បង្វែរពលករទេសន្តរប្រវេសន៍ពីក្រៅប្រទេសថយចុះ -២៨% (ពីប្រទេសថៃថយចុះ -១ដង ម៉ាឡេស៊ី -០,១% និងកូរ៉េ -២,៧% ខណៈដែលប្រទេសជប៉ុនកើន ១២,៥%) និងប្រាក់បង្វែរចូលពីក្រៅប្រទេសផ្សេងទៀតថយចុះ -១៦,៩%។

[១៩] ក្នុងនោះ ការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់កើន ៦៩,៥% និងចំណាយការប្រាក់របស់រាជរដ្ឋាភិបាលកើន ១១,២%។

លំហូរចូលវិនិយោគផ្ទាល់បរទេសមាន ៥,២ ប៊ីលានដុល្លារអាមេរិក (កើន ១៨,២%) ដែលគាំទ្រដោយកំណើនការវិនិយោគក្នុងវិស័យមិនមែនហិរញ្ញវត្ថុ ២៤% ក្នុងនោះវិស័យកម្មន្តសាល[២០] កើន ៥០% ខណៈដែលវិស័យសណ្ឋាគារ និងការកម្សាន្តថយ -២៨,៨% វិស័យសំណង់ -៧,៧% វិស័យអចលនទ្រព្យ -២៣,២% ថាមពល -១៥,២% កសិកម្ម -៤,៧% និងវិស័យផ្សេងទៀត -២៩,៥%។ ដោយឡែកការវិនិយោគផ្ទាល់បរទេសក្នុងវិស័យហិរញ្ញវត្ថុក៏បានថយចុះ -១២,៨%។

**ក្រាហ្វ ២៧៖ ការរួមចំណែកក្នុងកំណើនវិនិយោគផ្ទាល់បរទេស**

(គិតជាភាគរយ, ឆ្នាំ២០១៩ - ឆ្នាំ២០២៥ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន

ប្រទេសចិន[២១] នៅតែបន្តនាំមុខក្នុងការវិនិយោគនៅកម្ពុជា (៧៣% នៃលំហូរវិនិយោគសរុប) បន្ទាប់មកសិង្ហបុរី (៧%) កូរ៉េខាងត្បូង (៤%) កាណាដា (៤%) ម៉ាឡេស៊ី (៣%) និងផ្សេងៗ (៩%)។

លំហូរចេញសុទ្ធនៃវិនិយោគផ្សេងទៀតបង្ហាញពីការកើនទ្រព្យសកម្មបរទេសសុទ្ធ ២,៩ ប៊ីលានដុល្លារអាមេរិក (កើន ៦,៩%) ដែលជាចម្បងបណ្ដាលមកពីការកើនឡើងប្រាក់បញ្ញើនៃវិស័យហិរញ្ញវត្ថុ ខណៈដែលកម្ចីសុទ្ធរបស់រាជរដ្ឋាភិបាលកើនឡើង ៣,៦%។

**ក្រាហ្វ ២៨៖ សមាមាត្រលំហូរចូលវិនិយោគផ្ទាល់បែងចែកតាមប្រទេស**

(គិតជាភាគរយ, ឆ្នាំ២០២៥ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន

**សូមស្វែងរកបច្ចុប្បន្នភាពទិន្នន័យស្ថិតិជញ្ជីងទូទាត់កម្ពុជាតាមរយៈយូអរកូដខាងក្រោម៖**

ព្រឹត្តិបត្រស្ថិតិជញ្ជីងទូទាត់

ទិន្នន័យស្ថិតិជញ្ជីងទូទាត់កម្ពុជា

[២០] វិស័យកាត់ដេរសម្លៀកបំពាក់កើន ៧,៥% ស្បែកជើង ១៨,៩% គេសជ្ជៈ ៧១,៣% វេចខ្ចប់ ១៩,៣% ផលិតផលធ្វើដំណើរ ១,៨% និងផ្សេងៗ ១ដង ខណៈដែលផលិតផលផ្ទាំងសូឡា -៧១,៦% កែច្នៃឈើ -០,១% និង ផលិតផលចំណីអាហារ -៧,៣%។

[២១] រាប់បញ្ចូលទាំង ហុងកុង តៃវ៉ាន់ និងម៉ាការ។

## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិបន្តរក្សាបាននៅកម្រិតខ្ពស់ដែលឆ្លុះបញ្ចាំងពីភាពរឹងមាំនៃលទ្ធភាពសងបំណុលក្រៅប្រទេស ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងប្រព័ន្ធទូទាត់ជាតិ ព្រមទាំងផ្តល់ការការពារគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការសន្ទនីយភាពទប់ទល់នឹងវិបត្តិខាងក្រៅ។ ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២៧,៥ ប៊ីលានដុល្លារអាមេរិក ក្នុងអត្រា ២២,៣% ធៀបនឹងឆ្នាំ២០២៤ (២២,៥ ប៊ីលានដុល្លារអាមេរិក) ឬស្មើនឹង ៨ ខែ នៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់ ដែលជាកម្រិតខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីការកើនឡើង៖ i/-តម្លៃមាស ii/-ចំណូលពីការវិនិយោគក្រៅប្រទេស iii/-ការប្រែប្រួលអត្រាប្តូរប្រាក់ និង iv/-ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាល និងប្រាក់បម្រុងកាតព្វកិច្ច។




ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ត្រូវបានអនុវត្តដោយការប្រុងប្រយ័ត្ននិងប្រកបដោយវិជ្ជាជីវៈ ដោយរចនាសម្ព័ន្ធគ្រប់គ្រងទុនបម្រុងអន្តរជាតិ ត្រូវបានរៀបចំឡើងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រុងប្រយ័ត្នខ្ពស់។ ការកំណត់ទិសដៅយុទ្ធសាស្ត្រ និងកម្រិតហានិភ័យទទួលយកបាន ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាល តាមរយៈការអនុម័តលើគោលនយោបាយវិនិយោគជាប្រចាំឆ្នាំឬតាមការចាំបាច់។ រីឯការតាមដានជាប្រចាំខែគឺត្រូវអនុវត្តដោយគណៈកម្មការវិនិយោគទុនបម្រុង ដែលមានទេសាភិបាលជាប្រធានគណៈកម្មការ ដើម្បីពិនិត្យលទ្ធផលនៃការវិនិយោគ វិភាគលក្ខខណ្ឌទីផ្សារ និងផ្តល់អនុសាសន៍កែសម្រួលចាំបាច់ដើម្បីធានាថាយុទ្ធសាស្ត្រគ្រប់គ្រងទុនបម្រុងត្រូវបានផ្តោតលើសុវត្ថិភាព សន្ទនីយភាព និងទទួលបានចំណូលសមស្រប។ នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មលើ៖ i/-សេចក្តីណែនាំការវិនិយោគ ii/-សេចក្តីណែនាំលើការងារជ្រើសរើសនិងគ្រប់គ្រងអ្នកចាត់ការខាងក្រៅនិងភ្នាក់ងាររក្សាមូលបត្រ iii/-បទបញ្ជាផ្ទៃក្នុងស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីបុគ្គលិកនាយកដ្ឋានគ្រប់គ្រងទុនបម្រុង" iv/-ប្រព័ន្ធគ្រប់គ្រងទុនបម្រុង និង v/-ការធ្វើពិពិធកម្មភ្នាក់ងាររក្សាមូលបត្របន្ថែម សំដៅក្នុងការធានាសុវត្ថិភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងទុនបម្រុងអន្តរជាតិ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការវិនិយោគលើសញ្ញាប័ណ្ណបៃតង (Green bonds) និងសញ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងតំបន់អឺរ៉ុបក្នុងគោលដៅចូលរួមចំណែកលើកកម្ពស់ការអនុវត្តតាមគោលនយោបាយវិនិយោគប្រកបដោយការទទួលខុសត្រូវទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ច រក្សាបានចីរភាព សុវត្ថិភាព ការវិនិយោគទុនបម្រុង និងស្របតាមនិន្នាការនៃការវិនិយោគសកល។

**ប្រអប់ ២៖ តើទុនបម្រុងអន្តរជាតិជាអ្វី?**

យោងតាមជំពូកទី៧ មាត្រា៣០ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ទុនបម្រុងអន្តរជាតិ ដែលត្រូវរក្សានិងគ្រប់គ្រងដោយធនាគារកណ្តាល គឺជាទ្រព្យសកម្មអន្តរជាតិ រួមមាន៖ មាស រូបិយប័ណ្ណនិងសមតុល្យធនាគារនៅបរទេស SDRs (Special Drawing Rights) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ទុនបម្រុងដែលរក្សាទុកនៅមូលនិធិរូបិយវត្ថុអន្តរជាតិ និងបណ្ណរតនាគារឬមូលបត្រដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា។ គោលបំណងចម្បងនៃការរក្សាទុនបម្រុងអន្តរជាតិ គឺដើម្បីរក្សាទំនុកចិត្តសាធារណជនលើគោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ ធានាលទ្ធភាពទូទាត់កាតព្វកិច្ចក្រៅប្រទេស ដែលរួមមានការនាំចូលទំនិញចាំបាច់ជាដើម និងរក្សាស្ថិរភាពសេដ្ឋកិច្ចនៅពេលមានវិបត្តិក្នុងស្រុក ឬការប៉ះទង្គិចពីខាងក្រៅ។

ជាទូទៅ ទុនបម្រុងអន្តរជាតិមិនត្រូវបានវិនិយោគក្នុងស្រុកឬជារូបិយវត្ថុជាតិ ដោយសារទុនបម្រុងអន្តរជាតិត្រូវបានរក្សាទុកដើម្បីធានាស្ថិរភាពសេដ្ឋកិច្ចនៅពេលប្រទេសប្រឈមនឹងការប៉ះទង្គិច ដែលតម្រូវឱ្យមានរូបិយប័ណ្ណបរទេសភ្លាមៗដើម្បីធ្វើអន្តរាគមន៍ទ្រទ្រង់រូបិយវត្ថុជាតិ និងទូទាត់ការនាំចូល។ ការវិនិយោគទុនបម្រុងនៅក្នុងប្រទេស អាចធ្វើឱ្យប្រឈមនឹងហានិភ័យនៃការខាតបង់នៅពេលដែលកម្ពុជាមានវិបត្តិសេដ្ឋកិច្ច ដូច្នេះកាត់បន្ថយលទ្ធភាពរបស់ទុនបម្រុងក្នុងការដើរតួនាទីបំពេញសន្ទនីយភាពដើម្បីស្តារសេដ្ឋកិច្ចឡើងវិញ។ ដូច្នេះ ទុនបម្រុងអន្តរជាតិត្រូវធ្វើការវិនិយោគនៅក្រៅប្រទេស ទៅលើឧបករណ៍ដែលមានសុវត្ថិភាព និងសន្ទនីយភាពខ្ពស់ ដើម្បីធានាថាទុនបម្រុងអន្តរជាតិនេះអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញនៅពេលសេដ្ឋកិច្ចកម្ពុជាមានវិបត្តិ។

## ៥- ស្ថានភាពអតិផរណា

អត្រាអតិផរណារួមនាឆ្នាំ២០២៥ បានកើនឡើងដល់ ២,៥% បន្ទាប់ពីបានថយចុះមកកម្រិតទាបបំផុតនាឆ្នាំ២០២៤ ក្នុងអត្រា ០,៨%ក្នុងរយៈពេលជាង ១ ទសវត្សរ៍ចុងក្រោយនេះ។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីមូលដ្ឋានគណនាទាប និងការកើនឡើងនៃថ្លៃក្រុមម្ហូបអាហារ កាលពីដើមឆ្នាំ២០២៥ ខណៈដែលការបន្ធូរថ្លៃប្រេងនៅពិភពលោកបានជួយបន្ថយសម្ពាធអតិផរណា។ គួរកត់សម្គាល់ផងដែរថា ជម្លោះព្រំដែនកម្ពុជា-ថៃ ដែលនាំឱ្យមានការបិទព្រំដែនបានរាំងស្ទះដល់ការនាំចូលទំនិញពីប្រទេសថៃតាមផ្លូវគោក និងការហាមឃាត់ការនាំចូលទំនិញមួយចំនួនពីថៃ បាននាំឱ្យថ្លៃទំនិញមួយចំនួនតូចកើនបន្តិចនិងក្នុងរយៈពេលខ្លីប៉ុណ្ណោះ ជាពិសេសនៅក្នុងតំបន់ព្រំដែនខ្មែរ-ថៃ។ ទំនិញទាំងនោះត្រូវបានជំនួសយ៉ាងឆាប់រហ័សដោយទំនិញក្នុងស្រុកនិងទំនិញនាំចូលពីប្រទេសផ្សេង។



**អតិផរណា**
▲ ២,៥%
*(០,៨% ក្នុងឆ្នាំ២០២៤)*

**ក្រាហ្វ ២៩៖ ការរួមចំណែកក្នុងអតិផរណារួម**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣០៖ អតិផរណារួម និងអតិផរណាក្រុមទាំងបី**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣១៖ អតិផរណាក្រុមម្ហូបអាហារ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

អតិផរណាក្រុមម្ហូបអាហារជាមធ្យមបានកើនឡើង ៣,៧%(ធៀបនឹង ១,២% នាឆ្នាំ២០២៤) ជាចម្បងបណ្ដាលមកពីការកើនឡើងថ្លៃបន្លែ ៥,៦% (៤,៥% នាឆ្នាំ២០២៤) ផ្លែឈើ ៥,២% (២,៣% នាឆ្នាំ២០២៤) ត្រីស្រស់ ៣,៦% (-០,១% នាឆ្នាំ២០២៤) សាច់គោ ៣,៥% (០,៥% នាឆ្នាំ២០២៤) និងសាច់ជ្រូក ២,៧% (០,១% នាឆ្នាំ២០២៤)។ ការឡើងថ្លៃបន្លែនិងផ្លែឈើជាពិសេសនៅដើមឆ្នាំ២០២៥ បណ្ដាលមកពីមូលដ្ឋានគណនាទាប និងតម្រូវការខ្ពស់ក្នុងអំឡុងពេលចូលឆ្នាំប្រពៃណីចិន។ ទន្ទឹមនេះ ការបង្ក្រាបបទល្មើសជលផលទ្រង់ទ្រាយធំ ការថយចុះការចិញ្ចឹមគោ និងកំណើនតម្រូវការក្នុងរដូវបុណ្យទានបានធ្វើឱ្យថ្លៃត្រី សាច់គោ និងសាច់ជ្រូកកើនឡើងផងដែរ។

ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបន្តថយចុះ -១,៧% (ធៀបនឹង -២,១% នាឆ្នាំ២០២៤) ស្របតាមការថយចុះនៃថ្លៃប្រេងនៅពិភពលោក។ នៅកម្ពុជា ថ្លៃសាំងបានបន្តធ្លាក់ចុះ -៧,៦% (-៦,៣% នាឆ្នាំ២០២៤) ហើយថ្លៃឧស្ម័នថយ -០,៤% (-០,៩% នាឆ្នាំ២០២៤) ចំណែកឯថ្លៃឥន្ធនៈរឹងបានកើនបន្តិច ១,៩% (-០,៩% នាឆ្នាំ២០២៤)។ គួរបញ្ជាក់ថា ការនាំចូលប្រេងឥន្ធនៈពីប្រទេសថៃត្រូវបានជំនួសភាគច្រើនដោយការនាំចូលពីប្រទេសសិង្ហបុរីនិងម៉ាឡេស៊ី (ប្រអប់៣)។

**ក្រាហ្វ ៣២៖ អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៣៖ អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងកំណើនថ្លៃប្រេងនៅអន្តរជាតិ**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ រដ្ឋបាលព័ត៌មានអំពីថាមពលរបស់សហរដ្ឋអាមេរិក (EIA) វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

អតិផរណាស្នូលបានកើនឡើងដល់ ១,៩% (១% នាឆ្នាំ២០២៤) ដោយសារកំណើនថ្លៃនៃការថែរក្សានិងការជួសជុលជម្រកស្នាក់នៅ ៥,៩% (១,៨% នាឆ្នាំ២០២៤) សម្លៀកបំពាក់ ៥,១% (២,៧% នាឆ្នាំ២០២៤) និងភោជនីយដ្ឋាន ១,២% (០,៣% នាឆ្នាំ២០២៤) ខណៈដែលការទិញយានជំនិះបានថយថ្លៃ -១,០% (១,៤% នាឆ្នាំ២០២៤)។ ការកើនឡើងនៃអតិផរណាស្នូលនេះបណ្តាលមកពីកម្រិតថ្លៃមូលដ្ឋានទាបកាលពីឆ្នាំមុន ការឡើងថ្លៃសម្ភារៈសំណង់នាំចូល កំណើនភ្ញៀវអន្តរជាតិតាមផ្លូវអាកាសនិងទេសចរក្នុងស្រុក និងឥទ្ធិពលពីការឡើងថ្លៃម្ហូបអាហារទៅលើមុខទំនិញរបស់អតិផរណាស្នូល ជាពិសេសក្រុមភោជនីយដ្ឋាន បើទោះជាកំណើនឥណទាននៅមានភាពទន់ខ្សោយនៅឡើយ។

**ក្រាហ្វ ៣៤៖ អតិផរណាស្នូល**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៥៖ អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាភោជនីយដ្ឋាន**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ប្រអប់ ៣៖ ការជំនួសនៃប្រភពទំនិញនាំចូលពីថៃ

ក្រោយការប្រកាសបិទការនាំចូលបន្លែនិងផ្លែឈើពីថៃនាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥ បរិមាណនាំចូលម្ហូបអាហារពីថៃបានធ្លាក់ចុះ -១៨,៩% នាខែមិថុនា ធៀបនឹងចុងឆ្នាំ២០២៤ ហើយការនាំចូលម្ហូបអាហារសរុបបានធ្លាក់ចុះ -១៤,៣%។ នាអំឡុងខែកក្កដា-វិច្ឆិកា ការនាំចូលម្ហូបអាហារបានកើនបន្តិច ០,៧% ធៀបនឹងចុងឆ្នាំ២០២៤ ដែលបណ្ដាលមកពីកំណើនការនាំចូលពីវៀតណាមនិងចិន ខណៈដែលការនាំចូលពីថៃនៅតែបន្តធ្លាក់ចុះ (ក្រាហ្វ៣៦)។ ការណ៍នេះបង្ហាញថាការនាំចូលពីថៃត្រូវបានជំនួសភាគច្រើនដោយការនាំចូលពីវៀតណាមនិងចិន។ បន្លែនិងផ្លែឈើ ដែលជាទំនិញរងបម្រាមនាំចូលពីថៃ ត្រូវបានជំនួសភាគច្រើនដោយការនាំចូលពីវៀតណាម (ក្រាហ្វ៣៨)។ លើសពីនេះ ការនាំចូលទំនិញម្ហូបអាហារដែលមិនរងបម្រាមនាំចូលផ្សេងទៀតក៏ត្រូវបានជំនួសផងដែរដូចជា៖ ប៊ីចេង ប្រេងឆា គ្រឿងឧបភោគបរិភោគ ទឹកបរិសុទ្ធ និងអង្ករ។ ដោយឡែក ការនាំចូលភេសជ្ជៈបានធ្លាក់ចុះដោយមិនមានការនាំចូលជំនួស ខណៈការនាំចូលស្ករសពីថៃបានងើបបន្តិចមកវិញ បន្ទាប់ពីបានធ្លាក់ចុះនាខែមិថុនា។ ក្រៅពីនេះ ការបិទការនាំចូលប្រេងនិងឧស្ម័នឥន្ធនៈពីថៃ ដែលត្រូវបានអនុវត្តនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ មិនបង្កផលប៉ះពាល់ទៅលើការផ្គត់ផ្គង់នោះទេ ដោយសារកម្ពុជាបានបង្វែរការនាំចូលពីប្រទេសផ្សេង ជាពិសេសសិង្ហបុរី និងម៉ាឡេស៊ី (ក្រាហ្វ៣៧)។

**ក្រាហ្វ ៣៦៖ ការរួមចំណែកក្នុងកំណើនការនាំចូលម្ហូបអាហារសរុប**

(គិតជាភាគរយ, ផ្អែកលើបរិមាណ, ធៀបនឹងខែធ្នូ ឆ្នាំ២០២៤*)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ៣៧៖ បរិមាណនាំចូលប្រេងសាំងធម្មតានិងម៉ាស៊ូត**

(គិតជាពាន់តោន, ខែមករា ឆ្នាំ២០២៤ - ខែវិច្ឆិកា ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៨៖ ការរួមចំណែកក្នុងកំណើនការនាំចូលតាមមុខទំនិញម្ហូបអាហារ**

(គិតជាភាគរយ, ផ្អែកលើបរិមាណ, ធៀបនឹងខែធ្នូ ឆ្នាំ២០២៤)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ខែមករា-ឧសភា ឆ្នាំ២០២៥ សំដៅអំឡុងពេលមុនជម្លោះព្រំដែនកម្ពុជា-ថៃនាខែមិថុនា ជាពិសេសមុនការបិទការនាំចូលបន្លែនិងផ្លែឈើពីថៃដែលត្រូវបានអនុវត្តនៅខែមិថុនា ឆ្នាំ២០២៥។ ខែកក្កដា-វិច្ឆិកា ឆ្នាំ២០២៥ សំដៅអំឡុងក្រោយការបិទការនាំចូលនេះ។ កត្តារដូវកាលត្រូវបានញែកចេញពីទិន្នន័យមុននឹងយកទៅគណនាជាកំណើនធៀបនឹងខែធ្នូ ឆ្នាំ២០២៤។

*នាខែធ្នូ ឆ្នាំ២០២៤ បរិមាណនាំចូលម្ហូបអាហារសរុបមានសមាមាត្រ ៤២% ពីថៃ ១៥% ពីវៀតណាម ៨,៦% ពីចិន និង ៣៤,៥% ពីប្រទេសផ្សេងទៀត។

## ៦- ស្ថានភាពអត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនាឆ្នាំ២០២៥ រក្សាបានស្ថិរភាពល្អប្រសើរប្រហាក់ប្រហែលនឹងបណ្តាឆ្នាំកន្លងទៅ និងបានឡើងថ្លៃផង ដោយមានអត្រាមធ្យម ៤.០១១ រៀលក្នុងមួយដុល្លារអាមេរិក។ លើសពីនេះ ប្រាក់រៀលបានឡើងថ្លៃជាមធ្យម ១,៥% ធៀបនឹងឆ្នាំ២០២៤ (៤.០៧១ រៀលក្នុងមួយដុល្លារអាមេរិក) ឡើងថ្លៃ ២,២% ធៀបនឹងអំឡុងពេលនិងក្រោយមានវិបត្តិកូវីដ-១៩ ឆ្នាំ២០២០-២០២៣ (៤.១០១ រៀលក្នុងមួយដុល្លារអាមេរិក) និងឡើងថ្លៃ ១,១% ធៀបនឹងអំឡុងពេលមុនវិបត្តិកូវីដ-១៩ ឆ្នាំ២០១៦-២០១៩ (៤.០៥៦ រៀលក្នុងមួយដុល្លារអាមេរិក)។ ការឡើងថ្លៃប្រាក់រៀលត្រូវបានគាំទ្រជាចម្បងដោយកំណើនតម្រូវការប្រាក់រៀលនៅក្នុងជីវភាពរស់នៅ ការកើនឡើងផលិតកម្មកសិកម្ម និងកំណើននៃការទូទាត់ជាប្រាក់រៀលតាមប្រព័ន្ធអេឡិចត្រូនិក។ ដោយឡែកក្នុងស្ថានភាពនៃការវិលត្រឡប់មកវិញរបស់ពលករទេសន្តរប្រវេសន៍នាអំឡុងពេលជម្លោះព្រំដែនកម្ពុជា-ថៃ ធនាគារជាតិនៃកម្ពុជាបានរក្សាអត្រាប្តូររវាងប្រាក់បាតថៃនិងរៀលស្របតាមអត្រាទីផ្សារ ដើម្បីរួមចំណែកការពារអត្ថប្រយោជន៍របស់ពលករដែលប្តូរប្រាក់ពីបាតថៃមកជារៀល។ គួររំលេចថា ការកើនឡើងនៃបរិមាណប្រាក់បាតថៃនៅលើទីផ្សារបានធ្វើឱ្យអាជីវករប្តូរប្រាក់មួយចំនួន ពិសេសនៅតាមព្រំដែន ឆ្លៀតឱកាសទិញប្រាក់បាតថៃនៅតម្លៃថោកជាងអត្រាទីផ្សារ ដែលធ្វើឱ្យប៉ះពាល់ដល់អត្ថប្រយោជន៍របស់ពលករ។ ឆ្លើយតបទៅនឹងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានណែនាំដល់គ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ឱ្យប្រើប្រាស់អត្រាទីផ្សារសម្រាប់ការប្តូរប្រាក់បាតថៃទៅគ្រប់រូបិយប័ណ្ណ។

**អត្រាប្តូរប្រាក់**




▲ ៤.០១១ រៀល/ដុល្លារអាមេរិក

*(៤.០៧១ រៀល/ដុល្លារអាមេរិក នាឆ្នាំ២០២៤)*

### ក្រាហ្វ ៣៩៖ ស្ថានភាពអត្រាប្ដូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក

(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ៤ ៖ អត្រាប្ដូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា

អត្រាប្ដូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានគណនាចេញពីអត្រាប្ដូរប្រាក់មធ្យមថ្លឹងរបស់ប្រតិបត្តិការប្ដូរប្រាក់អន្តរធនាគារលើថ្នាលធនាគារជាតិនៃកម្ពុជា (NBCP)។ នាឆ្នាំ២០២៥ ប្រតិបត្តិការប្ដូរប្រាក់លើ NBCP មានទំហំ ៣,៩ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៤៦,២% ធៀបនឹងឆ្នាំមុន (២,៧ ប៊ីលានដុល្លារអាមេរិក)។ កំណើននេះបង្ហាញថា៖ i/- អត្រាប្ដូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាកាន់តែឆ្លុះបញ្ចាំងពីអត្រាប្ដូរប្រាក់លើទីផ្សារ ii/- NBCP បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទីផ្សារប្ដូរប្រាក់ និង iii/- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែមានឥទ្ធិពលក្នុងការកំណត់អត្រាលើទីផ្សារប្ដូរប្រាក់ធៀបនឹងអាជីវករប្ដូរប្រាក់។

### ក្រាហ្វ ៤០៖ ប្រតិបត្តិការជួញដូរប្រាក់ដុល្លារអាមេរិកលើ NBCP និងគម្លាតអត្រាប្ដូរប្រាក់ផ្លូវការ-ទីផ្សារ

(ឆ្នាំ២០១៨ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជារួម កំណើនសេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២៥ ត្រូវបានប៉ាន់ស្មានថា សម្រេចបានក្នុងអត្រា ៥% ដែលគាំទ្រជាចម្បងដោយកំណើននៃការនាំចេញផលិតផលកម្មន្តសាល។ កំណើននេះមាន កម្រិតទាបជាងឆ្នាំមុន ដោយសារផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ និងភាពមិនច្បាស់លាស់ នៃស្ថានភាពសេដ្ឋកិច្ចពិភពលោក។ អតិផរណាបានងើបឡើងវិញពីមូលដ្ឋានថ្លៃទាប និងការកើនឡើង ថ្លៃនៃក្រុមម្ហូបអាហារ ប៉ុន្តែបន្តស្ថិតនៅក្នុងកម្រិតទាប ក្នុងពេលដែលអត្រាប្តូរប្រាក់បន្តមានស្ថិរភាព ល្អប្រសើរ។ កំណើននៃការនាំចេញ គួបផ្សំនឹងកំណើនរឹងមាំនៃវិនិយោគផ្ទាល់បរទេសបានគាំទ្រ ឱ្យមានការកើនឡើងនៃអតិរេកជញ្ជីងទូទាត់ ដែលបានជួយដល់ការគរពូនទុនបម្រុងអន្តរជាតិឱ្យ ស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ ក្នុងការរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន និង សាធារណជនមកលើភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា។

## II- ស្ថានភាពរូបិយវត្ថុ

### ១-ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បានកើនឡើង ១៥% (ឆ្នាំលើឆ្នាំ) ទាបជាងកំណើនឆ្នាំមុន (១៧,៥%) តែខ្ពស់ជាងកំណើនមធ្យមរយៈពេល ៥ ឆ្នាំចុងក្រោយ (១៤%)។ ការថយល្បឿននេះ បណ្តាលមកពីប្រាក់បញ្ញើជារូបិយប័ណ្ណបានថមថយកំណើនមកត្រឹម ១៤,៩% (ទាបជាងឆ្នាំមុន ១៩,៩%) ប្រាក់បញ្ញើជារៀលកើនដល់ ១៤,៧% (ខ្ពស់ជាងឆ្នាំមុន ១២,៥%) ខណៈរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើកើនដល់ ១៧,៣% (-២,៨% នាឆ្នាំ២០២៤)។

សេដ្ឋកិច្ចកម្ពុជាបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅស្មើនឹង ៨៥% ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុប ៩០,៩% និងឥណទានជារូបិយប័ណ្ណធៀបនឹងឥណទានសរុប ៨៨,១%។

**ក្រាហ្វ ៤១៖ ការរួមចំណែកក្នុងកំណើនរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៤២៖ កំណើនសមាសធាតុរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ឆ្នាំ២០១៦ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

### ២- ករីដ័រអត្រាការប្រាក់ និងអត្រាការប្រាក់អន្តរធនាគារ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើទំនើបកម្មក្របខណ្ឌនយោបាយរូបិយវត្ថុ ដោយអភិវឌ្ឍករីដ័រអត្រាការប្រាក់[២២] (Interest Rate Corridor)។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានកំណត់អត្រាការប្រាក់យោងមួយដែលនឹងមានឥទ្ធិពលដល់ការកំណត់អត្រាការប្រាក់នៅលើទីផ្សារ ជាពិសេសក្នុងស្ថានភាពដែលចរាចរណ៍ប្រាក់រៀលកើនឡើងកាន់តែទូលំទូលាយ។

ចាប់តាំងពីការអនុវត្តករីដ័រអត្រាការប្រាក់ អត្រាការប្រាក់យោងដែលជាអត្រាការប្រាក់ LPCO ដែលមានឥណប្រតិទាន ៧ថ្ងៃ បានរួមចំណែកផ្តល់ឱ្យដល់ទីផ្សារនូវកម្រិតអត្រាការប្រាក់មួយដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុយកទៅគិតគូរពីអត្រាការប្រាក់របស់ខ្លួន។ ជាលទ្ធផលគម្លាតនៃកម្រិតអត្រាការប្រាក់ដែលកំណត់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមាននិន្នាការថយចុះដែលរួមចំណែកកាត់បន្ថយថ្លៃដើមមូលនិធិ។ ជាក់ស្តែង អត្រាការប្រាក់អន្តរធនាគារជាប្រាក់រៀល

[២២] ករីដ័រអត្រាការប្រាក់ត្រូវបានអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ២០២៣។

មានកម្រិតជាមធ្យម ៣,០៧% ធៀបនឹង ៣,៥៨% នាឆ្នាំ២០២៤ សម្រាប់ឥណប្រតិទានពី ១-៣០ថ្ងៃ ដែលក្នុងនោះ អត្រាការប្រាក់មធ្យមសម្រាប់ឥណប្រតិទាន ១-១៤ថ្ងៃ មានកម្រិត ២,៩២% ធៀបនឹង ៣,១៨% នាឆ្នាំ២០២៤ ស្របពេលដែលអត្រាការប្រាក់មធ្យមសម្រាប់ឥណប្រតិទាន ១៥-៣០ថ្ងៃ មានកម្រិត ៣,៥៤% ធៀបនឹង ៤,១១% នាឆ្នាំ២០២៤។

**ក្រាហ្វ ៤៣៖ ប្រតិបត្តិការអន្តរធនាគារជារៀល១-៣០ថ្ងៃ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ទំហំនៃចំណុចពណ៌បៃតងនិងលឿងសំដៅដល់ទំហំប្រតិបត្តិការ និងទីតាំងនៃចំណុចពណ៌បៃតងនិងលឿងសំដៅដល់អត្រាការប្រាក់

## ៣- អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងមិនមែនធនាគារ

### ក. អត្រាការប្រាក់គ្រឹះស្ថានធនាគារ

អត្រាការប្រាក់មធ្យមថ្លឹងប្រាក់បញ្ញើនិងឥណទានរបស់គ្រឹះស្ថានធនាគារមាននិន្នាការថយចុះ។ អត្រាការប្រាក់បញ្ញើជារៀលថយចុះពីអត្រាមធ្យម ៥,៧១% នាឆ្នាំ២០២៤ មក ៥,០១% នាឆ្នាំ២០២៥ និងអត្រាការប្រាក់ឥណទានជារៀលថយចុះពី ១២,១៣% មក ១១,២៦%។ ទន្ទឹមនេះ អត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិកបានថយចុះពី ៥,១៨% មក ៤,៩១% ហើយអត្រាការប្រាក់ឥណទានជាដុល្លារអាមេរិកបានថយចុះពី ១០,៣% មក ១០,១៤%។

**ក្រាហ្វ ៤៤៖ អត្រាការប្រាក់មធ្យមថ្លឹងប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣-ខែតុលា ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- អត្រាការប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

អត្រាការប្រាក់មធ្យមថ្លឹងប្រាក់បញ្ញើនិងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏មាននិន្នាការថយចុះផងដែរ។ អត្រាការប្រាក់បញ្ញើជារៀលបានថយចុះពីអត្រាមធ្យម ៦,៤៤% នាឆ្នាំ២០២៤ មក ៥,៤១% នាឆ្នាំ២០២៥ និងអត្រាការប្រាក់ឥណទានជារៀលបានថយចុះពី ១៦,៦៤% មក ១៦,១១%។ ចំណែកឯអត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិកគឺបានថយចុះពី ៦,៥១% មក ៥,៤៨% និងអត្រាការប្រាក់ឥណទានជាដុល្លារអាមេរិកបានថយចុះពី ១៤,២៥% មក ១៣,៤៨% ។

**ក្រាហ្វ ៤៥៖ អត្រាការប្រាក់មធ្យមថ្លឹងប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៣-ខែតុលា ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ៥៖ ទំនាក់ទំនងរវាងអត្រាការប្រាក់គោលរបស់ Fed និងអត្រាការប្រាក់នៅកម្ពុជា**

ដោយសារកម្រិតខ្ពស់នៃដុល្លារូបនីយកម្មនៅកម្ពុជា អត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក (Fed) មានទំនាក់ទំនងជាមួយអត្រាការប្រាក់ជាដុល្លារអាមេរិករបស់គ្រឹះស្ថានធនាគារនៅកម្ពុជា ជាពិសេសជាមួយអត្រាការប្រាក់បញ្ញើ។ ចាប់ពីដើមឆ្នាំ២០២២ អត្រាការប្រាក់គោលរបស់ Fed កើនឡើងពី ០,៥% (ខែមីនា ឆ្នាំ២០២២) ទៅ ៥,៥% (ខែសីហា ឆ្នាំ២០២៣) ស្របពេលដែលអត្រាការប្រាក់បញ្ញើគ្រឹះស្ថានធនាគារនៅកម្ពុជាកើនឡើងពី ៣,៨២% ទៅ ៥,៧១% និងអត្រាការប្រាក់ឥណទានកើនឡើងពី ៩,១៥% ទៅ ៩,៨៨%។ នៅពេលដែលអត្រាការប្រាក់គោលរបស់ Fed ត្រូវបានទម្លាក់ចាប់ពីខែកញ្ញា ឆ្នាំ២០២៤ ពី ៥% មក ៤% នាខែតុលា ឆ្នាំ២០២៥ អត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិករបស់គ្រឹះស្ថានធនាគារនៅកម្ពុជាក៏មាននិន្នាការថយចុះស្របគ្នាផងដែរ ពី ៤,៦០% មក ៤,០៦% ហើយអត្រាការប្រាក់ឥណទានថយចុះពី ១០,០៥% មក ១០%។

**ក្រាហ្វ ៤៦៖ អត្រាការប្រាក់បញ្ញើជាដុល្លារអាមេរិករបស់គ្រឹះស្ថានធនាគារ និងអត្រាការប្រាក់គោលរបស់ Fed**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២១ - ខែតុលា ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា និង Federal Reserve Bank of St. Louis

## ៤- ប្រតិបត្តិការរូបិយវត្ថុ

### ក- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលនិងរូបិយប័ណ្ណត្រូវបានបន្តរក្សាក្នុងកម្រិត ៧%។ កំណើននៃប្រាក់បញ្ញើបានធ្វើឱ្យប្រាក់បម្រុងកាតព្វកិច្ចជារៀលកើនឡើង ១០% ដល់ ១,៨ ទ្រីលានរៀល (៤៦១ លានដុល្លារអាមេរិក) និងជារូបិយប័ណ្ណបានកើនឡើង ៨,៩% ដល់ ៤,៣ ប៊ីលានដុល្លារអាមេរិក (១៧,៤ ទ្រីលានរៀល)។

**ក្រាហ្វ ៤៧៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**

(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៣ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បម្រុងលើស[២៣]ជារៀលមាន ៦,៣ ទ្រីលានរៀល (១,៦ ប៊ីលានដុល្លារអាមេរិក) ដែលស្មើនឹង ៣,៤ដង នៃប្រាក់បម្រុងកាតព្វកិច្ចជារៀល។ ប្រាក់បម្រុងលើសជាដុល្លារអាមេរិកមាន ៥,៥ ប៊ីលានដុល្លារអាមេរិក (២២ ទ្រីលានរៀល) ដែលស្មើនឹង ១,៣ដង នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក។

[២៣] ប្រាក់បម្រុងលើស = សមតុល្យគណនីចរន្ត + សមតុល្យគណនីផាត់ទាត់ + សមតុល្យគណនីបាគង

**ក្រាហ្វ ៤៨៖ ប្រាក់បម្រុងលើសជារៀល និងដុល្លារអាមេរិក**
(គិតជាទ្រីលានរៀល, ខែមករា ឆ្នាំ២០២៤ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៩៖ អនុបាតប្រាក់បម្រុងលើសធៀបនឹងប្រាក់បម្រុងភាតព្វកិច្ចជារៀល និងដុល្លារអាមេរិក**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២៤ - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- ប្រតិបត្តិការស្រូបសន្ទនីយភាព

តាមរយៈការចេញផ្សាយ NCD ជារៀល[២៤] ធនាគារជាតិនៃកម្ពុជាបានស្រូបយកប្រាក់រៀលសរុប ៤៩,៤ ទ្រីលានរៀល (ប្រមាណ ១២ ប៊ីលានដុល្លារអាមេរិក) ដែលបានកើនឡើង ៨៤,៤% ធៀបនឹងឆ្នាំមុន ដែលក្នុងនោះ NCD ជាប្រាក់រៀលដែលមានឥណប្រតិទាន៧ថ្ងៃ មាន ៤៨,១ ទ្រីលានរៀល ៩១ថ្ងៃ មាន ១,១ ទ្រីលានរៀល និង ១៨២ថ្ងៃ មាន ១៦៩ ប៊ីលានរៀល។ NCD ជារៀលដែលមិនទាន់ដល់ឥណប្រតិទានមានចំនួន ១,៥ ទ្រីលានរៀល។ គួររំលេចថា ការដេញថ្លៃ NCD មាននិន្នាការថយចុះក្នុងឆមាសទី១ ដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការប្រាក់រៀលនៅលើទីផ្សារសម្រាប់ការបង់ពន្ធនិងការប្រមូលកសិផល ប៉ុន្តែបានកើនឡើងមកវិញបន្ទាប់ពីតម្រូវការប្រាក់រៀលបានថមថយនាគ្រាបន្ទាប់។ ចាប់ពីខែកក្កដា ទំហំដាក់ឱ្យដេញថ្លៃត្រូវបានដំឡើងដល់ ១,៥ ទ្រីលានរៀលក្នុងមួយលើក ដោយផ្តោតលើឥណប្រតិទាន ៧ថ្ងៃ ខណៈដែលអត្រាការប្រាក់ NCD ជាប្រាក់រៀលដែលមានឥណប្រតិទាន ៩១ថ្ងៃ និង ១៨២ ថ្ងៃ ត្រូវបានបន្ថយពី ១,៣៣% មក ១,១៥% និង ១,៣៨% មក ១,៣០% រៀងគ្នា។ ទន្ទឹមនេះ អត្រាការប្រាក់ NCD ជារៀលជាមធ្យមបានកើនឡើងពី ០,៩៧% នាឆ្នាំមុនដល់ ១,០៥% ដែលក្នុងនោះ អត្រាការប្រាក់ NCD ៧ថ្ងៃមានកម្រិត ០,៩៨% (កើនពី ០,៦៣%) ៩១ថ្ងៃ ១,០៦% (ថយពី ១,២៨%) និង ១៨២ថ្ងៃ ១,១១% (កើនពី ០,៩៩%)។

**ក្រាហ្វ ៥០៖ NCD ជារៀល**
(គិតជាទ្រីលានរៀល, ខែមករា - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥១៖ អត្រាការប្រាក់ NCD ជារៀល**
(គិតជាភាគរយ, ឆ្នាំ២០២៤ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[២៤] ធនាគារជាតិនៃកម្ពុជាបានផ្លាស់ប្តូរថ្ងៃដេញថ្លៃ និងទូទាត់ NCD ក្នុងថ្ងៃតែមួយ (T+0) ចាប់ពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥។

ការស្រូបយកសន្ទនីយភាពជាដុល្លារអាមេរិកសរុបមាន ៣,៨ ប៊ីលានដុល្លារអាមេរិក ថយចុះ ០,៨% ធៀបនឹងឆ្នាំមុន ដែលក្នុងនោះឥណប្រតិទាន ៩១ថ្ងៃ មាន ២,១ ប៊ីលានដុល្លារអាមេរិក ១៨២ថ្ងៃ មាន ១,២ ប៊ីលានដុល្លារអាមេរិក និង ៣៦៤ថ្ងៃ មាន ០,៥ ប៊ីលានដុល្លារអាមេរិក។ NCD ជាដុល្លារអាមេរិកដែលមិនទាន់ដល់ឥណប្រតិទានមាន ១,៤ ប៊ីលានដុល្លារអាមេរិក។ គួររំលេចថា ការដេញថ្លៃ NCD ជាដុល្លារអាមេរិកមានទំហំខ្ពស់ជាងទំហំដាក់ឱ្យដេញថ្លៃ ដែលបានឆ្លុះបញ្ចាំងពីកម្រិតខ្ពស់នៃស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិកជាមធ្យមបានថយពី ១,១១% នាឆ្នាំ២០២៤ មកត្រឹម ០,៨៣% ដែលក្នុងនោះអត្រាការប្រាក់ NCD ៩១ថ្ងៃមានកម្រិត ០,៥១% (ថយពី ១,០៩%) ១៨២ថ្ងៃ ០,៩១% (ថយពី ១,០៨%) និង ៣៦៤ថ្ងៃ ១,០៦% (ថយពី ១,១៦%) គិតត្រឹមការចេញផ្សាយក្នុងត្រីមាសទី២[២៥]។

**ក្រាហ្វ ៥២៖ NCD ជាដុល្លារអាមេរិក**

(គិតជាលានដុល្លារអាមេរិក, ខែមករា- ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៣៖ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក**

(គិតជាភាគរយ, ឆ្នាំ២០២៤ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ- ប្រតិបត្តិការផ្តល់សន្ទនីយភាព

ការផ្តល់សន្ទនីយភាពជារៀលទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈ LPCO សរុបមានចំនួន ៤,១ ទ្រីលានរៀល (ស្មើនឹង ១.០២៧,២ លានដុល្លារអាមេរិក) ដែលបានថយចុះ -៤,៨៦% ធៀបនឹងឆ្នាំមុន ដោយក្នុងនោះ ឥណប្រតិទាន៧ថ្ងៃ មាន ១,៧ ទ្រីលានរៀល ៩១ថ្ងៃ មាន ១,៧ ទ្រីលានរៀល និង ១៨២ថ្ងៃ មាន ១,២ ទ្រីលានរៀល។ ការថយចុះនេះគឺដោយសារកម្រិតខ្ពស់នៃសន្ទនីយភាពជាប្រាក់រៀលក្នុងប្រព័ន្ធធនាគារ ស្របពេលកំណើនឥណទានបានថយល្បឿន។ LPCO មិនទាន់ដល់ឥណប្រតិទានមាន ១ ទ្រីលានរៀល ដែលកើនឡើង ៤៣,៥៧% ធៀបនឹងឆ្នាំមុន។



អត្រា LPCO 7ថ្ងៃ

**២,៧៥%**

*(៣,៥% ក្នុងឆ្នាំ២០២៤)*

ជាមួយគ្នានេះ អត្រាការប្រាក់ LPCO ដែលមានឥណប្រតិទាន ៧ថ្ងៃ ៩១ថ្ងៃ និង ១៨២ថ្ងៃ ត្រូវបានកាត់បន្ថយមកត្រឹម ២,៧៥% (ថយពី ៣,៥០%) ៣,២៥% (ថយពី ៤,០០%) និង ៣,៥០% (ថយពី ៤,២៥%) រៀងគ្នា ឱ្យស្របតាមស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងនិន្នាការទីផ្សារអន្តរជាតិ។ ទន្ទឹមនេះ អត្រាការប្រាក់ដេញថ្លៃបាន LPCO មានកម្រិតទាបជាមធ្យមថយពី ៤,០៧% នាឆ្នាំ២០២៤ មកត្រឹម ៣,៣៥% នាឆ្នាំ២០២៥ ដែលក្នុងនោះ អត្រាការប្រាក់ LPCO ៧ថ្ងៃមានកម្រិត ៣,០៦% (ថយពី ៣,៧៣%) ៩១ថ្ងៃ ៣,៣៨% (ថយពី ៤,១៣%) និង ១៨២ថ្ងៃ ៣,៦៤% (ថយពី ៤,៣៣%)។

[២៥] មិនមានការដាក់ឱ្យដេញថ្លៃចាប់ពីថ្ងៃទី២៤ ខែកក្កដា។

**ក្រាហ្វ ៥៤៖ ទំហំទឹកប្រាក់ក្នុងប្រតិបត្តិការ LPCO**

(គិតជាប៊ីលានរៀល, ខែមករា-ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៥៖ អត្រាការប្រាក់ដេញថ្លៃបាន ប្រតិបត្តិការ LPCO**

(គិតជាភាគរយ, ខែមករា - ខែធ្នូ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនឹង LPCO តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (Marginal Lending Facility-MLF) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ទទួលបានសន្ទនីយភាពជារៀលពីធនាគារជាតិនៃកម្ពុជាចំនួន ១,៧ ប៊ីលានរៀល នាឆ្នាំ២០២៥ ដែលធ្លាក់ចុះ -៩៨,៣% ធៀបនឹងឆ្នាំមុន។

ជារួម រូបិយវត្ថុទូទៅបន្តមានកំណើនរឹងមាំ ទោះបីជាបានថយចុះបន្តិចធៀបនឹងឆ្នាំមុន។ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសន្ទនីយភាព ធនាគារជាតិនៃកម្ពុជាបានធ្វើប្រតិបត្តិការរូបិយវត្ថុប្រកបដោយប្រុងប្រយ័ត្ន។ ទន្ទឹមនេះ ការបង្រួមកូរីដ័រអត្រាការប្រាក់ត្រូវបានធ្វើឡើង សំដៅពង្រឹងប្រសិទ្ធភាពនៃអត្រាការប្រាក់យោង។

## III- វឌ្ឍនភាពប្រព័ន្ធធនាគារ

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារកម្ពុជាមាន ធនាគារពាណិជ្ជ ៥៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ ធនាគារឯកទេស ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៥ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១២ គ្រឹះស្ថានឥណទានជនបទ ៨៩ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ ៣០ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងបរទេស ៥ និងអាជីវកម្មប្ដូរប្រាក់ ៣.៣៩៥[២៧]។

**ក្រាហ្វ ៥៦៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាទ្រីលានរៀល, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ៥៧៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(គិតជាលានគណនី, ឆ្នាំ២០២១ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា)

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ[២៨] បានកើន ៩,៥% ដល់ ៤០៧,១ ទ្រីលានរៀល (១០១,៨ ប៊ីលានដុល្លារអាមេរិក) ដោយក្នុងនោះទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានសមាមាត្រ ៩៧% និងបានកើនឡើង ៩,៧% ដល់ ៣៩៤,៨ ទ្រីលានរៀល (៩៨,៧ ប៊ីលានដុល្លារអាមេរិក) ខណៈដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានសមាមាត្រ ៣% និងបានកើនឡើង ៣,១% ដល់ ១២,៣ ទ្រីលានរៀល (៣,១ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៥៨៖ កំណើនទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០២២ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥)

---

[២៧] អាជីវកម្មប្ដូរប្រាក់ដែលមានអាជ្ញាប័ណ្ណមាន ៤០ (រាជធានីភ្នំពេញចំនួន ៣៥ និងខេត្តចំនួន ៥) និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្ដូរប្រាក់មាន ៣.៣៥៥ (រាជធានីភ្នំពេញចំនួន ៥៨ និងខេត្តចំនួន ៣.២៩៧)។

[២៨] រួមបញ្ចូលធនាគារពាណិជ្ជ ធនាគារឯកទេស MDIs MFIs និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

ឥណទានអតិថិជនបានកើនឡើងប្រមាណ ៤,១% ដល់ ២៥២,២ ទ្រីលានរៀល (៦៣ ប៊ីលានដុល្លារអាមេរិក) ខណៈប្រាក់បញ្ញើអតិថិជនបានកើន ១៤,៧% ដល់ ២៦២,៩ ទ្រីលានរៀល (៦៥,៧ ប៊ីលានដុល្លារអាមេរិក) ហើយដើមទុនបានកើន ២,៨% ដល់ ៤១,៩ ទ្រីលានរៀល (១០,៤ ប៊ីលានដុល្លារអាមេរិក)។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុបន្ថែមឱ្យកាន់តែទូលំទូលាយជូនអតិថិជន ដោយចំនួនគណនីប្រាក់បញ្ញើនិងឥណទានបានកើនដល់ ៣០,៦ និង ៤,៥ លានគណនី រៀងគ្នា។ ចំនួនទីស្នាក់ការកណ្តាលនិងសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បានកើនជាលំដាប់ដល់ ២.៧៣៥ ទីតាំង ជាមួយនឹងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៦.០៤៦ ម៉ាស៊ីនទូទាំងប្រទេសផងដែរ។




ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ[២៩]បានកើនឡើង ៣,៨% ដល់ ២៤០,៧ ទ្រីលានរៀល (៦០,២ ប៊ីលានដុល្លារអាមេរិក) និងបានផ្តល់ទៅកាន់វិស័យសំខាន់ៗ ដូចជា សកម្មភាពផ្ទែកអចលនទ្រព្យ ២២,៥% អាជីវកម្មលក់រាយ ១៦,៨% សកម្មភាពគ្រួសារ ១០,៦% សំណង់ ១០,៥% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩,៥% អាជីវកម្មលក់ដុំ ៨,៥% និង ផ្សេងៗ ២១,៦%។

**ក្រាហ្វ ៥៩៖ ឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យសំខាន់ៗ ក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

[២៩] រួមមានធនាគារពាណិជ្ជ និង MDIs។

ទន្ទឹមនេះ ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ បានកើនឡើង ៨,៧% ដល់ ១១,៥ ទ្រីលានរៀល (២,៩ ប៊ីលានដុល្លារអាមេរិក) និងបានផ្តល់ទៅកាន់វិស័យសំខាន់ៗ ក្នុងសកម្មភាពសេដ្ឋកិច្ច រួមមាន៖ តម្រូវការផ្ទាល់ខ្លួន ៥០% ការផ្គត់ផ្គង់សេវាសាធារណៈ ១៤,១% ពាណិជ្ជកម្មនិងជំនួញ ៧,៧% វិស័យសំណង់ ៧,៨% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៦,៧% កម្មន្តសាល ៤,៤% ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន ៣,៥% និងវិស័យផ្សេងៗ ៥,៨%។

**ក្រាហ្វ ៦០៖ ឥណទានតាមវិស័យសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

### ប្រអប់ ៦៖ ការបែងចែកប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

នៅក្នុងក្របខណ្ឌនៃការវិភាគនិងចងក្រងទិន្នន័យ ធនាគារជាតិនៃកម្ពុជាបានបែងចែកប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាពីរគឺ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ដែលប្រភេទនីមួយៗរួមមានគ្រឹះស្ថានដូចខាងក្រោម៖

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រួមមាន ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ រួមមាន ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ។

## ២- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ក- ការត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជាបាននិងបន្តតាមដាន និងត្រួតពិនិត្យជាប្រចាំចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ វិធីសាស្ត្រត្រួតពិនិត្យត្រូវបានពង្រឹងជាប្រចាំតាមរយៈការអនុវត្តក្របខណ្ឌនៃការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ដោយអនុលោមតាមវិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃស្រេប (SREP) សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងអនុវត្តវិធីសាស្ត្រនៃការត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត និងវិធីសាស្ត្រ CAMEL-HIS សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ ការវាយតម្លៃនេះផ្តោតលើ៖ i/-ភាពគ្រប់គ្រាន់នៃដើមទុន ii/-គុណភាពទ្រព្យសកម្ម iii/-អភិបាលកិច្ច iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញ v/-គុណភាពសន្ទនីយភាព vi/-គុណវុឌ្ឍិរបស់បុគ្គលិក vii/-ការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និង viii/-ការគ្រប់គ្រងប្រព័ន្ធធនាគារស្នូលក្នុងការរក្សាទិន្នន័យនិងការពារពីការវាយប្រហារតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងការធ្វើស្រ្តេសតេស្ត ដើម្បីវាយតម្លៃនិងវាស់វែងលើភាពគ្រប់គ្រាន់នៃសន្ទនីយភាពនិងដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងត្រួតពិនិត្យលើអនុបាតឥណទានមិនដំណើរការ ឥណទានរៀបចំឡើងវិញ លទ្ធភាពស្វែងរកប្រាក់ចំណេញ ព្រមទាំងអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិជាដើម។

នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានជួបប្រជុំជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានជាបន្តបន្ទាប់ ដើម្បីពិភាក្សាអំពីស្ថានភាពនៃអាជីវកម្ម គុណភាពឥណទាន ការដោះស្រាយឥណទានមិនដំណើរការ យុទ្ធសាស្ត្រអាជីវកម្ម និងស្ថានភាពឥណទានចំពោះវិស័យអចលនទ្រព្យជាដើម។ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៨ ដោយបានផ្តោតលើការវាយតម្លៃ៖ i/-គុណភាពឥណទាន រួមទាំង ការធ្វើចំណាត់ថ្នាក់ឥណទាន ការធ្វើសំវិធានធនលើអ៊ីមភែរមិន និងការរៀបចំឥណទានឡើងវិញ ii/-អភិបាលកិច្ច iii/-ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការ iv/-ការត្រួតពិនិត្យលើការអនុវត្តតាមអនុសាសន៍ដែលបានដាក់ចេញ និង v/-ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាលទ្ធផល គ្រឹះស្ថានភាគច្រើនបន្តរក្សាបានភាពធន់នៃដើមទុននិងភាពគ្រប់គ្រាន់នៃសន្ទនីយ មានអភិបាលកិច្ចល្អ គ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួនក៏នៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុងនិងអភិបាលកិច្ច ការប្រឈមនឹងកំណើនឥណទានមិនដំណើរការ ការថយចុះលទ្ធភាពស្វែងរកប្រាក់ចំណេញ ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការនៅមានកម្រិត និងការមិនទាន់អនុវត្តបានពេញលេញតាមអនុសាសន៍ ដែលទាមទារឱ្យមានការត្រួតពិនិត្យនិងតាមដានជាប្រចាំ និងដាក់ចេញនូវអនុសាសន៍និងវិធានការកែតម្រូវបន្ថែមទៀត។

ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារជាតិនៃកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែងចំនួន ៤៧ គ្រឹះស្ថាន ក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨ ការិយាល័យតំណាង ១ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ២ និងគ្រឹះស្ថានឥណទានជនបទ ៣៦។ វិសាលភាពនៃការត្រួតពិនិត្យដល់ទីកន្លែង គឺផ្តោតសំខាន់លើការធ្វើចំណាត់ថ្នាក់ឥណទាន ការធ្វើសំវិធានធន

លើអ៊ីមែរមិន អភិបាលកិច្ច និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ជាលទ្ធផលបានបង្ហាញថា គ្រឹះស្ថានភាគច្រើនរក្សាបាននូវភាពធន់នៃសន្ទនីយភាពនិងដើមទុន ដោយបានពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន តាមរយៈការយកចិត្តទុកដាក់ខ្ពស់ក្នុងការបញ្ចេញឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន និងបរិយាបន្ន ស្របពេលគ្រឹះស្ថានភាគច្រើនបន្តអនុលោមតាមច្បាប់និងបទប្បញ្ញត្តិបានល្អ។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ និងការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារជាតិនៃកម្ពុជាក៏បានចាត់វិធានការនានា ដូចជាការផ្តល់ជាអនុសាសន៍កែតម្រូវ និងការពិន័យជាដើម ចំពោះគ្រឹះស្ថានណាដែលមិនបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ។

ទន្ទឹមនេះ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជា បញ្ញាសិប្បនិម្មិត សេវាក្លោដ ទិន្នន័យធំ ប្លុកឆេន និងបច្ចេកវិទ្យាកង់ទិចគណនា (Quantum Computing) បានបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងផ្តល់សេវាកម្មថ្មីៗជូនអតិថិជន ប៉ុន្តែបច្ចេកវិទ្យាទាំងនេះ ក៏អាចបង្កជាហានិភ័យដែលមិនអាចមើលរំលងបានដូចជា ការរាំងស្ទះដំណើរការប្រព័ន្ធ និងការគំរាមកំហែងសាយប័រ។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងកែសម្រួលសេចក្តីណែនាំស្តីពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយបានពិគ្រោះយោបល់ជាមួយគ្រឹះស្ថានទាំងនោះ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន ២ លើក និងបានរៀបចំកិច្ចពិភាក្សាជាមួយគ្រឹះស្ថានស្តីពីសុវត្ថិភាពសាយប័រ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់សន្តិសុខសាយប័រ។

ក្នុងក្របខណ្ឌត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារពាណិជ្ជចំនួន ៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ដោយផ្តោតទៅលើអភិបាលកិច្ច ប្រព័ន្ធធនាគារស្នូល សុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា ឧបទ្ទវហេតុព័ត៌មានវិទ្យា ការគ្រប់គ្រងការផ្លាស់ប្តូរ សេវាក្លោដ ប្លុកឆេន ផែនការនិរន្តរភាពធុរកិច្ច ផែនការស្តារប្រព័ន្ធពីគ្រោះមហន្តរាយ និងការពិនិត្យឯកសារសវនកម្មព័ត៌មានវិទ្យា។ ជាលទ្ធផល គ្រឹះស្ថានទាំងនោះបានអនុវត្តល្អនូវការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា បទដ្ឋាន ឧត្តមានុវត្តន៍ និងអនុលោមតាមសេចក្តីណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការគ្រប់គ្រងសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធធនាគារស្នូល ការតាមដានប្រតិបត្តិការជាមួយតតីយភាគីរបស់គ្រឹះស្ថាន ការពឹងផ្អែកលើក្រុមហ៊ុនផ្តល់សេវាក្លោដតែមួយ និងការខ្វះខាតការធ្វើតេស្តជ្រៀតចូលប្រព័ន្ធ ជាដើម ដែលទាមទារនូវការតាមដាន និងត្រួតពិនិត្យជាប្រចាំលើការអនុវត្តតាមអនុសាសន៍របស់ធនាគារជាតិនៃកម្ពុជា។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍឧបករណ៍ត្រួតពិនិត្យសម្រាប់ការវាយតម្លៃលើស្ថានភាពរបស់គ្រឹះស្ថាន ដែលជាជំនួយ ក្នុងការវិភាគ និងតាមដានហានិភ័យបច្ចេកវិទ្យានិងសាយប័រ។ ទន្ទឹមនេះ ការធ្វើទំនើបកម្មប្រព័ន្ធត្រួតពិនិត្យក៏ត្រូវបានធ្វើឡើងដើម្បីបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យ និងការធ្វើស្វ័យប្រវត្តិកម្មការងារ ដូចជាប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ ប្រព័ន្ធវិភាគទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងលំហូរការងារជាដើម។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងប្រើប្រាស់ធនធានមនុស្សផ្ទៃក្នុង និងសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់បច្ចេកវិទ្យាត្រួតពិនិត្យដើម្បីសិក្សាកាលានុវត្តភាពនៃបច្ចេកវិទ្យាថ្មីៗផងដែរ។ ធនាគារជាតិនៃកម្ពុជាបាននិងបន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យទៅលើប្រធានបទថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៅក្នុងវិស័យហិរញ្ញវត្ថុ និងការបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ២- ការត្រួតពិនិត្យការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបន្តរៀបចំទម្រង់របាយការណ៍ថ្មីៗស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) សម្រាប់ដាក់ឱ្យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើអនុវត្ត ហើយគិតត្រឹមឆ្នាំ២០២៥ ចំនួនរបាយការណ៍បានកើនឡើងដល់ ៥១ របាយការណ៍។ ជាមួយគ្នានេះដែរ ទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ចំនួន ២២ របាយការណ៍ កំពុងត្រូវបានរៀបចំសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្តក្នុងពេលដ៏ខ្លីខាងមុខផងដែរ។ ទន្ទឹមនេះ ផ្ទាំងបង្ហាញព័ត៌មានសង្ខេប (Dashboard) ក៏ត្រូវបានរៀបចំនិងអនុវត្តជាបណ្តើរៗ សម្រាប់ពង្រឹងការតាមដាន និងការវិភាគស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជាផងដែរ។

ជាមួយគ្នានេះ ដើម្បីបន្តពង្រឹងគុណភាពនៃទិន្នន័យផ្នែកត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីរបាយការណ៍ត្រួតពិនិត្យទម្រង់ថ្មីដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីផ្សព្វផ្សាយទម្រង់របាយការណ៍ថ្មី និងផ្តល់ជាវេទិកាសម្រាប់ឆ្លុះបញ្ចាំងអំពីការអនុវត្តនិងពិភាក្សាអំពីបញ្ហាប្រឈមដែលគ្រឹះស្ថានបានជួបប្រទះក្នុងអំឡុងពេលនៃការរាយការណ៍។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញនូវវិធានការរដ្ឋបាលដំណាក់កាលដំបូងក្រោមរូបភាពជាកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងគ្រឹះស្ថានដែលមិនអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងកាតព្វកិច្ចរាយការណ៍ ដែលរួមមានគ្រឹះស្ថានទាំងឡាយណាដែលមានភាពយឺតយ៉ាវក្នុងការបញ្ជូនរបាយការណ៍ និងមានកំហុសឆ្គងក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យប្រចាំគ្រាផងដែរ។

## ៣- ការរៀបចំបទប្បញ្ញត្តិ

ដើម្បីធានាវឌ្ឍនភាពនៃប្រព័ន្ធធនាគារ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិថ្មី និងកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់ជាបន្តបន្ទាប់។ នាឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងប្រកាសស្តីពី វិធានការបុរេសកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំប្រកាស និងសេចក្តីណែនាំមួយចំនួន រួមមាន៖ i/- ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ii/- ប្រកាសស្តីពី ការកំណត់ពិដានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/- ប្រកាសស្តីពី ក្របខណ្ឌអនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ iv/- ប្រកាសស្តីពី ការគួបសរុបផ្នែកបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង v/- សេចក្តីណែនាំស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំបទប្បញ្ញត្តិឱ្យស្របតាមការវិវឌ្ឍនៃប្រព័ន្ធហិរញ្ញវត្ថុ និងស្តង់ដាអន្តរជាតិ នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដូចជា៖ i/- កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរក្នុងស្រុក និងអង្គភាពពាក់ព័ន្ធ រួមមាន និយ័តករមូលបត្រកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកិច្ចការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ii/-កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ iii/- កិច្ចសហប្រតិបត្តិការ

អន្តរជាតិជាមួយក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មកូរ៉េ (KAMCO) ពាក់ព័ន្ធនឹងការដោះស្រាយឥណទានមិនដំណើរការ iv/- កិច្ចសហប្រតិបត្តិការជាមួយក្រុមជំនាញការមកពីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) តាមរយៈការផ្តល់ជំនួយផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង v/- កិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជននិងកីឡា ពាក់ព័ន្ធនឹងការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅដំណាក់កាលទី៣។

គិតត្រឹម ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ១២លើក និងវគ្គបណ្តុះបណ្តាលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៧លើក។ វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងវិស័យធនាគារ ព្រមទាំងផ្សព្វផ្សាយបទប្បញ្ញត្តិថ្មី ពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលមាន។

### ៤- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ

បរិយាបន្នហិរញ្ញវត្ថុ នៅតែជាការងារអាទិភាពដ៏សំខាន់មួយរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលមានលក្ខណៈទាន់ពេលវេលា តម្លៃសមរម្យ និងមានការការពារតាមច្បាប់សម្រាប់ប្រជាជនគ្រប់រូប ជាពិសេសជនក្រីក្រ ប្រជាជននៅតាមតំបន់ជនបទ ស្ត្រី និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។ ធនាគារជាតិនៃកម្ពុជា បានបន្តអនុវត្តផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ យ៉ាងសកម្ម និងកំពុងរៀបចំធ្វើបច្ចុប្បន្នភាព យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៦-២០៣០ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការបន្តធានាឱ្យបាននូវវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងចីរភាព ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ក្រាហ្វ ៦១៖ ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកប្រើប្រាស់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
(គិតជាលាននាក់, ២០២៤ - ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែកញ្ញា២០២៥)

ការងារលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ បន្តមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលឆ្លុះ-បញ្ចាំងតាមរយៈកំណើនចំនួនអ្នកដាក់ប្រាក់បញ្ញើ ៣៤,៩% ដល់ ១៨,៦ លាននាក់ និងកំណើនចំនួនអ្នកប្រើប្រាស់សេវាឥណទាន ១៨,៨% ដល់ ៤,៣ លាននាក់។

ដើម្បីគាំទ្រដល់ការរៀបចំគោលនយោ-បាយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីប្រកបដោយចីរភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងប្រមូលទិន្នន័យបែងចែកតាមភេទ (Sex Disaggregated Data)។ គិតត្រឹមឆ្នាំ២០២៥ នេះ ភាគរយនៃស្ត្រីដែលបានប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានច្រើនជាងបុរស ទាំងការប្រើប្រាស់សេវាប្រាក់កម្ចី និងប្រាក់បញ្ញើ។ ចំពោះវិស័យធនាគារ ចំនួនស្ត្រីដែលបានប្រើប្រាស់សេវាប្រាក់កម្ចីមានប្រមាណ ៥៣% និងចំនួនស្ត្រីដែលមានប្រាក់បញ្ញើមានប្រមាណ ៥១%។ ចំណែកឯ វិស័យមីក្រូហិរញ្ញវត្ថុ ចំនួនស្ត្រីដែលបានប្រើប្រាស់សេវាប្រាក់កម្ចី និងប្រាក់បញ្ញើមានប្រមាណ ៦៧% និង ៦៥% រៀងគ្នា។

ក្រាហ្វ ៦២៖ ចំនួនអ្នកប្រើប្រាស់សេវាប្រាក់បញ្ញើ
(ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ៦៣៖ ចំនួនអ្នកប្រើប្រាស់សេវាឥណទាន
(ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

លើសពីនេះ ប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងមានចំនួន ១.៣២៥,៦៥ លានប្រតិបត្តិការ (កើន ១,២ ដងធៀបនឹងឆ្នាំមុន) ក្នុងនោះ ៧៧១,២ លានប្រតិបត្តិការជាប្រាក់រៀល និង ៥៥៤,៥ លានប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក និងចំនួនគណនីកាបូបអេឡិចត្រូនិកមានប្រមាណ ១៨,៩ លានគណនី[៣០]។ ជាមួយគ្នានេះ ការប្រើប្រាស់សេវាកម្មធនាគារប៉ារង[៣១] មានកំណើនល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនចំនួនប័ណ្ណសន្សាប៉ារង ១៧២,៩% ដល់ ៣.៨៣២.២៩៤ ប័ណ្ណ និងកំណើនចំនួនទឹកប្រាក់ធានា ២៩% ដល់ ១០២,៨ ប៊ីលានដុល្លារអាមេរិក។

## ៥- កិច្ចការពារអតិថិជន

ដើម្បីរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជន ក៏ដូចជាចូលរួមដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវានិងផលិតផលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេល និងមានសង្គតិភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូរស័ព្ទហតឡាញ ចំនួន ២៦ ខ្សែ (ទីស្នាក់ការកណ្តាលចំនួន ៥ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន ២១ខ្សែ) ដើម្បីផ្តល់លទ្ធភាពបន្ថែមដល់អ្នកប្រើប្រាស់អាចដាក់ពាក្យបណ្តឹង ស្នើសុំការអន្តរាគមន៍ ឬសាកសួរព័ត៌មានផ្សេងៗពាក់ព័ន្ធការប្រើប្រាស់សេវានិងផលិតផលហិរញ្ញវត្ថុ។

នាឆ្នាំ២០២៥ មន្ត្រីទទួលបន្ទុកហតឡាញធនាគារជាតិនៃកម្ពុជា បានទទួលបណ្តឹងនិងការសាកសួរសរុបចំនួន ៧២១ ករណី (បណ្តឹងនៅទីស្នាក់ការកណ្តាលមានចំនួន ៥៣៣ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត មានចំនួន ១៨៨ ករណី) ក្នុងនោះបណ្តឹងចំនួន ៦៨៣ ករណី ត្រូវបានដោះស្រាយរួចរាល់ បណ្តឹងចំនួន ១២ ករណីទៀតកំពុងត្រូវបានដោះស្រាយ និងបណ្តឹងចំនួន ២៦ ករណីផ្សេងទៀត ស្ថិតក្នុងនីតិវិធីតុលាការ។ បណ្តឹងនិងការសាកសួរទាំងនេះពាក់ព័ន្ធនឹង៖ i/- ការពិន័យលើការបង់ផ្តាច់ឥណទានមុនកាលកំណត់ ii/-ការស្នើសុំរៀបចំឥណទានឡើងវិញ iii/-កម្ចីខុសច្បាប់ iv/-ការឆបោកផ្នែកហិរញ្ញវត្ថុ v/-ការស្នើសុំអនុគ្រោះលក្ខខណ្ឌទូទាត់ vi/-ការស្នើសុំដំណើរការគណនីដែលបានបង្កក vii/-ការដកប្រាក់បញ្ញើពីគ្រឹះស្ថានដែលត្រូវបានដកហូតអាជ្ញាប័ណ្ណ viii/-ការស្នើសុំកែតម្រូវព័ត៌មានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និង ix/-ការយឺតយ៉ាវក្នុងការដកទ្រព្យធានា។

[៣០] ទិន្នន័យគិតត្រឹមខែ១១ ឆ្នាំ២០២៥។
[៣១] ទិន្នន័យគិតត្រឹម១១ខែ នៃឆ្នាំ២០២៥។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បន្តពង្រឹងយន្តការគ្រប់គ្រងនិងដោះស្រាយបណ្ដឹងអតិថិជន តាមរយៈការពិនិត្យនិងកែសម្រួលឡើងវិញនូវប្រកាសស្ដីពី ការដោះស្រាយបណ្ដឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីឱ្យស្របច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងការវិវត្តនៃប្រព័ន្ធធនាគារ។

កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយភាគីពាក់ព័ន្ធ លើកទី៣ ស្ដីពី "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាង ធនាគារជាតិនៃកម្ពុជា និងអង្គការសហប្រជាជាតិនៅកម្ពុជា ក្នុងគោលបំណងសម្របសម្រួលឱ្យមានការចូលរួមពិភាក្សាក្នុងន័យស្ថាបនាពីភាគីពាក់ព័ន្ធ បង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីបញ្ហាប្រឈមនានា និងកំណត់សកម្មភាពនិងការប្ដេជ្ញាចិត្តជាក់លាក់ ដែលអាចគាំទ្រដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការដោះស្រាយបញ្ហាបំណុលលើសលប់ និងចាប់យកកាលានុវត្តភាពក្នុងការពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុ។ ជាលទ្ធផល ក្នុងចំណោមសកម្មភាពអាទិភាពចំនួន ២២ សកម្មភាពអាទិភាពចំនួន ១០ ត្រូវបានអនុវត្តពេញលេញ និងសកម្មភាពអាទិភាពចំនួន ១២ទៀត កំពុងបន្តអនុវត្ត ដែលមានសង្ខេបតាមផ្នែកអាទិភាពទាំង ៥។




*ធនាគារជាតិនៃកម្ពុជាសហការជាមួយអង្គការសហប្រជាជាតិនៅកម្ពុជា*
*រៀបចំកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយភាគីពាក់ព័ន្ធ លើកទី៣ ស្ដីពី "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា"*
*នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

ទន្ទឹមនេះ កិច្ចពិគ្រោះយោបល់ ស្ដីពី "ការចូលរួមរបស់វិនិយោគិនប្រកបដោយការទទួលខុសត្រូវ" ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្ដោតលើក្របខណ្ឌអភិបាលកិច្ចដែលមានស្រាប់ និងភាពខ្វះចន្លោះ ដែលចំណុចទាំងអស់នោះអាចនឹងយកមកកសាងជាទិសដៅយុទ្ធសាស្ត្រមួយក្នុងការអនុវត្តរបស់វិនិយោគិនឱ្យស្របទៅនឹងចក្ខុវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព និងផ្ដោតទៅលើការជឿទុកចិត្ត ការទទួលខុសត្រូវរួម និងកំណើនប្រកបដោយបរិយាបន្ន។

បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បានគាំទ្រគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា លើការរៀបចំស្វ័យបញ្ញត្តិ រួមមាន៖ i/-វិសោធនកម្មស្ដង់ដាកិច្ចសន្យាឥណទានសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ ii/-ក្របខណ្ឌនៃការផ្ដល់ការលើកទឹកចិត្តសម្រាប់មន្ត្រីពាក់ព័ន្ធនឹងផ្នែកឥណទាន iii/-គោលការណ៍ណែនាំស្ដីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីពាក់ព័ន្ធនឹងផ្នែកឥណទាន និង iv/-និយមន័យប្រតិបត្តិការឥណទានខ្នាតមីក្រូសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ដើម្បីធានាឱ្យបាននូវកិច្ចការពារអតិថិជនប្រកបដោយតម្លាភាព នាឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជា បានធ្វើការអង្កេតការអនុវត្តក្រមប្រតិបត្តិទីផ្សារ ក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន ៥ រួមមានៈ ខេត្តត្បូងឃ្មុំ ព្រះវិហារ រតនគិរី កោះកុង និងប៉ៃលិន។ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងវាយតម្លៃទៅលើក្រមប្រតិបត្តិទីផ្សាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ក្នុងការធានាឱ្យបាននូវតម្លាភាព ប្រសិទ្ធភាព និងការការពារសិទ្ធិនិងផលប្រយោជន៍របស់អតិថិជន ដែលបានប្រើប្រាស់ផលិតផលនិងសេវារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ការសិក្សានេះផ្អែកទៅលើការវាយតម្លៃវិធីសាស្ត្ររបស់បុគ្គលិកឥណទានក្នុងការផ្តល់ឥណទានជូនដល់អតិថិជន និងការសិក្សាស្វែងយល់អំពីចំណាប់អារម្មណ៍និងការពេញចិត្តរបស់អតិថិជនចំពោះសេវាឥណទានរបស់គ្រឹះស្ថាន។ បន្ថែមលើនេះ ការសិក្សាស្រាវជ្រាវនេះក៏មានគោលបំណងបញ្ជ្រាបការយល់ដឹងអំពីបំណិនហិរញ្ញវត្ថុបន្ថែមដល់ប្រជាជន និងផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់កម្ចីខុសច្បាប់ផងដែរ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានជួបសំណេះសំណាលការងារជាមួយអភិបាលនៃគណៈអភិបាល និងថ្នាក់ដឹកនាំរដ្ឋបាល ខេត្តកំពង់ចាម ខេត្តរតនគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ក្នុងគោលបំណងស្វែងយល់បន្ថែមពីស្ថានភាពសេដ្ឋកិច្ច និងស្នើសុំកិច្ចសហការក្នុងការបង្ការនិងចាត់វិធានការលើកម្ចីខុសច្បាប់ ព្រមទាំងចែករំលែកព័ត៌មានពីកម្មវិធីមួយចំនួនរបស់ធនាគារជាតិនៃកម្ពុជា ដូចជា ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន និងទិវាប្រាក់រៀល ជាដើម។



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូ ធនាគារជាតិនៃកម្ពុជា ជួបសំណេះសំណាលការងារជាមួយអភិបាលនៃគណៈអភិបាលខេត្តខេត្តស្ទឹងត្រែង នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥*

## ៦- កិច្ចការពារប្រាក់បញ្ញើ

ក្នុងគោលបំណងការពារអ្នកដាក់ប្រាក់បញ្ញើ រក្សាទំនុកចិត្តសាធារណជនលើប្រព័ន្ធធនាគារ និងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំក្របខណ្ឌច្បាប់សម្រាប់អនុវត្តយន្តការកិច្ចការពារប្រាក់បញ្ញើ ដែលរួមមានសេចក្តីព្រាងប្រកាសស្តីពី កិច្ចការពារប្រាក់បញ្ញើ ការកំណត់បុព្វលាភនិងសំណង និងរចនាសម្ព័ន្ធអភិបាលកិច្ចសម្រាប់យន្តការនេះជាដើម។

នាឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពី យន្តការកិច្ចការពារប្រាក់បញ្ញើ ជូនមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងជូនដល់ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលនឹងក្លាយជាសមាជិកនៃយន្តការកិច្ចការពារប្រាក់បញ្ញើ ព្រមទាំងបាននិងកំពុងសិក្សារៀបចំនូវនីតិវិធីនៃការជម្រះបញ្ជីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ។

## ៧- ហិរញ្ញវត្ថុប្រកបដោយចីរភាព

នៅក្នុងបរិបទនៃការប្រែប្រួលដ៏លឿននៃសេដ្ឋកិច្ច បរិស្ថាន និងសង្គម ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាព។ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាធនាគារកណ្តាល មានតួនាទីសំខាន់ក្នុងការធានាថាប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាមានស្ថិរភាព និងមានសមត្ថភាពឆ្លើយតបនឹងហានិភ័យបច្ចុប្បន្ន និងអនាគត ជាពិសេស ហានិភ័យទាំងនេះរួមមាន ហានិភ័យរូបវន្ត ដែលកើតពីគ្រោះធម្មជាតិដូចជា ទឹកជំនន់ និងភាពរាំងស្ងួត ដែលប៉ះពាល់ផ្ទាល់ដល់វិស័យកសិកម្ម និងអចលនទ្រព្យ ព្រមទាំងហានិភ័យអន្តរកាល ដែលកើតពីការផ្លាស់ប្តូរគោលនយោបាយ បច្ចេកវិទ្យា និងតម្រូវការទីផ្សារ ឆ្ពោះទៅរកសេដ្ឋកិច្ចកាបូនទាប។ ការងារហិរញ្ញវត្ថុប្រកបដោយចីរភាព ជាការងារចម្បងមួយដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាឱ្យបាននូវភាពធន់ និងការបង្ការហានិភ័យផ្សេងៗចំពោះប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះផងដែរ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមអនុវត្តគោលនយោបាយ និងគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច ព្រមទាំងផែនការជាតិដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹតភាពកាបូន របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ដើម្បីគាំទ្រដល់ការងារនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតឱ្យមានរចនាសម្ព័ន្ធការងារច្បាស់លាស់ ដោយបង្កើតឱ្យមានការិយាល័យហិរញ្ញវត្ថុប្រកបដោយចីរភាពដែលស្ថិតនៅក្រោមនាយកដ្ឋានបរិយាបន្នហិរញ្ញវត្ថុ។ ការិយាល័យនេះមានភារកិច្ចស្រាវជ្រាវអំពីនិន្នាការទូទៅនៃហិរញ្ញវត្ថុបៃតងក្នុងប្រទេស រៀបចំច្បាប់និងបទប្បញ្ញត្តិ និងគោលនយោបាយហិរញ្ញវត្ថុប្រកបចីរភាព ដើម្បីជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំបង្កើតក្រុមការងារអន្តរក្រសួងពីវិស័យពាក់ព័ន្ធ ដែលមានសមាជិកមកពីតំណាងក្រសួងពាក់ព័ន្ធចំនួន ១២ ដែលមានតួនាទីចម្បងក្នុងការផ្តល់អនុសាសន៍ និងប្រឹក្សាយោបល់លើគោលនយោបាយ យុទ្ធសាស្ត្រ គំនិតផ្តួចផ្តើម និងទិសដៅការងារអាទិភាព ដើម្បីធានាសុខដុមរមនានៃគោលនយោបាយជាតិសម្រាប់ការកៀរគរហិរញ្ញវត្ថុបៃតង។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បានសហការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ជាមួយដៃគូអភិវឌ្ឍនានា ដើម្បីនាំការអនុវត្តប្រកបដោយឧត្តមានុវត្តន៍របស់អន្តរជាតិ ក្នុងន័យចូលរួមកសាងសមត្ថភាពមន្ត្រីនៃធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដូចជា ការវាយតម្លៃហានិភ័យអាកាសធាតុមកលើប្រព័ន្ធធនាគារ ការបង្កើតផលិតផលប្រកបដោយនវានុវត្តន៍ ការគ្រប់គ្រងហានិភ័យអាកាសធាតុ និងការកត់ត្រាការបញ្ចេញកាបូន ជាដើម។ ជាមួយគ្នានេះ ប្រព័ន្ធវគ្គករសាស្ត្រកម្ពុជា និងផែនទីចង្អុលទិសហិរញ្ញវត្ថុប្រកបដោយចីរភាព គ្រោងនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២៦។ ប្រព័ន្ធវគ្គករសាស្ត្រ គឺជាប្រព័ន្ធចំណាត់ថ្នាក់ ដែលកំណត់និយមន័យច្បាស់លាស់ថាតើសកម្មភាពសេដ្ឋកិច្ច ឬគម្រោងវិនិយោគណាមួយ អាចចាត់ទុកថា "បៃតង" ឬ "ប្រកបដោយចីរភាព"។ គោលបំណងចម្បងគឺ ដើម្បីទប់ស្កាត់ការអះអាងមិនពិតអំពីភាពបៃតង (Greenwashing) និងជួយវិនិយោគិន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យបែងចែកមូលធនទៅកាន់គម្រោងដែលមានអត្ថប្រយោជន៍ពិតប្រាកដដល់បរិស្ថាន។ ការបង្កើតប្រព័ន្ធនេះនឹងជួយបង្កើតតម្លាភាព និងទំនុកចិត្តក្នុងទីផ្សារហិរញ្ញវត្ថុបៃតងនៅកម្ពុជា។

បន្ថែមពីលើការងារដែលបានអនុវត្តក្នុងប្រទេស ធនាគារជាតិនៃកម្ពុជា ត្រូវបានតែងតាំងជាសហប្រធានគណៈកម្មាធិការជាន់ខ្ពស់អាស៊ាន លើហិរញ្ញវត្ថុប្រកបដោយចីរភាព និងសមាជិកក្រុមប្រឹក្សាប្រព័ន្ធវដ្តករសាស្ត្រអាស៊ាន ដែលការចូលរួមនេះបង្ហាញថាធនាគារជាតិនៃកម្ពុជាមិនត្រឹមតែអភិវឌ្ឍលើផ្នែកជាតិទេ ប៉ុន្តែក៏បានសហការយ៉ាងសកម្មក្នុងតំបន់ទាំងមូលផងដែរ។ តួនាទីនៅក្នុងក្រុមប្រឹក្សាប្រព័ន្ធវដ្តករសាស្ត្រអាស៊ាន គឺមានសារៈសំខាន់ជាយុទ្ធសាស្ត្រ ព្រោះវានឹងធានាថាប្រព័ន្ធវដ្តករសាស្ត្រកម្ពុជា នឹងមានអន្តរប្រតិបត្តិការ ជាមួយប្រព័ន្ធវដ្តករសាស្ត្រអាស៊ាន។ ការណ៍នេះនឹងជួយសម្រួលដល់ការវិនិយោគបៃតងឆ្លងប្រទេស ដែលជាកត្តាធ្វើឱ្យទីផ្សារកម្ពុជាកាន់តែទាក់ទាញសម្រាប់មូលធនអន្តរជាតិ ដែលកំពុងស្វែងរកឱកាសវិនិយោគប្រកបដោយចីរភាព។ តួនាទីនេះបង្ហាញពីសមត្ថភាពនៃកម្ពុជា ក្នុងការធ្វើជាដៃគូសំខាន់នៃអាស៊ាន ក្នុងការជំរុញគោលនយោបាយហិរញ្ញវត្ថុបៃតង និងការបង្កើនសមត្ថភាពប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

សមិទ្ធផលនិងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាទាំងនេះ គឺជាកាតាលីករជំរុញការទទួលបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានស្ថិរភាព ភាពធន់ និងប្រកបដោយចីរភាព។

## ៨- ស្ថិរភាពហិរញ្ញវត្ថុ

ស្របពេលដែលសេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់នៃបរិការណ៍ខាងក្រៅ ប្រព័ន្ធធនាគារកម្ពុជាក៏បានទទួលរងផលប៉ះពាល់ដោយប្រយោលផងដែរ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនទាបនៃឥណទាន និងការថយចុះនៃគុណភាពឥណទាន ដែលបានដាក់សម្ពាធដល់លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បញ្ហាប្រឈមនិងហានិភ័យទាំងនោះរួមមាន៖

i/- ការរីករាលដាលនៃបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលអាចបង្កជាហានិភ័យកេរ្តិ៍ឈ្មោះ និងបង្កើនលទ្ធភាពឱ្យកម្ពុជាចូលទៅក្នុងបញ្ជីប្រផេះម្តងទៀត ដែលនេះនាំឱ្យប៉ះពាល់ដល់ជំនឿទំនុកចិត្តចំពោះការវិនិយោគបរទេស និងការធ្វើប្រតិបត្តិការធនាគារ ជាពិសេសប្រតិបត្តិការទូទាត់ឆ្លងដែន

ii/- ការផ្ទុះអាវុធតាមព្រំដែនកម្ពុជា-ថៃទាំងពីរលើក ដែលអាចជះឥទ្ធិពលដល់វិស័យទេសចរណ៍និងប្រាក់បង្វែរពលករ ដែលអាចប៉ះពាល់ដល់ចំណូលនិងលទ្ធភាពសងកម្ចីរបស់ក្រុមគ្រួសារពលករ

iii/- ការងើបឡើងយឺតនៃវិស័យសំណង់និងអចលនទ្រព្យ ដែលអាចប៉ះពាល់ដល់តម្លៃទ្រព្យធានានិងគុណភាពឥណទានទៅកាន់វិស័យនេះ

iv/- ហានិភ័យបច្ចេកវិទ្យា ដែលអាចបង្កការរាំងស្ទះដល់ប្រតិបត្តិការ អាចប៉ះពាល់ទំនុកចិត្តរបស់អតិថិជន និងអាចបង្កជាហានិភ័យនៃការដកប្រាក់គំហុក និង

v/- ហានិភ័យការប្រែប្រួលអាកាសធាតុដែលអាចជះឥទ្ធិពលដល់វិស័យធនាគារនិងហិរញ្ញវត្ថុតាមរយៈការកើនឡើងនៃហានិភ័យរូបវន្ត និងហានិភ័យអន្តរកាលមកលើវិស័យសំខាន់ៗ ដូចជាកសិកម្ម កម្មន្តសាល ជាដើម។

បើទោះជាមានបញ្ហាប្រឈមយ៉ាងណាក្តី ប្រព័ន្ធធនាគារនៅបន្តរក្សាបានភាពធន់ដែលឆ្លុះ-បញ្ចាំងតាមរយៈសូចនាករហិរញ្ញវត្ថុដូចខាងក្រោម៖

i/- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តរក្សាបានដើមទុនគ្រប់គ្រាន់ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិត ២១,៩% និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានកម្រិត ៣១,៤% ដែលខ្ពស់ជាងកម្រិតកំណត់បទប្បញ្ញត្តិ (១៥%)។ លទ្ធផលស្ត្រេសតេស្តភាពគ្រប់គ្រាន់នៃដើមទុនបានបង្ហាញថា ប្រព័ន្ធធនាគារជារួមមានភាពធន់ អាចទប់ទល់នឹងសេណារីយ៉ូហានិភ័យជាច្រើនចាប់ពីកម្រិតទាបដល់កម្រិតកើនឡើងខ្លាំងនៃឥណទានមិនដំណើរការ។

**ក្រាហ្វ ៦៤៖ អនុបាតភាពគ្រប់គ្រាន់នៃដើមទុន**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ៦៥៖ អនុបាតក្របខណ្ឌសន្ទនីយភាព**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

ii/- ចំពោះស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបន្តមានកម្រិត ១៧៧,៣% ខ្ពស់ជាងកម្រិតកំណត់បទប្បញ្ញត្តិ (១០០%) ដែលបង្ហាញពីលទ្ធភាពរឹងមាំក្នុងការបំពេញតម្រូវការសន្ទនីយភាពរយៈពេលខ្លី ដូចជាតម្រូវការសាច់ប្រាក់និងឥណទានជាដើម។ ការធ្វើស្ត្រេសតេស្តលើសន្ទនីយភាពរបស់ប្រព័ន្ធធនាគារក្រោមសេណារីយ៉ូកម្រិតមធ្យមនៃការដកប្រាក់បញ្ញើ បានបង្ហាញថា ប្រព័ន្ធធនាគារ ជារួម អាចបន្តរក្សាបាននូវក្របខណ្ឌសន្ទនីយភាពរឹងមាំ។

iii/- អនុបាតឥណទានមិនដំណើរការរបស់ប្រព័ន្ធធនាគារបន្តកើនឡើងដល់ ៨,៩% ពី ៧,៩% នាឆ្នាំ២០២៤។ យ៉ាងណាមិញ អនុបាតឥណទានមិនដំណើរការសុទ្ធ[៣២] មានកម្រិតត្រឹម ២,៩% ខណៈអនុបាតសំវិធានធនធៀបនឹងឥណទានមិនដំណើរ-ការមានកម្រិត ៦៧,៥% ដែលបង្ហាញពីលទ្ធភាពរបស់គ្រឹះស្ថានក្នុងការទប់ទល់នឹងហានិភ័យឥណទាន។

**ក្រាហ្វ ៦៦៖ ឥណទានមិនដំណើរការ**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

[៣២] គណនាដោយដកសំវិធានធនពីឥណទានមិនដំណើរការដុល

iv/- លទ្ធភាពស្វែងរកប្រាក់ចំណេញមានភាពប្រសើរឡើង[៣៣]ជាងគ្រាដូចគ្នាឆ្នាំមុន ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិត ១,២% ( ០,៩% ឆ្នាំ២០២៤) និង ៦,៧% (៤,៨% ឆ្នាំ២០២៤) រៀងគ្នា ស្របពេលដែល ROA និង ROE របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានកម្រិត ២,១% (-០,៨% ឆ្នាំ២០២៤) និង ៦% (-២,២% ឆ្នាំ២០២៤) រៀងគ្នា។

**ក្រាហ្វ ៦៧៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**
(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

**ក្រាហ្វ ៦៨៖ អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក**
(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

v/- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរៀបចំឥណទានឡើងវិញ តាមវិធានការអនុគ្រោះបទប្បញ្ញត្តិ ដើម្បីសម្រួលបន្ទុកអតិថិជនដែលជួបការលំបាកជាបណ្តោះអាសន្ន។ បច្ចុប្បន្ន ឥណទានរៀបចំឡើងវិញ មានចំនួន ២១,១ ទ្រីលានរៀល (៥,៣ ប៊ីលានដុល្លារអាមេរិក) ប្រមាណ ៨,៣% នៃឥណទានសរុប និងមានចំនួនអតិថិជន ២៥២.៨៦៨ នាក់។

**ក្រាហ្វ ៦៩៖ ឥណទានរៀបចំឡើងវិញ**
(គិតជាភាគរយ, ឆ្នាំ២០២៤ - ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ប = ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា)

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងការតាមដានស្ថិរភាពហិរញ្ញវត្ថុតាមរយៈ ការវិភាគហានិភ័យនិងភាពប្រទាក់ក្រឡាក្នុងវិស័យហិរញ្ញវត្ថុ ការធ្វើស្ត្រេសតេស្ត និងការរៀបចំសូចនាករព្រមាន។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញនូវគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នប្រកបដោយភាពអនុគ្រោះតាមរយៈបទប្បញ្ញត្តិមួយចំនួនដែលបានបញ្ចប់ ត្រឹមដំណាច់ឆ្នាំ២០២៥ ដូចជា៖ i/- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាទ្រនាប់ដើមទុនខនស៊េរវេសិននៅកម្រិត ១,២៥% និង ii/-អនុញ្ញាតឱ្យ

[៣៣] ការផ្លាស់ប្តូរទម្រង់របាយការណ៍ជា CIFRS ជាទូទៅបណ្តាលឱ្យចំណាយសំវិធានធនថយចុះ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញជូនដល់អតិថិជន ខណៈអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវបានអនុញ្ញាតឱ្យបន្តរក្សាក្នុងកម្រិត ៧% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ ដើម្បីជំរុញការផ្តល់ឥណទានទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច។ ដោយសារការផ្ទុះអាវុធកម្ពុជា-ថៃនៅតែបន្តមានភាពតានតឹង ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការណែនាំឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រួលបន្ទុកដល់ជនភៀសសឹក ពលករ និងយោធិនក្នុងសមរភូមិប្រយុទ្ធ ដោយលើកលែងរាល់កម្រៃ ការផាកពិន័យ និងការទូទាត់សងការប្រាក់និងប្រាក់ដើមឥណទាន ព្រមទាំងលុបចោលឥណទានចំពោះយោធិនពិការនិងពលីក្នុងសមរភូមិប្រយុទ្ធ។ ស្របពេលនឹងការរីករាលដាលនៃបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តយ៉ាងតឹងរ៉ឹងលើវិធានការប្រុងប្រយ័ត្នចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន និងត្រៀមរួចជាស្រេចក្នុងការចាត់វិធានការចាំបាច់ ដើម្បីធានាប្រតិបត្តិការជាប្រក្រតី និងសុវត្ថិភាពសាច់ប្រាក់របស់អតិថិជន។

ជារួម ប្រព័ន្ធធនាគារនៅកម្ពុជាបន្តមានភាពធន់ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃដើមទុន និងសន្ទនីយភាព បើទោះជាប្រឈមនឹងភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល ការគំរាមកំហែងពីការផ្ទុះអាវុធតាមព្រំដែន កំណើនទាបនៃឥណទាន និងការកើនឡើងនៃឥណទានមិនដំណើរការក៏ដោយ។ ដើម្បីរក្សាបានភាពធន់និងបង្ការហានិភ័យ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់និងពង្រឹងលើការតាមដាននិងវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះជាប្រព័ន្ធ តាមរយៈការរៀបចំប្រព័ន្ធសូចនាករព្រមាន ការធ្វើស្ត្រេសតេស្ត ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្អែកលើហានិភ័យនិងទស្សនៈអនាគត ជាពិសេសហានិភ័យបច្ចេកវិទ្យា ការពង្រឹងច្បាប់និងបទប្បញ្ញត្តិឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងដាក់ចេញគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងបន្តការអនុវត្តការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ កិច្ចការពារអតិថិជន កិច្ចការពារប្រាក់បញ្ញើ និងការងារហិរញ្ញវត្ថុប្រកបដោយចីរភាពយ៉ាងសកម្ម ដើម្បីជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយតម្លាភាព បរិយាបន្ន និងចីរភាព។

## IV- ប្រព័ន្ធនិងសេវាទូទាត់សងប្រាក់

### ១- ប្រព័ន្ធទូទាត់សងប្រាក់

#### ក- ស្ថានភាពទូទៅ

ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថល ប្រព័ន្ធទូទាត់សងប្រាក់ទាំងតម្លៃរាយនិងតម្លៃធំត្រូវបានធ្វើទំនើបកម្មជាលំដាប់ ដែលបានគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនិងសមាហរណកម្មប្រព័ន្ធទូទាត់នៅក្នុងតំបន់និងអន្តរជាតិ។ ជាក់ស្តែង ការដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួមកាលពីពាក់កណ្តាលឆ្នាំ២០២៤ បានសម្រួលដល់សមាជិកនិងអតិថិជនក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ប្រាក់អន្តរគ្រឹះស្ថាន កាន់តែងាយស្រួល សុវត្ថិភាព និងឆាប់រហ័ស ព្រមទាំងបានរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបរិយាបន្នហិរញ្ញវត្ថុ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំដាក់ចេញវិធាននិងនីតិវិធីនៃប្រព័ន្ធទូទាត់សងប្រាក់រួម ព្រមទាំងឯកសារគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រកិច្ចដំណើរការប្រព័ន្ធ និងទុកជាចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិកអនុវត្ត ក៏ដូចជាកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធ និងទទួលបានទំនុកចិត្តពីសាធារណៈជន។ នាឆ្នាំ២០២៥ ប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System - IPS) មានប្រតិបត្តិការសរុបចំនួនប្រមាណ ១,២ ប៊ីលានប្រតិបត្តិការ ដែលស្មើនឹងទំហំប្រាក់ ៦,៣ ដង នៃផ.ស.ស. ស្របពេលដែលប្រតិបត្តិការប្រព័ន្ធធនាគារអេឡិចត្រូនិក (Online Banking System - OBS) មាន ៩២ ពាន់ប្រតិបត្តិការ ដែលស្មើនឹងទំហំប្រាក់ ៣,២ ដង នៃផ.ស.ស.។

សេវាទូទាត់សងប្រាក់បានវិវត្តទៅមុខគួរឱ្យកត់សម្គាល់ និងបន្តចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាហិរញ្ញវត្ថុដ៏សម្បូរបែប តាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាចំណែកមួយជំរុញឱ្យមានការប្រកួតប្រជែង និងការពង្រីកសេវាទូទាត់សងប្រាក់និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិកកាន់តែទូលំទូលាយថែមទៀត។ មធ្យោបាយអេឡិចត្រូនិកទាំងនេះ បានផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការបែបឌីជីថលដោយខ្លួនឯងបានតាមរយៈ សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងសេវាទូទាត់ចល័ត ជាពិសេស ការទូទាត់ប្រតិបត្តិការតាមយ្យអរកូត ដែលជាមធ្យោបាយដ៏ពេញនិយមនាពេលបច្ចុប្បន្ន ដែលអាចឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការអន្តរគ្រឹះស្ថាន និងផ្ទេរប្រាក់ចេញ-ចូលជាមួយបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់តាមរយៈប្រព័ន្ធបាគងបានយ៉ាងងាយស្រួល រហ័ស និងមានសុវត្ថិភាព។

បច្ចុប្បន្ន គ្រឹះស្ថានទទួលអាជ្ញាប័ណ្ណផ្តល់សេវាទូទាត់សងប្រាក់សរុបមានចំនួន ៣០ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលបានលិខិតអនុញ្ញាតផ្តល់សេវាទូទាត់សងប្រាក់មានចំនួន ៣។ គិតត្រឹមឆ្នាំ២០២៥ ចំនួនប្រតិបត្តិការនៃសេវាទូទាត់សងប្រាក់ជារៀលសរុប ១,៤ ប៊ីលានប្រតិបត្តិការ (កើនឡើង ៨៩% ធៀបនឹងឆ្នាំ២០២៤) ដែលស្មើនឹងទំហំប្រាក់ ៤៧០,៣ ទ្រីលានរៀល (កើនឡើង ២៩%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកសរុប ២,៣ ប៊ីលានប្រតិបត្តិការ (កើនឡើង ២៧%) ដែលស្មើនឹងទំហំប្រាក់ ៣៦៣,៤ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២៣%)។

## ខ- ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ក្នុងគោលបំណងកាត់បន្ថយហានិភ័យចម្បងៗ ដែលអាចនឹងកើតមានលើប្រព័ន្ធទូទាត់សងប្រាក់នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធបាគងធៀបជាមួយគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ហើយជាលទ្ធផលនៃការត្រួតពិនិត្យប្រព័ន្ធបាគងបានអនុលោមតាមគោលការណ៍ PFMI បានល្អ។ បន្ទាប់ពីបានត្រួតពិនិត្យប្រព័ន្ធបាគងរួចមក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងត្រួតពិនិត្យនិងវាយតម្លៃ NBCP ដែលមានមុខងារចម្បងក្នុងការធ្វើប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុដូចជា មូលបត្រអាចជួញដូរបាន ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ប្រតិបត្តិការជួញដូររូបិយប័ណ្ណ និងឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានតាមដាននិងត្រួតពិនិត្យលើប្រតិបត្តិការ និងឧប្បត្តិហេតុប្រព័ន្ធទូទាត់សងប្រាក់ជាប្រចាំ ព្រមទាំងកំពុងរៀបចំឯកសារផែនការនិរន្តរភាព (Business Continuity Plan) សម្រាប់ប្រព័ន្ធទូទាត់នៅកម្ពុជា ក្នុងគោលដៅការពារនិងពង្រឹងបន្ថែមលើប្រតិបត្តិការប្រចាំថ្ងៃនៃដំណើរការប្រព័ន្ធទូទាត់សងប្រាក់។

## គ- ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍនិងតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ឆ្លងដែនផ្លូវការ និងជំរុញការទូទាត់ឌីជីថល ក្នុងគោលបំណងរួមចំណែកជំរុញវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ព្រមទាំងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដោយបានតភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងក្រុមហ៊ុនបណ្តាញប័ណ្ណអន្តរជាតិ ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនទ្វេភាគី និងពហុភាគី។

### i/- កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនទ្វេភាគីតាមយូអរកូដជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ចិន ជប៉ុន និងសិង្ហបុរី ហើយគ្រោងនឹងដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនទ្វេភាគីជាមួយប្រទេសឥណ្ឌា នាពេលឆាប់ៗខាងមុខ និងបានចុះអនុស្សរណៈយោគយល់ជាមួយឥណ្ឌូណេស៊ី ហើយកំពុងពិភាក្សាតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសហ្វីលីពីនផងដែរ។ គិតត្រឹមឆ្នាំ២០២៥ ចំនួនប្រតិបត្តិការសរុបមាន ២២៦ពាន់ប្រតិបត្តិការ (កើនឡើង ៩៤%ធៀបនឹងឆ្នាំ២០២៤) ដែលស្មើនឹងទំហំប្រាក់ ១០៤ ប៊ីលានរៀល (កើន ១១៥%)។



*ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដ ដំណាក់កាលទី២ រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអន្តរជាតិ យូញៀនផេ (បាគងស្កេន UnionPay) នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*



*ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដ ដំណាក់កាលទី២ រវាងកម្ពុជា និងប្រទេសម៉ាឡេស៊ី (កម្ពុជាស្កេនម៉ាឡេស៊ី) នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី*






ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី១ រវាងកម្ពុជា និងជប៉ុន (បាគងស្កេន JPQR) នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងអូសាកា ប្រទេសជប៉ុន

ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដដំណាក់កាលទី១ រវាងកម្ពុជានិងសិង្ហបុរី (បាគងស្កេនSGQR) នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅប្រទេសសិង្ហបុរី







ពិធីចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយសក្តានុពល រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Tenpay Global នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅប្រទេសសិង្ហបុរី

ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ដំណាក់កាលទី២៖ ឡាវស្កេនខេអេចយូអរកូដ) នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ

### ii/- កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនពហុភាគី

ធនាគារជាតិនៃកម្ពុជាបានចូលរួមជាសមាជិកទី៩ ក្នុងកិច្ចសហប្រតិបត្តិការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់ (Regional Payment Connectivity-RPC) កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ ដែលជាក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ប្រទេសជាសមាជិកអាស៊ាន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន និងជំរុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក្នុងគោលដៅពន្លឿនការតភ្ជាប់ការទូទាត់ឆ្លងដែន និងបង្កើនប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែនពហុភាគីតាមរយៈការប្រើប្រាស់រូបិយវត្ថុចម្រុះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជាសមាជិកអង្កេតការណ៍ក្នុងគម្រោង NEXUS ជាគម្រោងទូទាត់ពហុភាគីដែលផ្តួចផ្តើមអភិវឌ្ឍដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS)។ ទន្ទឹមនេះ ក្នុងនាមជាសមាជិកអង្កេតការណ៍ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាផ្សព្វផ្សាយអំពី វឌ្ឍនភាពនៃការអភិវឌ្ឍគម្រោង mBridge (mBridge Outreach Meeting) និងបានចូលរួមក្នុងវគ្គចែករំលែកចំណេះដឹងនិងបទពិសោធ ព្រមទាំងពិភាក្សាបន្ថែមជាមួយអាជ្ញាធររូបិយវត្ថុហុងកុង (Hong Kong Monetary

Authority-HKMA) ពាក់ព័ន្ធនឹងការចូលរួមជាសមាជិកនៃគម្រោងនេះផងដែរ ដើម្បីស្វែងយល់បន្ថែមពីបច្ចុប្បន្នភាពនិងវឌ្ឍនភាពក្នុងការអភិវឌ្ឍគម្រោង។

### iii/- កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនជាមួយប័ណ្ណទូទាត់អន្តរជាតិ

ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់កម្មវិធីទូទាត់បាគងទេសចរ (Bakong Tourist) ជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard និង VISA ដើម្បីសម្រួលដល់ការទូទាត់របស់ភ្ញៀវទេសចរអន្តរជាតិដែលធ្វើដំណើរកម្សាន្តនៅប្រទេសកម្ពុជា ដោយផ្តល់លទ្ធភាពក្នុងការស្កេន KHQR ទូទាត់បែបឌីជីថលបានងាយស្រួលដូចប្រជាជនក្នុងស្រុក។ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការការទូទាត់ឆ្លងដែនតាមឃ្យូអរកូតជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ UnionPay International (UPI) ដើម្បីសម្រួលដល់ការទូទាត់ឆ្លងដែនរវាងប្រជាជននៃប្រទេសទាំងពីរ ដោយផ្តល់លទ្ធភាពឱ្យប្រជាជនកម្ពុជាអាចធ្វើប្រតិបត្តិការទូទាត់ឆ្លងដែនតាមរយៈការស្កេនឃ្យូអរកូតរបស់ UPI នៅក្នុងប្រទេសចិន ព្រមទាំងអនុញ្ញាតឱ្យអតិថិជនដែលប្រើប្រាស់បណ្តាញប័ណ្ណទូទាត់អន្តរជាតិ UPI អាចស្កេន KHQR សម្រាប់ទូទាត់នៅក្នុងប្រទេសកម្ពុជាបានយ៉ាងងាយស្រួលផងដែរ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយក្រុមហ៊ុន Alipay ដើម្បីសម្រួលដល់ការទូទាត់របស់អតិថិជននៃបណ្តាប្រទេសជាដៃគូរបស់ Alipay ទាំងអស់ អាចទូទាត់ថ្លៃទំនិញនិងសេវាតាមរយៈការស្កេន KHQR របស់ពាណិជ្ជករនៅក្នុងប្រទេសកម្ពុជាដែលមានគណនីជាប្រាក់រៀល។ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនទ្វេភាគីជាមួយប្រទេសចិនឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ធនាគារជាតិនៃកម្ពុជាកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន TenPay Global ក្នុងគោលបំណងបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការរួមគ្នាជំរុញអន្តរប្រតិបត្តិការរវាងប្រព័ន្ធបាគង (KHQR) របស់ប្រទេសកម្ពុជា និងបណ្តាញទូទាត់ចល័ត Weixin Pay របស់ប្រទេសចិន។






*ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ (Bakong Tourist App) ជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Visa នាព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា សែនសុខ*

### iv/- កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្មឆ្លងដែន

ធនាគារជាតិនៃកម្ពុជានិងអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានប្រកាសដាក់ឱ្យដំណើរការនូវគម្រោង Financial Transparency Corridor (FTC) កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុន រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃគម្រោងនេះនៅប្រទេសទាំងពីរ ដើម្បីសម្រួលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ក្នុងការធ្វើសកម្មភាពពាណិជ្ជកម្មនិងហិរញ្ញវត្ថុឆ្លងដែនកាន់តែពិលាស។

បច្ចុប្បន្ន ភាគីកម្ពុជាមានគ្រឹះស្ថានចំនួន ៧ បានចូលរួមជាសមាជិកនៃគម្រោងនេះ រួមមាន ធនាគារអេស៊ីលីដា ស្ថាបនា ហ្វីលីព វីង វឌ្ឍនៈអាស៊ីចំកាត់ អេសប៊ីអាយ លីហ្ស និងពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និងភាគីសិង្ហបុរី មានចំនួន ៣ គ្រឹះស្ថាន រួមមាន ANEXT Bank, Liquid Group និង Sing Investment and Finance ហើយគ្រឹះស្ថានទាំងនោះបាននិងកំពុងតភ្ជាប់ប្រព័ន្ធជាមួយក្រុមហ៊ុន Proxtera។

ធនាគារជាតិនៃកម្ពុជាក្នុងនាមជាសហប្រធាន (Co-chair) ជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត បានចាប់ផ្តើមគម្រោងដំណើរការសាកល្បងគម្រោង Universal Trusted Credentials (UTC) នៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ ដើម្បីផ្តល់នូវថ្នាលទិន្នន័យ និងក្របខណ្ឌទិន្នន័យជាក់លាក់មួយសម្រាប់ MSMEs និងចូលរួមដោះស្រាយបញ្ហាប្រឈមមួយចំនួនដែល MSMEs បាននិងកំពុងជួបប្រទះ។ បច្ចុប្បន្ន ថ្នាល UTC កំពុងត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុនបច្ចេកទេស DFINITY Foundation និងបានដាក់បង្ហាញសាកល្បងជាមួយគ្រឹះស្ថានជាសមាជិក ហើយគ្រោងនឹងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៦។

ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងសិក្សាស្វែងយល់ជាមួយអាជ្ញាធររូបិយវត្ថុហុងកុង (HKMA) ពាក់ព័ន្ធនឹងគម្រោង Ensemble ដែលជាគម្រោងអភិវឌ្ឍក្របខណ្ឌអន្តរប្រតិបត្តិការសម្រាប់ប្រាក់បញ្ញើតូខិន (Tokenized Deposits) ដែលបានកំពុងប្រើប្រាស់លើប្រធានបទចំនួន ៤ រួមមាន មូលនិធិចំណូលថេរ និងការវិនិយោគ (Fixed-income and Investment Funds) ការគ្រប់គ្រងសន្ទនីយភាព (Liquidity Management) ហិរញ្ញវត្ថុបៃតងនិងចីរភាព (Green and Sustainable Finance) និងពាណិជ្ជកម្ម/ហិរញ្ញវត្ថុខ្សែច្រវាក់ផ្គត់ផ្គង់ (Trade and Supply Chain Finance)។

### ឃ- នវានុវត្តន៍ហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបានបន្តជំរុញនិងអភិវឌ្ឍមុខងារបន្ថែមក្នុងប្រព័ន្ធបាគងប្រកបដោយនវានុវត្តន៍ដោយបានអភិវឌ្ឍ៖

**-មុខងារសម្រួលការទូទាត់វិក្កយបត្រ (Bill Payment)៖** ធនាគារជាតិនៃកម្ពុជាកំពុងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីអភិវឌ្ឍមុខងារទូទាត់តាមខេអេចយ្យូអរកូតនៅលើវិក្កយបត្រដោយផ្ទាល់ដូចជាវិក្កយបត្រសម្រាប់បង់ថ្លៃទឹក ភ្លើង និងប្រព័ន្ធបង់ប្រាក់ចំណតរថយន្តនៅអាកាសយានដ្ឋានអន្តរជាតិតេជោជាដើម ដែលនឹងសម្រួលដល់ការទូទាត់វិក្កយបត្របែបឌីជីថលជូនដល់សាធារណជន និងស្ថាប័នក្នុងវិស័យសាធារណៈ។

**-មុខងារស្វែងរកព័ត៌មានរបស់សាធារណជន (Information)៖** ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងសុខាភិបាល ក្នុងការស្វែងរកព័ត៌មាននៃការចាក់វ៉ាក់សាំងកូវីដ-១៩ និងកំពុងសិក្សាលទ្ធភាពបន្ថែមក្នុងកិច្ចសហការជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំដៅផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់កម្មវិធីបាគងអាចឆែកមើលទិន្នន័យព័ត៌មានផ្ទាល់ខ្លួនសម្រាប់ចូលរួមការបោះឆ្នោតបានយ៉ាងងាយស្រួល និងឆាប់រហ័ស។

**-មុខងារតភ្ជាប់គណនីធនាគារ (Linking Account)៖** ការតភ្ជាប់គណនីធនាគារជាមួយកម្មវិធីទូទាត់បាគង គឺជាមធ្យោបាយដាក់ប្រាក់បន្ថែមមួយទៀតនៅក្នុងកម្មវិធីទូទាត់បាគង ដែលអតិថិជនអាចតភ្ជាប់គណនីបាគងរបស់ខ្លួន ជាមួយគណនីរបស់គ្រឹះស្ថានធនាគារដោយផ្ទាល់ ដោយគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកចំនួន ៣២ បានធ្វើសន្ធានកម្មរួចរាល់។

**-មុខងារទូទាត់ប្រាក់ដោយមិនត្រូវការអ៊ីនធឺណិត (Bakong Offline)៖** ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលទ្ធភាពអភិវឌ្ឍមុខងារទូទាត់សងប្រាក់ដោយពុំត្រូវការអ៊ីនធឺណិត ដើម្បីសម្រួលដល់ការទូទាត់និងទទួលប្រាក់ប្រចាំថ្ងៃរបស់សាធារណជន និងពាណិជ្ជករទូទាំងប្រទេសកម្ពុជា។

**-ច្រកទូទាត់ (Payment Gateway)៖** ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធដោយផ្ដល់លទ្ធភាពជាច្រកទូទាត់ និងប្រមូលចំណូលជូនដល់ក្រសួង-ស្ថាប័នក្នុងវិស័យសាធារណៈដោយបានសហការអភិវឌ្ឍប្រព័ន្ធជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រួលដល់ការទូទាត់កម្រៃសេវាច្រកចេញ-ចូលតែមួយ សហការជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការអភិវឌ្ឍផ្លែតហ្វម Cambodia Trade ឱ្យមានលទ្ធភាពទទួលការទូទាត់រវាងអតិថិជននិងអាជីវករដែលចុះឈ្មោះប្រើប្រាស់និងធ្វើពាណិជ្ជកម្មនៅក្នុងផ្លែតហ្វម និងសហការជាមួយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដើម្បីសម្រួលដល់ការទូទាត់របស់សាធារណជនដែលប្រើប្រាស់សេវារបស់ក្រសួង។

**-មុខងារផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង (Bakong e-KYC)៖** ធនាគារជាតិនៃកម្ពុជាបានផ្ដួចផ្ដើមនិងកំពុងធ្វើនវានុវត្តន៍បន្ថែមទៅលើប្រព័ន្ធបាគង ដោយប្រើប្រាស់មុខងារផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង (Bakong e-KYC) ដែលមុខងារបន្ថែមនេះនឹងអនុញ្ញាតឱ្យគ្រឹះស្ថានដែលជាសមាជិកបាគងទាំងអស់អាចប្រើប្រាស់ទិន្នន័យសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនរបស់ខ្លួនតាមរយៈប្រព័ន្ធ Bakong e-KYC បានយ៉ាងឆាប់រហ័ស សុវត្ថិភាព និងប្រកបដោយទំនុកចិត្ត។

**-បាគងទេសចរ (Bakong Tourist)៖** ធនាគារជាតិនៃកម្ពុជាបានរួមចំណែកលើកស្ទួយវិស័យទេសចរណ៍នៅកម្ពុជា ដោយបានដាក់ឱ្យដំណើរការជាបឋមកម្មវិធីទូទាត់បាគងទេចរ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយភ្ញៀវទេសចរដែលមកកម្ពុជា អាចទាញយកកម្មវីធីបាគងទេសចរនិងភ្ជាប់ជាមួយប័ណ្ណទូទាត់អន្តរជាតិដូចជា Mastercard និង VISA ដើម្បីទូទាត់ទំនិញនិងសេវាផ្សេងៗជាមួយខេអេចឃ្យូអរកូតរបស់ពាណិជ្ជករទូទាំងប្រទេសកម្ពុជាប្រកបដោយភាពងាយស្រួល និងសុវត្ថិភាពខ្ពស់។

**-បាគងយុវជន (Bakong Junior)៖** ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍនិងដាក់ឱ្យដំណើរការសាកល្បងកម្មវិធីទូទាត់បាគងយុវជន ព្រមទាំងបានស្នើសុំកិច្ចសហការពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្សព្វផ្សាយនិងជំរុញឱ្យសិស្សានុសិស្សប្រើប្រាស់កម្មវិធីបាគងយុវជននេះឱ្យកាន់តែច្រើន ហើយសិស្សានុសិស្សដែលមានអាយុក្រោម ១៥ឆ្នាំ អាចប្រើប្រាស់ប័ណ្ណសម្គាល់ខ្លួនជាសិស្សក្នុងការចុះឈ្មោះប្រើប្រាស់កម្មវិធីបាគងយុវជន ដើម្បីអាចទទួលបានបទពិសោធប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលរួមមាន ការសន្សំ ការផ្ទេរប្រាក់រវាងគណនីបាគងយុវជននិងគណនីបាគង និងការទូទាត់ប្រាក់តាមរយៈការស្កេនខេអេចឃ្យូអរកូត។

## ខ- គោលនយោបាយគាំទ្រ

ដើម្បីចូលរួមលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្ន និងផ្ដល់ភាពងាយស្រួលដល់អាជីវករដែលទទួលការទូទាត់ពីភ្ញៀវទេសចរ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្ដីណែនាំស្ដីពី "ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ពាណិជ្ជករ" កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ ដោយតម្រូវឱ្យគ្រឹះស្ថានអនុវត្តខេអេចឃ្យូ-អរកូតរួម (Combined KHQR) សម្រាប់ពាណិជ្ជករ និងផ្ដល់អាទិភាពធ្វើប្រតិបត្តិការទូទាត់សងប្រាក់ជារៀល ព្រមទាំងអភិវឌ្ឍមុខងារលើកម្មវិធីសេវាធនាគារចល័ត ដោយកំណត់យកប្រាក់រៀលជា

គណនីគោល។ ខ្លឹមសារនៃសេចក្តីណែនាំនេះក៏ជំរុញអតិថិជនដែលប្រកបអាជីវកម្ម មុខរបរ និង/ឬ ការងារដែលជាសកម្មភាពស្របច្បាប់ឱ្យចុះបញ្ជីតាមបណ្តាញសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ព្រមទាំងបង្កើតគណនីនិងខេអេចយ្យូអរកូតពាណិជ្ជករ ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល។

ក្នុងគោលបំណងពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីបញ្ហារអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់តាមរយៈកម្មវិធីធនាគារចល័ត/កម្មវិធីទូទាត់ចល័ត និងបណ្តាញសេវាធនាគារនានា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទូទាត់សងប្រាក់របស់សាធារណជន ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសេចក្តីណែនាំស្តីពី ការពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីភាពរអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ជូនសាធារណជន កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥។ ខ្លឹមសារនៃសេចក្តីណែនាំ តម្រូវឱ្យគ្រឹះស្ថានជូនដំណឹង ពីរបាយការណ៍ឧប្បត្តិហេតុនៃការទូទាត់ ដល់ក្រុមការងារធនាគារជាតិនៃកម្ពុជា ដើម្បីតាមដាន សម្របសម្រួល និងដោះស្រាយបញ្ហា។

កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការលើការជំរុញបរិវត្តកម្មឌីជីថល និងការផ្ទៀងផ្ទាត់អត្តសញ្ញាណស៊ីមកាតជាមួយនឹងគណនីធនាគារ/គណនីទូទាត់សងប្រាក់របស់អ្នកប្រើប្រាស់ ដើម្បីពង្រឹងសុវត្ថិភាព ព័ត៌មានអត្តសញ្ញាណអតិថិជន សំដៅទប់ស្កាត់បទល្មើសឆបោកដោយបន្លំអត្តសញ្ញាណ និងជំរុញការធ្វើបរិវត្តកម្ម និងនវានុវត្តន៍ឌីជីថលក្នុងវិស័យធនាគារ និងវិស័យទូរគមនាគមន៍ ។

អនុលោមតាមផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០២០-២០២៥ ដែលបានដាក់ចេញកាលពីឆ្នាំ២០២០កន្លងទៅ ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ដោយបានអនុវត្តនូវវិធានការគន្លឹះសំខាន់ មានដូចជាការរៀបចំក្របខណ្ឌបទប្បញ្ញត្តិនិងគោលនយោបាយសំខាន់ៗជាមួយស្ថាប័នពាក់ព័ន្ធ ព្រមទាំងបានបង្កើតក្រុមការងារចូលរួមអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឱ្យមានសន្ទុះកាន់តែខ្លាំង។ ទន្ទឹមនឹងនោះដើម្បីឆ្លើយតបទៅនឹងនិន្នាការវិវត្តន៍ថ្មីៗនៃប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងតំបន់ និងសកល ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងរៀបចំធ្វើបច្ចុប្បន្នកម្មផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ បន្តឆ្ពោះទៅឆ្នាំ២០២៦-២០៣០ ដោយកំណត់នូវគោលនយោបាយអាទិភាពសំខាន់ៗដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ដោយក្នុងនោះរួមមានក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យនិងការចែករំលែកទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ សេវាធនាគារឌីជីថល ក្របខណ្ឌធនាគារបើកចំហ ការប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី បញ្ញាសិប្បនិម្មិត អត្តសញ្ញាណឌីជីថល ក្របខណ្ឌសន្តិសុខសាយប័រ និង Quantum Computing ព្រមទាំងគោល-នយោបាយផ្សេងៗទៀត។

ជាមួយគ្នានេះ ក្នុងគោលដៅលើកកម្ពស់ចំណេះដឹងផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានរៀបចំយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលដល់សាធារណជន និងរៀបចំវេទិការបច្ចេកវិទ្យាហិរញ្ញវត្ថុផ្សព្វផ្សាយអំពីកាលានុវត្តន៍ភាពថ្មី ព្រមទាំងគំនិតផ្តួចផ្តើមផ្សេងទៀតដើម្បីលើកកម្ពស់ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារឱ្យកាន់តែមានសក្តានុពលថែមទៀត។

## ២- សេវាទូទាត់សងប្រាក់

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជា ចែកជា ២ គឺ ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS) និងប្រព័ន្ធទូទាត់សងប្រាក់រួម។

**i/- ប្រព័ន្ធធនាគារអេឡិចត្រូនិក** (OBS)៖ ប្រព័ន្ធ OBS មានសមាជិកចំនួន ៨៧ ដែលក្នុងនោះមានធនាគារពាណិជ្ជ ៥៧ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៤គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៨និងស្ថាប័នរដ្ឋ ២ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS សរុបមាន ៩២,៩ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ៦២២,៣ ទ្រីលានរៀល (កើន ២២,៦% ធៀបនឹងឆ្នាំមុន)។ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលជារៀលតាមប្រព័ន្ធ OBS មាន ៥៩,៤ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ១៦១,៨ ទ្រីលានរៀល (កើន ២១,៦%) និងជាដុល្លារអាមេរិកមាន ៣២,៤ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ១០៥,៥ ប៊ីលានដុល្លារអាមេរិក (កើន ២២,៩%)។ ទន្ទឹមនេះ ការផ្ទេរប្រាក់ជាមួយសាខាធនាគារជាតិនៃកម្ពុជាជារៀលតាមប្រព័ន្ធ OBS មាន ៧០៧ ប្រតិបត្តិការ ដែលស្មើនឹង ៨,២ ទ្រីលានរៀល (កើន ៣២,២%) និងជាដុល្លារអាមេរិកមាន ៣៨៣ ប្រតិបត្តិការ ដែលស្មើនឹង ៤,៨ ប៊ីលានដុល្លារអាមេរិក (កើន ២០,៥%)។ នាឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍមុខងារបន្ថែមលើប្រព័ន្ធ OBS ក្នុងគោលបំណងសម្រួលដល់ការទូទាត់របស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព និងរហ័សជាងមុន។

**ក្រាហ្វ ៧០៖ ការផ្ទេរប្រាក់រៀលតាមប្រព័ន្ធ** OBS
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧១៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមប្រព័ន្ធ** OBS
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ii/- **ប្រព័ន្ធទូទាត់សងប្រាក់រួម៖** ប្រព័ន្ធនេះចែកចេញជា ២ម៉ូឌុល គឺ ម៉ូឌុលបាគង និង ម៉ូឌុលទូទាត់សុទ្ធ។

- **ម៉ូឌុលបាគង** មានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ (Bakong LVPS)។

សេវាទូទាត់បាគងមានសមាជិកចំនួន ៦៣ កំពុងដំណើរការជាផ្លូវការ និងចំនួន ៧ កំពុងធ្វើសន្ធានកម្មប្រព័ន្ធ។ នាឆ្នាំ២០២៥ នេះ សេវាទូទាត់បាគងមានប្រតិបត្តិការជារៀល ៧៧១,២ លានប្រតិបត្តិការ (កើន ១,៦ ដង ធៀបនឹងឆ្នាំមុន) ដែលស្មើនឹង ២៨៥,៩ ទ្រីលានរៀល (កើន ៥៩,៤%) និងប្រតិបត្តិការជាដុល្លារអាមេរិក ៥៥៤,៥ លានប្រតិបត្តិការ (កើន ៧៩,៧%) ដែលស្មើនឹង ១៥២,៨ ប៊ីលានដុល្លារអាមេរិក (កើន ៤៩,៣%)។

**ក្រាហ្វ ៧២៖ ការទូទាត់ជារៀលតាមសេវាទូទាត់បាគង**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៣៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាទូទាត់បាគង**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សេវាទូទាត់បាគងតម្លៃធំ មានសមាជិកចំនួន ៤៨ កំពុងប្រើប្រាស់។ នាឆ្នាំ២០២៥ នេះ សេវាទូទាត់បាគងតម្លៃធំមានប្រតិបត្តិការជារៀល ១,៦ ពាន់ប្រតិបត្តិការ (កើន ១,២ ដង ធៀបនឹង ៨ខែ ឆ្នាំ២០២៤[៣៤]) ស្មើនឹង ៣,២ ទ្រីលានរៀល (កើន ៧,៣ ដង) និងប្រតិបត្តិការជាដុល្លារអាមេរិក ១១,១ ពាន់ប្រតិបត្តិការ (កើន ២,៣ ដង) ស្មើនឹង ២,១ ប៊ីលានដុល្លារអាមេរិក (កើន ២,៧ ដង)។

**ក្រាហ្វ ៧៤៖ ការទូទាត់ប្រាក់រៀលតាមសេវាទូទាត់បាគងតម្លៃធំ**
(ខែឧសភា-ខែធ្នូ ឆ្នាំ២០២៤ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៥៖ ការទូទាត់ប្រាក់ដុល្លារអាមេរិកតាមសេវាទូទាត់បាគងតម្លៃធំ**
(ខែឧសភា-ខែធ្នូ ឆ្នាំ២០២៤ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣៤] សេវាទូទាត់បាគងតម្លៃធំត្រូវបានដាក់ដំណើរការជាផ្លូវការចាប់ពីខែឧសភា ឆ្នាំ២០២៤។

- **ម៉ូឌុលទូទាត់សុទ្ធ** មានសេវាទូទាត់មូលប្បទានប័ត្រ និងសេវាប័ណ្ណទូទាត់។

សេវាទូទាត់មូលប្បទានប័ត្រមានសមាជិកសរុបចំនួន ៦០ ដែលក្នុងនោះសមាជិកផ្ទាល់ ៤៩ និងសមាជិកមិនផ្ទាល់ ១១។ ការទូទាត់មូលប្បទានប័ត្រចារឹកជារៀលមាន ៣០,២ ពាន់សន្លឹក (ថយ -៧,៧% ធៀបនឹងឆ្នាំមុន) ដែលស្មើនឹង ២៥,៤ ទ្រីលានរៀល (កើន ១៧,៨%) ស្របពេលដែលជាដុល្លារអាមេរិកមាន ៩៩៣,៤ ពាន់សន្លឹក (ថយ -២,១%) ដែលស្មើនឹង ៥២,២ ប៊ីលានដុល្លារអាមេរិក (ថយ -៩,៤%)។

**ក្រាហ្វ ៧៦៖ ការទូទាត់ជារៀលតាមសេវាទូទាត់មូលប្បទានប័ត្រ**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៧៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាទូទាត់មូលប្បទានប័ត្រ**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សេវាប័ណ្ណទូទាត់មានសមាជិកចំនួន ៥០ (សមាជិកផ្ទាល់ ៤៦ និងសមាជិកមិនផ្ទាល់ ៤) កំពុងប្រើប្រាស់សេវាប័ណ្ណទូទាត់ និងគ្រឹះស្ថានចំនួន ៧ កំពុងធ្វើសន្ធានកម្មប្រព័ន្ធ។ សេវាប័ណ្ណទូទាត់បានដំណើរការទូទាត់ប្រតិបត្តិការជាប្រាក់រៀលចំនួន ៧៦,៩ ពាន់ប្រតិបត្តិការ (ថយ -៥៣,១% ធៀបនឹងឆ្នាំមុន) ដែលស្មើនឹង ១៨,៧ ប៊ីលានរៀល (ថយ -៤៧,៦%) ស្របពេលដែលជាដុល្លារអាមេរិក មាន ១៣,៧ ពាន់ប្រតិបត្តិការ (ថយ -៥៩,៥%) ដែលស្មើនឹង ១,៩ លានដុល្លារអាមេរិក (ថយ -៥៨,៩%)។

**ក្រាហ្វ ៧៨៖ ការទូទាត់ជារៀលតាមសេវាប័ណ្ណទូទាត់**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៩៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាប័ណ្ណទូទាត់**
(ឆ្នាំ២០២០ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជារួម នាឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលនយោបាយគាំទ្រខាងលើ ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានប្រសិទ្ធភាព ពង្រឹងនីតិវិធីនៃការជូនដំណឹងអំពីបញ្ហារអាក់រអួលពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់ និងកសាងមូលដ្ឋានគ្រឹះក្នុងការចាប់យកឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទិសដៅគោលនយោបាយថ្មីៗក៏មានបំណងបង្កើនតម្លាភាពក្នុងប្រព័ន្ធសេវាទូទាត់សងប្រាក់ និងជំរុញឱ្យមានការគ្រប់គ្រងហានិភ័យប្រសើរឡើង។ ការផ្តោតលើការអប់រំបណ្តុះបណ្តាលឌីជីថលសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និងប្រជាជនក៏ត្រូវបានពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធានាថាការចូលរួមក្នុងប្រព័ន្ធទូទាត់ឌីជីថលកាន់តែទូលំទូលាយ។

## V- ការផ្ដត់ផ្គង់សេវាធនាគារកណ្ដាល

### ១- សេវាគ្រប់គ្រងគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីសរុបចំនួន ២.៩៤១ ដែលក្នុងនោះ នៅស្នាក់ការកណ្ដាលមាន ២.២១៨ គណនី និងតាមបណ្ដាសាខាធនាគារជាតិនៃកម្ពុជាមាន ៧២៣ គណនី។ គណនីសរុបបានកើនឡើង ៥៥[៣៥] គណនី ធៀបនឹងឆ្នាំមុន ដោយសារការបើកគណនីថ្មីជូនអង្គភាពថវិការបស់ក្រសួង-ស្ថាប័នរដ្ឋ និងគណនីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ប្រាក់បញ្ញើជារៀលរបស់ស្ថាប័នរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗ នៅធនាគារជាតិនៃកម្ពុជា ទាំងនៅស្នាក់ការកណ្ដាល និងតាមបណ្ដាសាខាធនាគារជាតិនៃកម្ពុជាបានកើនឡើងចំនួន ៣ ទ្រីលានរៀល (កើន ២៥,៣%) ខណៈដែលប្រាក់បញ្ញើជាដុល្លារអាមេរិកថយចុះចំនួន ០,៤ ប៊ីលានដុល្លារអាមេរិក (ថយ -២,៦%) ធៀបនឹងឆ្នាំមុន។

ការផ្ទេរប្រាក់សរុប គិតជាប្រាក់រៀល មានចំនួន ៦៧៦,២ ទ្រីលានរៀល ក្នុងនោះការផ្ទេរប្រាក់ក្នុងប្រទេសមានចំនួន ៦៣៩,៧ ទ្រីលានរៀល និងការផ្ទេរប្រាក់ក្រៅប្រទេសមានចំនួន ៣៦,៥ ទ្រីលានរៀល (៩,១ ប៊ីលានដុល្លារអាមេរិក)។

### ២- សេវាគ្រប់គ្រងមូលបត្រ

#### ក- តួនាទីជាអាណត្តិគាហកសម្រាប់ការបោះផ្សាយមូលបត្ររដ្ឋ

ក្នុងឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ដោយបានសម្របសម្រួលដល់ការបោះផ្សាយមូលបត្ររដ្ឋជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១១ លើក ក្នុងទំហំទឹកប្រាក់សរុប ៤១០,៣ ប៊ីលានរៀល និង ៧០ លានដុល្លារអាមេរិក។ ទន្ទឹមនេះ ការទូទាត់គូប៉ុងសរុបមានចំនួន ៤០ លើក និងទូទាត់ប្រាក់ដើមចំនួន ៦ លើក។

**ក្រាហ្វ ៤០៖ មូលបត្ររដ្ឋជាប្រាក់រៀល**

(គិតជាប៊ីលានរៀល, ឆ្នាំ២០២២ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣៥] បានបើកសរុប ២៤៦ គណនី និងបិទសរុប ១៩១ គណនី។

មូលបត្ររដ្ឋឥណប្រតិទាន ១ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ២,៧៥% និងអត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម ៣,១៥% ឥណប្រតិទាន ២ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៣,២០% ឥណប្រតិទាន ៣ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៣,៤៨% និងអត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម ៣,៩៩% ឥណប្រតិទាន ៥ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៤,២១% និងអត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម ៤,៥% ហើយ ឥណប្រតិទាន ១០ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៤,៦០%។

**ក្រាហ្វ ៤១៖ អត្រាគូប៉ុងជាមធ្យម**
(គិតជាភាគរយ, ឆ្នាំ២០២២ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤២៖ អត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម**
(គិតជាភាគរយ, ឆ្នាំ២០២២ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានសម្របសម្រួលឱ្យគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដែលជាអន្តរការីមូលបត្ររដ្ឋចំនួន ១ (ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ស៊ីឃ្យូរីធី ម.ក) ចូលជាសមាជិកផ្ទាល់ NBCP ហើយបានចូលរួមដេញថ្លៃមូលបត្ររដ្ឋដោយជោគជ័យកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ នៃការបោះផ្សាយលក់មូលបត្ររដ្ឋលើកទី៣៩។ ទន្ទឹមនេះ ក្រុមការងារមូលបត្ររដ្ឋ នៃធនាគារជាតិនៃកម្ពុជា ក៏បានជួបពិភាក្សាការងារជាមួយអន្តរការីមូលបត្ររដ្ឋចំនួន ១ និងបានចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកម្មវិធីផ្សព្វផ្សាយលក់មូលបត្ររដ្ឋដល់វិនិយោគិនសក្តានុពលចំនួន ២ដង ដើម្បីបន្តជំរុញការចូលរួមបន្ថែមពីបណ្តាវិនិយោគិន។

## ខ- ការគ្រប់គ្រងប័ណ្ណសងតាមបញ្ជា

ប័ណ្ណសងតាមបញ្ជាដែលរាជរដ្ឋាភិបាលបានចេញផ្សាយជូនធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ត្រូវបានរក្សាទុកក្នុងគណនីបញ្ញើប័ណ្ណសងតាមបញ្ជា (Custodian Account) នៅធនាគារជាតិនៃកម្ពុជា។ ការគ្រប់គ្រងប័ណ្ណសងតាមបញ្ជា រួមមានការតាមដានព័ត៌មានគណនី និងសម្របសម្រួលការទូទាត់តាមការស្នើសុំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។ នាឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជាបានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបានទូទាត់ជូនធនាគារអភិវឌ្ឍន៍អាស៊ី លើប័ណ្ណសងតាមបញ្ជាដែលបានចេញផ្សាយកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ចំនួន ៦,៩ លានរៀល និងប័ណ្ណសងតាមបញ្ជាដែលបានចេញផ្សាយកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ ចំនួន ២១៣,១ លានរៀល។

## ៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

ដើម្បីបំពេញតម្រូវការរបស់សេដ្ឋកិច្ច សាធារណជន និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍ និងផ្គត់ផ្គង់ធនបត្រថ្មីគ្រប់ប្រភេទទៅក្នុងទីផ្សារ និងប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែកជាប្រចាំ។

នាឆ្នាំ២០២៥ ការទទួល និងការបើកប្រាក់រៀលមានចំនួន ១៩,៧ ទ្រីលានរៀល (កើន ០,២%) និង ២១,៦ ទ្រីលានរៀល (កើន ១២,៣%) រៀងគ្នា។ ចំណែកឯការទទួល និងការបើកប្រាក់ដុល្លារអាមេរិក មានចំនួន ១៧,៧ ប៊ីលានដុល្លារអាមេរិក (កើន ៣,៧%) និង ៩,៨ ប៊ីលានដុល្លារអាមេរិក (កើន ៣៩%) រៀងគ្នា។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំយុទ្ធនាការប្តូរប្រាក់ចាស់ ទក់ រហែក នៅទូទាំងប្រទេស ដែលបានផ្ទេរប្រាក់ចូលគណនីបាគងរបស់ប្រជាពលរដ្ឋចំនួន ៤.៥១៩ ប្រតិបត្តិការ ដែលមានទឹកប្រាក់ចំនួន ៣,៦ ប៊ីលានរៀល និងប្តូរក្រដាសប្រាក់ថ្មីជូនប្រជាពលរដ្ឋចំនួន ៧,៣ ប៊ីលានរៀល។

**ក្រាហ្វ ៨៣៖ ការទទួលនិងការបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២១ - ឆ្នាំ២០២៥)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៤៖ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២១ - ឆ្នាំ២០២៥)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តមានចំនួន ៥,៧ ទ្រីលានរៀល បានកើនឡើង ៨៩% ធៀបនឹងឆ្នាំ២០២៤ រីឯការដឹកជញ្ជូនក្រដាសប្រាក់រៀលចាស់ ទក់ រហែក និងសាច់ប្រាក់លើសពីតម្រូវការមកស្នាក់ការកណ្តាលវិញមានចំនួន ៥,៨ ទ្រីលានរៀល បានថយចុះ -៥%។ ទន្ទឹមនេះ ការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានចំនួន ៥៩១ លានដុល្លារអាមេរិក ដែលបានកើនឡើង ៦៨,៩% និងការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្តាលវិញ មានចំនួន ៥,៥ ប៊ីលានដុល្លារអាមេរិកបានកើនឡើង ២០%។

**ក្រាហ្វ ៨៥៖ ប្រាក់រៀលដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**

(គិតជាប៊ីលានរៀល, ឆ្នាំ២០២១-២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៦៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២១-២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា





*ការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក និងខូច ជូនសាធារណជននៅបណ្តារាជធានី-ខេត្ត តាមរយៈប្រព័ន្ធបាគង*

ជារួម ចរាចរណ៍ធនបត្រ ត្រូវបានបន្តគ្រប់គ្រង និងពង្រឹងប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់អន្តរការិយកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តម្រូវការសាច់ប្រាក់របស់រាជរដ្ឋាភិបាល និងសម្រួលដល់ការទូទាត់ទំនិញនិងសេវា ស្របតាមការរីកចម្រើនរបស់សេដ្ឋកិច្ចជាតិ។ ការណ៍នេះបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃតម្រូវការសាច់ប្រាក់ជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

## VI- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ស.ហ.ក. បានបន្តពង្រឹងការអនុវត្តច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកបដោយការទទួលខុសត្រូវលើការងារត្រួតពិនិត្យបុគ្គលរាយការណ៍ ការងារវិភាគប្រតិបត្តិការ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងការពង្រឹងសមត្ថភាពនិងលើកកម្ពស់ការយល់ដឹងដល់ភាគីពាក់ព័ន្ធ។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី៦០ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា*

ក្រុមប្រឹក្សាភិបាលនៃ ស.ហ.ក. បានបើកកិច្ចប្រជុំចំនួន ៤ លើក ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងាររបស់ ស.ហ.ក. និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ និងការត្រៀមលក្ខណៈរបស់កម្ពុជា សម្រាប់ការវាយតម្លៃអញ្ញមញ្ញឆ្នាំ២០២៨-២០២៩។

ស.ហ.ក. បានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នក្នុងការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ លើកទី២ និងបានបញ្ចប់ការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ជាមួយគ្នានេះ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) បានពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២នេះ នាកិច្ចប្រជុំ គ.ស.ហ. កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ហើយរបាយការណ៍នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈនាពេលខាងមុខ។





*កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ នៅទីស្តីការក្រសួងយុត្តិធម៌*

## ១- ការត្រួតពិនិត្យបុគ្គលរាយការណ៍

ក្នុងឆ្នាំនេះ ស.ហ.ក. បានត្រួតពិនិត្យដល់ទីកន្លែង ចំពោះបុគ្គលរាយការណ៍សរុបចំនួន ៤៣ រួមមាន៖ ធនាគារពាណិជ្ជចំនួន ៨ ធនាគារឯកទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ២ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ២ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ចំនួន ២ ក្រុមហ៊ុនប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ៤ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ២ ក្រុមហ៊ុនមូលបត្រចំនួន ២ ក្រុមហ៊ុនបរធនបាលកិច្ចចំនួន ១ ក្រុមហ៊ុនអចលនវត្ថុចំនួន ៧ និងកាស៊ីណូចំនួន ១០ ដោយបានផ្តល់អនុសាសន៍កែតម្រូវមួយចំនួន។ ទន្ទឹមនេះ ស.ហ.ក. បានអនុវត្តការត្រួតពិនិត្យលើឯកសារជាប្រចាំ តាមរយៈ៖ i/- ការបន្តតាមដានវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែង ii/- លទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង iii/- លទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង។

ជាមួយគ្នានេះ ស.ហ.ក. បានវាយតម្លៃនិងទទួលស្គាល់គុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិចំនួន ១១០រូប មកពីធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនវត្ថុ ក្រុមហ៊ុនបរធនបាលកិច្ច និងកាស៊ីណូ។

ក្រៅពីនេះ ស.ហ.ក. បាននិងកំពុងរៀបចំឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់វិស័យអចលនវត្ថុ វិស័យកាស៊ីណូ និងវិជ្ជាជីវៈច្បាប់ ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរត្រួតពិនិត្យក្នុងការប្រមូលព័ត៌មាន ទិន្នន័យ និងសារតារបស់បុគ្គលរាយការណ៍ ដែលជាធាតុចូលដ៏មានសារៈសំខាន់ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់សារតារហានិភ័យ។ ទន្ទឹមនេះ ស.ហ.ក. បាននិងកំពុងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជួយសម្រួលដល់ការងារត្រួតពិនិត្យបុគ្គលរាយការណ៍ឱ្យកាន់តែមានប្រសិទ្ធភាព។

## ២- ការវិភាគប្រតិបត្តិការ

ស.ហ.ក. បានបន្តតាមដានជាប្រចាំនូវការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ស្របតាមមាត្រា ១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០២០។ នាឆ្នាំ២០២៥ ការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់កើនឡើង ១២,១%[៣៦] និងការរាយការណ៍ប្រតិបត្តិការសង្ស័យកើនឡើង ១៧,២%[៣៧] បើធៀបនឹងឆ្នាំ២០២៤។ ទន្ទឹមនេះ ស.ហ.ក. បានរៀបចំកិច្ចប្រជុំជាមួយបុគ្គលរាយការណ៍ ដែលបានស្នើសុំភ្ជាប់ប្រព័ន្ធរាយការណ៍ចំនួន ៧៨ ដើម្បីណែនាំបុគ្គលរាយការណ៍ទាំងនោះឱ្យយកចិត្តទុកដាក់អនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាពិសេសការរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់។ ស.ហ.ក. បានរៀបចំ និងចែករំលែករបាយការណ៍វិភាគយុទ្ធសាស្ត្រចំនួន ៣ ដែលបង្ហាញអំពីនិន្នាការថ្មីៗនៃការសម្អាតប្រាក់ ជូនអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ។ ជាមួយគ្នាផងដែរ ស.ហ.ក. បាននិងកំពុងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជួយសម្រួលដល់ការងារវិភាគប្រតិបត្តិការហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព។

---

[៣៦] ទិន្នន័យព្យាករណ៍ខែធ្នូ ដោយគណនាមធ្យមភាគនៃ CTR ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៥។

[៣៧] ទិន្នន័យព្យាករណ៍ខែធ្នូ ដោយគណនាមធ្យមភាគនៃ STR ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៥។

## ៣- កិច្ចសហប្រតិបត្តិការ

### ក. កិច្ចសហប្រតិបត្តិការក្នុងស្រុក

ស.ហ.ក. បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នក្នុងស្រុក តាមរយៈយន្តការផ្លាស់ប្តូរព័ត៌មាន យន្តការអនុវត្តច្បាប់និងបទប្បញ្ញត្តិ និងអនុស្សរណៈយោគយល់។ ក្នុងឆ្នាំនេះ ស.ហ.ក. បានចុះអនុស្សរណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (គ.ល.ក.) និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដោយរួមបញ្ចូលនូវនិយ័តករដែលស្ថិតនៅក្រោមឱវាទ អ.ស.ហ.។



*ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ នៅអគាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា*



*ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាមួយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ នៅអគារទីស្តីការរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ*

### ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

#### i/- ក្រុមការងារហិរញ្ញវត្ថុ (FATF) និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG)

ស.ហ.ក. បានចូលរួមកិច្ចប្រជុំជាមួយក្រុមលេខាធិការដ្ឋាន APG និង FATF រួមមានកិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញចំនួន ៥ លើក កិច្ចប្រជុំគណៈកម្មការប្រតិបត្តិចំនួន ២ លើក និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗ។ ទន្ទឹមនេះ ស.ហ.ក.ក៏បានចូលរួមផ្តល់ធាតុចូលពាក់ព័ន្ធនឹងៈ i/- ស្ថានភាពហានិភ័យ និង/ឬកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលជាផ្នែកសំខាន់មួយក្នុងដំណើរការវាយតម្លៃអញ្ញមញ្ញ ii/- ប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង និងប្រទេសដែលត្រូវបង្កើនការតាមដាន iii/- ការស្ទង់មតិស្តីពីមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា



*កិច្ចប្រជុំមហាសន្និបាត និងវេទិកាជំនួយបច្ចេកទេសប្រចាំឆ្នាំ២០២៥ របស់ APG ចាប់ពីថ្ងៃទី២៥-២៩ ខែសីហា ឆ្នាំ២០២៥ នៅប្រទេសជប៉ុន*

និងអំពើជួញដូរមនុស្ស ដែលជាផ្នែកមួយនៃការរៀបចំរបាយការណ៍គំរូករណីសិក្សាប្រចាំឆ្នាំ២០២៥ របស់ APG iv/- ការស្ទង់មតិស្តីពីគម្រោងលើការបង្កើតប្រព័ន្ធការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសដែលមានសមត្ថភាពទាបរបស់ FATF និង v/- គម្រោងសិក្សាស្តីពីស្ថានភាពហានិភ័យវិស័យល្បែងពាណិជ្ជកម្មរបស់ FATF។ ជាមួយគ្នាផងដែរ ស.ហ.ក. បានចូលរួមកិច្ចប្រជុំមហាសន្និបាត និងវេទិកាជំនួយបច្ចេកទេសប្រចាំឆ្នាំ២០២៥ របស់ APG ដែលផ្តោតលើការងារសំខាន់ៗរួមមាន ការងារអភិបាលកិច្ច លទ្ធផលនៃការវាយតម្លៃអញ្ញមញ្ញ ការអនុវត្តការងារវាយតម្លៃអញ្ញមញ្ញ ជំនួយបច្ចេកទេស ការបណ្តុះបណ្តាលនិងគំរូសិក្សា និងការងារពាក់ព័ន្ធផ្សេងៗ។

ii/- **ក្រុមអ៊ិកម៉ុង (The Egmont Group)**

ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមការងាររបស់ក្រុមអ៊ិកម៉ុង តាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃគម្រោងសិក្សារបស់ក្រុមអ៊ិកម៉ុង និងនិន្នាការថ្មីៗពាក់ព័ន្ធនឹងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ស.ហ.ក. បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី៣១ ស្តីពី "កិច្ចសម្របសម្រួលអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនាពេលអនាគត" ដែលពិភាក្សាអំពីបញ្ហាប្រឈមជាសកលនិងសារៈសំខាន់នៃឯករាជ្យភាព និងស្វ័យភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ការពង្រឹងធនធានមនុស្សដល់ការងារប្រឆាំងនឹងហិរញ្ញប្បទានខុសច្បាប់ និងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យា ឱ្យស្របតាមនិន្នាការនៃការវិវត្តនៃហិរញ្ញវត្ថុវិមជ្ឈការ និងទ្រព្យសកម្មឌីជីថល។




*មហាសន្និបាតប្រចាំឆ្នាំលើកទី៣១ របស់ក្រុមអ៊ិកម៉ុង ចាប់ពីថ្ងៃទី៦-១១ ខែកក្កដា ឆ្នាំ២០២៤ នៅប្រទេសលុចសំបួ*

ទន្ទឹមនេះ ស.ហ.ក. បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញចំនួន ៣ លើក ដែលពិភាក្សាអំពីៈ i/- ការអភិវឌ្ឍកម្មវិធីសិក្សា Egmont Certificate of FIU Excellence and Leadership (ECOFEL) ii/- សមាជិកភាពរបស់ក្រុមអ៊ិកម៉ុង និង iii/- កិច្ចសហប្រតិបត្តិការរវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ បន្ថែមលើនេះ ស.ហ.ក. បានចូលរួមយ៉ាងសកម្មក្នុងការបំពេញកម្រងសំណួរលើគម្រោងសិក្សានានា ដូចជាៈ i/- បច្ចេកវិទ្យាថ្មី ii/- ការស្ទង់មតិឆ្នាំ២០២៥ ស្តីពីការចូលរួម ការពេញចិត្ត និងបទពិសោធរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និង iii/- ការធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

### iii/- ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (FICG)

ស.ហ.ក. បានចូលរួមកិច្ចប្រជុំរបស់ FICG ចំនួន ៣ លើក ដើម្បីពិភាក្សា និងចែករំលែកវឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងពិនិត្យលើវឌ្ឍនភាពនៃគម្រោងសិក្សានានា។ ស.ហ.ក. បានចូលរួមមហាសន្និបាតប្រចាំឆ្នាំ២០២៥ របស់ FICG ដែលផ្តោតលើគំនិតផ្តួចផ្តើម និងនវានុវត្តន៍ថ្មីៗពាក់ព័ន្ធនឹងហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការរួមគ្នាកាត់បន្ថយការគំរាមកំហែងផ្នែកសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងតំបន់។




*មហាសន្និបាតប្រចាំឆ្នាំ២០២៥ របស់ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី២៥-២៧ ខែមិថុនា ឆ្នាំ២០២៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន*

ជាមួយគ្នានេះ ស.ហ.ក. បានចូលជាសមាជិកប្រើប្រាស់ថ្នាលផ្លាស់ប្តូរព័ត៌មាន CLEO របស់ FICG ដែលបង្កើតឡើងក្នុងគោលបំណងសំខាន់ៗ រួមមាន៖ i/- ទំនាក់ទំនងរវាងសមាជិក FICG ii/- ការផ្លាស់ប្តូរព័ត៌មាន និង iii/- ការចែករំលែកឯកសារសម្រាប់ការបណ្តុះបណ្តាល។ ក្រៅពីនេះ ស.ហ.ក. ក៏បានផ្តល់ធាតុចូលសម្រាប់គម្រោងសិក្សា ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមាររបស់ FICG ផងដែរ។

## ៤. ការពង្រឹងសមត្ថភាព

ស.ហ.ក. បានបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីជាប្រចាំ។ ក្នុងន័យនេះ មន្ត្រី ស.ហ.ក. បានចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំតាមប្រព័ន្ធអនឡាញ ឬដោយផ្ទាល់លើប្រធានបទសំខាន់ៗ ដូចជា៖ i/-ការចូលរួមរបស់ស្ត្រីនៅក្នុង FATF និងបណ្តាញភាពជាអ្នកដឹកនាំជាសកល ii/-ការត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញ iii/-ហានិភ័យហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធទ្រព្យនិម្មិត និងបច្ចេកវិទ្យាទូទាត់ថ្មីៗ iv/-ការវិភាគ ការស៊ើបអង្កេត និងការចោទប្រកាន់បទល្មើសសម្អាតប្រាក់ និង v/-ស្តង់ដាររបស់ FATF ពាក់ព័ន្ធនឹងលទ្ធផលជាក់ស្តែងទី១ ទី៤ និងទី៦ ជាដើម។



*វគ្គបណ្តុះបណ្តាលផ្ទៃក្នុងសម្រាប់មន្ត្រី ស.ហ.ក. ស្តីពីនីតិវិធីវាយតម្លៃអញ្ញមញ្ញសកលជុំទី៥ របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) និងប្រធានបទពាក់ព័ន្ធ ចាប់ពីថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ*

ស.ហ.ក. បានរៀបចំសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលអំពីច្បាប់ និងបទប្បញ្ញត្តិស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន-ភេរវកម្ម វិធីសាស្ត្រវាយតម្លៃអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF និងនីតិវិធីនៃការវាយតម្លៃអញ្ញមញ្ញសកលជុំទី៥ សរុបចំនួន ១៣ លើក ជូនមន្ត្រី ស.ហ.ក. មន្ត្រីធនាគារជាតិនៃកម្ពុជា ក្រសួង-ស្ថាប័នត្រួតពិនិត្យ អាជ្ញាធរអនុវត្តច្បាប់ និងបុគ្គលរាយការណ៍។ បន្ថែមពីនេះ ស.ហ.ក. បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាដែលសហការរៀបចំដោយ អ.ស.ហ. និយ័តករសន្តិសុខសង្គម និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករបរធនបាលកិច្ច និយ័តករមូលបត្រកម្ពុជា និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និយ័តករគណនេយ្យនិងសវនកម្ម គ.ល.ក. និងលេខាធិការដ្ឋាននៃក្រុមការងារត្រួតពិនិត្យឡើងវិញ (RPG) នៃក្រសួងមហាផ្ទៃសរុបចំនួន ២១ លើក។



*សិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអនុលោមភាព" សម្រាប់គណៈគ្រប់គ្រងរបស់ធនាគារពាណិជ្ជ និងធនាគារឯកទេស នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ*

ជារួម ស.ហ.ក. បានបន្តពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការវិភាគរបាយការណ៍ប្រតិបត្តិការ និងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ ការធានាអនុលោមភាពរបស់បុគ្គលរាយការណ៍ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបណ្ដុះបណ្ដាល។ ស.ហ.ក. បានបន្តដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងបានបញ្ចប់ការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងរបាយការណ៍សង្ខេបដែលនឹងត្រូវដាក់ជូន គ.ស.ហ. ដើម្បីពិនិត្យ និងអនុម័ត។

VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ**

**១- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ**

ធនាគារជាតិនៃកម្ពុជាបន្តរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នអន្តរជាតិ ដើម្បីទទួលបានជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និងអនុសាសន៍គោលនយោបាយ សំដៅបន្តអភិវឌ្ឍនិងរក្សាភាពចន់វិស័យធនាគារកម្ពុជា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានបន្តចូលរួមតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ស្របពេលដែលធនាគារជាតិនៃកម្ពុជាបានឯកភាពនិងទទួលយកការដំឡើងកូតាពី ១៧៥ លានអេសដេអា (SDR) ដល់ ២៦២,៥ លាន SDR។ ការណ៍នេះនឹងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់កម្ពុជាច្រើនជាងមុនសម្រាប់ដោះស្រាយវិបត្តិដែលអាចកើតមានជាយថាហេតុ។

ក្រោមជំនួយបច្ចេកទេសរបស់ ADB ធនាគារជាតិនៃកម្ពុជាសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធបានបញ្ចប់ជាស្ថាពរការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ ដែលបានទទួលការឯកភាពនិងចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ កន្លងទៅ និងការអនុវត្តអនុកម្មវិធីទី១ នៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយចីរភាពនិងបរិយាបន្ន។ បច្ចុប្បន្ន អនុកម្មវិធីទី២ ត្រូវបានចាប់ផ្តើមអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធចាប់តាំងពីខែកញ្ញា ឆ្នាំ២០២៥ មក ហើយនឹងត្រូវបញ្ចប់នៅអំឡុងត្រីមាសទី៣ ឆ្នាំ២០២៦ ស្របពេលដែលជំនួយបច្ចេកទេសសម្រាប់ការធ្វើបច្ចុប្បន្នកម្មលើឯកសារយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០២៦-២០៣០ កំពុងត្រូវបានពិភាក្សា។ ជាមួយគ្នានេះ ជំនួយបច្ចេកទេសលើការដាក់ឱ្យដំណើរការប្រព័ន្ធកិច្ចការពារអតិថិជននៅកម្ពុជា និងការរៀបចំក្របខណ្ឌគ្រប់គ្រងវិបត្តិ ក៏កំពុងត្រូវបានពិភាក្សាជាមួយធនាគារពិភពលោក។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលស៊ាសិន មន្ត្រីបុគ្គលិកបានបន្តអភិវឌ្ឍជំនាញដោយបានចូលរួមវគ្គបណ្តុះបណ្តាលចំនួន ៣០ និងការស្រាវជ្រាវចំនួន ២ ក្នុងនោះ ធនាគារជាតិនៃកម្ពុជាទទួលរៀបចំវគ្គបណ្តុះបណ្តាល ចំនួន ២ ស្តីពី៖ i/-ការគ្រប់គ្រងវិបត្តិ ការរៀបចំផែនការដោះស្រាយនិងស្តារឡើងវិញ និង ii/-វិបត្តិនិងបញ្ហាប្រឈមនៅក្នុងម៉ាក្រូសេដ្ឋកិច្ច និងនយោបាយរូបិយវត្ថុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិស៊ាសិន និងក្រុមប្រឹក្សាភិបាលស៊ាសិន ដើម្បីពិភាក្សាលើផែនការយុទ្ធសាស្ត្រឆ្នាំ២០២៦-២០៣០ ផែនការការងារ និងថវិកាប្រចាំ ឆ្នាំ២០២៦ បញ្ហាប្រឈម និងសេចក្តីសម្រេចពាក់ព័ន្ធនឹងដំណើរការប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលស៊ាសិន។

ធនាគារជាតិនៃកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរឱ្យកាន់តែស៊ីជម្រៅ ដែលនឹងផ្តោតកិច្ចសហប្រតិបត្តិការលើការងារសំខាន់ចំនួន ៣៖ i/-ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ii/-ការពង្រឹងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងហិរញ្ញវត្ថុប្រកបដោយចីរភាព និងអាកាសធាតុ និង iii/-ការបង្កើតក្របខណ្ឌអន្តរប្រតិបត្តិការហិរញ្ញវត្ថុឆ្លងដែន (Cross-Border Interoperable Financial Framework – Universal Trusted Credentials)។ ទន្ទឹមនេះ ភាគីទាំងពីរក៏បានពិភាក្សាពីការស្រាវជ្រាវរួមគ្នា ការរៀបចំសន្និសីទកម្រិតខ្ពស់ ការគាំទ្រសហគ្រាសធុនតូច និងមធ្យម និងគំនិតផ្តួចផ្តើមនានា សំដៅលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។





*ជំនួបរវាងលោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោក អេនរីកូ ហ្គាវេលីយ៉ា (Enrico Gaveglia) តំណាងថ្មីនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ*

ក្នុងអំឡុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) ដើម្បីពិនិត្យនិងសម្រេចលើឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ AFI ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុបន្ថែមទៀត ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាក៏ត្រូវបានអញ្ជើញជាវាគ្មិនក្នុងកម្មវិធីចំនួន ២ របស់ AFI រួមមាន៖ i/-AFI Engage ដោយបានចែករំលែកបទពិសោធនៃភាពជាអ្នកដឹកនាំ ដល់អ្នកដឹកនាំវ័យក្មេងរបស់ប្រទេសមួយចំនួនដែលជាសមាជិករបស់ AFI និង ii/-Inclusive Policy Studio (IPS) ដោយបានចែករំលែកបទពិសោធ និងគំនិតផ្តួចផ្តើមថ្មីៗពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលស៊ាសិនលើកទី៦១ នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ នៅប្រទេសឥណ្ឌូណេស៊ី*



*លោកជំទាវបណ្ឌិត ទេសាភិបាល បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកម្មវិធី AFI Engage និង Inclusive Policy Studio (IPS) ចាប់ពីថ្ងៃ២-៤ ខែកញ្ញា ឆ្នាំ២០២៤ នៅប្រទេសណាមីប៊ី*

### ប្រអប់ ៧៖ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិផ្សេងទៀត

➢ **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៖** ក្រុមអ្នកជំនាញរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានមកបំពេញបេសកកម្មចំនួន២ លើកនៅធនាគារជាតិនៃកម្ពុជា ក្រោមគម្រោងជំនួយបច្ចេកទេស ស្តីពី "ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ចនិងប្រតិបត្តិការនយោបាយរូបិយវត្ថុ" ក្នុងគោលបំណងបន្តពិភាក្សាជាមួយមន្ត្រីជំនាញ និងគណៈកម្មាធិការគ្រប់គ្រងគម្រោងរបស់ធនាគារជាតិនៃកម្ពុជា។ លទ្ធផលសំខាន់ៗដែលទទួលបាន រួមមាន៖ i/-បង្កើនសមត្ថភាពបច្ចេកទេសលើគោលនយោបាយរូបិយវត្ថុ ការស្រាវជ្រាវ និងការវិភាគទិន្នន័យ ii/-ពិភាក្សាពីការព្យាករសន្ទនីយភាព (Liquidity Forecasting) iii/-ពង្រឹងប្រតិបត្តិការទីផ្សាររូបិយវត្ថុ (Money Market Operation) និង

iv/-ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ JICA នឹងបន្តជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់ឆ្នាំសារពើពន្ធជប៉ុន (JFY) ២០២៦ ក្រោមគម្រោងស្តីពី "ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ចនិងប្រតិបត្តិការនយោបាយរូបិយវត្ថុដំណាក់កាលទី២" ដែលជាកិច្ចការបន្តសម្រាប់ឆ្នាំ២០២៦។

➢ **អង្គការសហប្រជាជាតិនៅកម្ពុជា (UN)៖** ធនាគារជាតិនៃកម្ពុជាសហការជាមួយ អង្គការសហប្រជាជាតិនៅកម្ពុជា រៀបចំកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយពហុភាគីពាក់ព័ន្ធលើកទី២ និងទី៣ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងគោលបំណងពិនិត្យឡើងវិញនូវវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពអាទិភាពចំនួន ២២ ដែលបានអនុម័តក្នុងកិច្ចសន្ទនាកម្រិតខ្ពស់លើកទី១។ កិច្ចសន្ទនានេះក៏បានបង្ហាញពីការពិភាក្សាយ៉ាងស៊ីជម្រៅលើប្រធានបទសំខាន់ៗចំនួន ២៖ i/-កិច្ចការពារអតិថិជន និង ii/-ក្របខណ្ឌលើកទឹកចិត្ត ដែលរួមបញ្ចូលក្រមសីលធម៌ និងការទទួលខុសត្រូវក្នុងការផ្តល់កម្ចី និងការប្រមូលកម្ចីត្រឡប់មកវិញ។ ទន្ទឹមនេះ ភាគីទាំងពីរក៏បានរៀបចំកិច្ចពិគ្រោះយោបល់ ស្តីពីការចូលរួមរបស់វិនិយោគិនប្រកបដោយការទទួលខុសត្រូវ ក្នុងគោលបំណងបង្កើតចក្ខុវិស័យរួមគ្នាសម្រាប់ការអនុវត្តគោលការណ៍សង្គម អភិបាលកិច្ច និងកិច្ចការពារអតិថិជន ដែលគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីសម្រាប់ការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងចីរភាព។



*កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់លើកទី៣ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជានាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*



*កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់លើកទី២ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

➢ **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** កិច្ចសហការជាបន្តបន្ទាប់ត្រូវបានរៀបចំឡើងរវាងធនាគារជាតិនៃកម្ពុជា និង IFC លើដំណើរអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈសិក្ខា-សាលានានា ដែលក្នុងនោះសិក្ខាសាលាពិគ្រោះយោបល់ស្តីពី សេចក្តីព្រាងប្រព័ន្ធវង្គករសាស្ត្រ (Taxonomy) សម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជាធ្វើឡើងក្នុងគោលបំណងប្រមូលធាតុចូលបន្ថែមសម្រាប់បញ្ចូលក្នុងឯកសារដ៏មានសារៈសំខាន់នេះ សំដៅរួមចំណែកក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចបៃតង។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា IFC និងគ្រឹះស្ថានពាក់ព័ន្ធបានរៀបចំសិក្ខាសាលាស្តីពី "ទីផ្សាររូបិយវត្ថុនៅកម្ពុជា" ដើម្បីផ្តល់ជាវេទិកាដល់តំណាងស្ថាប័នហិរញ្ញវត្ថុជួបជុំ និងពិភាក្សា



*ឯកឧត្តម គីមទី កោមលី អគ្គនាយកប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីក្នុងសិក្ខាសាលា ស្តីពី «ទីផ្សាររូបិយវត្ថុនៅកម្ពុជា» នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

អំពីទិដ្ឋភាពទូទៅនិងសារៈសំខាន់របស់ទីផ្សាររូបិយវត្ថុ ឧបករណ៍ដែលបានជួញដូរនៅក្នុងទីផ្សាររូបិយវត្ថុ មូលដ្ឋានគ្រឹះសំខាន់ក្នុងការបង្កើតទីផ្សាររូបិយវត្ថុឱ្យមានដំណើរការល្អ ព្រមទាំងការស្វែង-យល់អំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមសំខាន់ៗក្នុងការអភិវឌ្ឍទីផ្សាររូបិយវត្ថុនៅកម្ពុជា។ លើសពីនេះ IFC បានបន្តគាំទ្រដល់ធនាគារជាតិនៃកម្ពុជាទៅលើ ការរៀបចំនិងដាក់ចេញនូវបទប្បញ្ញត្តិ និងការពង្រឹងការត្រួតពិនិត្យនានាពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន តាមរយៈការបញ្ជ្រាបចំណេះដឹងបន្ថែមក្រោមការធ្វើបទបង្ហាញស្តីពី "បទពិសោធនៃការគ្រប់គ្រងទ្រព្យសកម្មដែលមានវិបត្តិ (Distressed Asset)"។

➢ **អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO)៖** ធនាគារជាតិនៃកម្ពុជាសហការជាមួយនឹងអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) បានរៀបចំសិក្ខាសាលាស្តីពី "ការវិវត្តនៃយន្តការពហុនីយ-កម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)" នាថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០២៥។ សិក្ខាសាលានេះជាផ្នែកមួយនៃការលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីជំនាញរបស់ប្រទេសសមាជិក ទាំងមកពីធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សិក្ខាសាលានេះ បានផ្តោតលើប្រធានបទដូចជា៖ i/-ទិដ្ឋភាពទូទៅនៃបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុសកល និងតំបន់អាស៊ាន+៣ ii/-ដំណើរការនៃយន្តការ CMIM និងនីតិវិធីស្វ៊ប់ (SWAP) iii/-យន្តការក្នុងការសម្រេចចិត្ត និង iv/-ការផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹង "Structural, Policy, Improvement and Review, Instrument with Technical Assistance-SPIRIT"។




*សិក្ខាសាលាស្តីពី "ការវិវត្តនៃយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)" នាថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ*

➢ **វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា (ERIA)៖** ធនាគារជាតិនៃកម្ពុជាបានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា (ERIA) ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការលើកកម្ពស់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា"។ សិក្ខាសាលានេះ មានការចូលរួមដោយតំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍អន្តរជាតិ សមាគមធនាគារ សមាគមមីក្រូ-ហិរញ្ញវត្ថុនៅកម្ពុជា សមាគមពាណិជ្ជកម្ម សភាពាណិជ្ជកម្ម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុន-សហគ្រាសឯកជន និងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងគោលបំណងប្រមូលធាតុចូលបន្ថែម និងផ្ទៀងផ្ទាត់លទ្ធផលបឋមនៃគម្រោងស្រាវជ្រាវរបស់អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ។



*លោកបណ្ឌិត ឃូ វុណ្ណី ឧបការីទេសាភិបាល និងជាអគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុងសិក្ខាសាលា ស្តីពី "ការលើកកម្ពស់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

## ២- កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្ដាលនិងអាជ្ញាធររូបិយវត្ថុ

មន្ត្រីជំនាញនៃធនាគារជាតិនៃកម្ពុជាបានចែករំលែកបទពិសោធដល់មន្ត្រីជំនាញនៃអាជ្ញាធររូបិយវត្ថុប៊ូតង់ ដែលបានមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជាលើប្រធានបទ៖ i/-ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ii/ការផ្ទេរប្រាក់និងការទូទាត់ឆ្លងដែន iii/-ការផ្ដល់អាជ្ញាបណ្ណអាជីវកម្មប្ដូរប្រាក់ និង iv/-ទីផ្សាររូបិយវត្ថុ។ ជាមួយគ្នានេះ មន្ត្រីជំនាញនៃធនាគារជាតិនៃកម្ពុជាក៏បានចែករំលែកបទពិសោធ តាមប្រព័ន្ធអនឡាញ អំពីដំណើរការនៃកម្មវិធីបាគងទេសចរផងដែរ។



*ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញអាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់ នាថ្ងៃទី១២-១៨ ខែមករា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ*

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលម៉ាដាហ្គាស្កា បានចុះអនុស្សរណៈយោគយល់ ដើម្បីបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្ដាលទាំងពីរ ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារកណ្ដាលរួមមាន៖ i/-ការតភ្ជាប់ប្រព័ន្ធទូទាត់និងនវានុវត្តន៍ ii/-នវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល iii/-រូបិយប័ណ្ណឌីជីថលធនាគារកណ្ដាល iv/-សន្តិសុខសាយប័រ v/-អភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធផ្នែកព័ត៌មានវិទ្យា vi/-ការការពារទិន្នន័យ vii/-ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងមាស viii/-ការគ្រប់គ្រងរូបិយវត្ថុ និងទុនបម្រុងកាតព្វកិច្ច ix/-បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន x/-ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ xi/-ការត្រួតពិនិត្យធនាគារ និង xii/-ការអភិវឌ្ឍធនធានមនុស្ស រួមជាមួយការងារផ្សេងៗទៀតដែលភាគីទាំងពីរយល់ឃើញថាមានសារៈសំខាន់នាពេលអនាគត។




*ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលម៉ាដាហ្គាស្កា នាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

ក្រោមស្មារតីនៃការចុះអនុស្សរណៈយោគយល់រវាង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលទីម័រឡេស្តេកាលពីឆ្នាំ២០២៤ គណៈប្រតិភូធនាគារកណ្តាលទីម័រឡេស្តេបានមកធ្វើទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជា ដើម្បីស្វែងយល់ពីបទពិសោធរបស់ធនាគារជាតិនៃកម្ពុជា លើការអភិវឌ្ឍប្រព័ន្ធទូទាត់អេឡិចត្រូនិកនៅកម្ពុជា។



ទស្សនកិច្ចរបស់គណៈប្រតិភូធនាគារកណ្តាលទីម័រឡេស្តេ ដឹកនាំដោយលោកជំទាវ ទេសាភិបាលរង Sara Lobo Brites នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ីបានដាក់ឱ្យដំណើរការជាផ្លូវការនូវដំណាក់កាលទីពីរនៃគម្រោងទូទាត់ឆ្លងដែនតាមយ្យអរកូតរវាងប្រទេសទាំងពីរកាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ ក្នុងអំឡុងពេលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី១២ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ ការពង្រីកគម្រោងទូទាត់ឆ្លងដែននេះបានរួមចំណែក៖ i/-ជំរុញកំណើនទេសចរណ៍ ii/-លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈការផ្សាភ្ជាប់ទៅនឹងសេដ្ឋកិច្ចក្នុងតំបន់ និងកាលានុវត្តភាពធុរកិច្ចឱ្យកាន់តែទូលំទូលាយ iii/-ពង្រឹងសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងតំបន់ ដែលជាជំហានឆ្ពោះទៅរកទំនាក់ទំនងសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ និងកំណើនឌីជីថលប្រកបដោយសក្តានុពល។



ពិធីប្រកាសដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនតាមយ្យអរកូតដំណាក់កាលទីពីរ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

ធនាគារជាតិនៃកម្ពុជាបានជួបក្រុមការងារនៃអាជ្ញាធររូបិយវត្ថុហុងកុង ដើម្បីពិភាក្សាលើការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់រាយ ការតភ្ជាប់ការទូទាត់សងប្រាក់តម្លៃធំ និងការគ្រប់គ្រងការប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ។ ភាគីទាំងពីរក៏បានឯកភាពក្នុងការពិនិត្យលទ្ធភាពនៃការចុះអនុស្សរណៈយោគយល់ ក្នុងការផ្តល់នូវយន្តការសមស្របឱ្យភាគីទាំងពីរបំពេញកិច្ចការខាងលើដោយប្រសិទ្ធភាព។



ជំនួបរវាងលោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងតំណាងអាជ្ញាធររូបិយវត្ថុហុងកុង នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងហុងកុង



*ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្ដាលបង់ក្លាដេស នាថ្ងៃទី៨-១០ ខែឧសភា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ*

ធនាគារជាតិនៃកម្ពុជាបានចែករំលែកបទពិសោធនិងចំណេះដឹងដល់គណៈប្រតិភូនៃធនាគារកណ្ដាលបង់ក្លាដេស លើប្រធានបទចំនួន ៦ រួមមាន៖ i/-តួនាទី-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការអភិវឌ្ឍគោល-នយោបាយនិងបទប្បញ្ញត្តិលើការផ្ដល់ឥណទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ii/-យុទ្ធសាស្ត្រក្នុងការបង្កើនទំហំឥណទានសម្រាប់ MSMEs iii/-យុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុ iv/-តួនាទីសេវាហិរញ្ញវត្ថុឌីជីថល ដោយរួមបញ្ចូលសេវាធនាគារចល័ត v/-បច្ចេកវិទ្យាហិរញ្ញវត្ថុនិងប្រព័ន្ធបាគង និង vi/-ប្រព័ន្ធនៃការគ្រប់គ្រងនិងវាយតម្លៃប្រសិទ្ធភាពការងារមន្ត្រី-បុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា។




*ពិធីប្រកាសដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែន តាមយូអរកូដដំណាក់កាលទីពីរ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលឡាវ នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ*

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលឡាវបានជួបប្រជុំទ្វេភាគីប្រចាំឆ្នាំនៅកម្ពុជា ដើម្បីពិនិត្យមើលវឌ្ឍនភាព និងដាក់ចេញនូវទិសដៅសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរសម្រាប់ឆ្នាំ២០២៦ ខាងមុខ សំដៅរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៃប្រទេសទាំងពីរ ព្រមទាំងបានដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូត រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ដំណាក់កាលទី២៖ ឡាវស្កេនខេអេចយូអរកូត)។ ទន្ទឹមនេះ មន្ត្រីជំនាញនៃធនាគារកណ្ដាលឡាវបានមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជា ដើម្បីដកស្រង់បទពិសោធលើ៖ i/-យន្តការនៃការគ្រប់គ្រងអត្រាប្ដូរប្រាក់ ii/-ការគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទូទាត់របស់ធនាគារកណ្ដាល iii/-នីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណតាមប្រភេទគ្រឹះស្ថានធនាគារ iv/-ច្បាប់និងបទប្បញ្ញត្តិលើការគ្រប់គ្រងការធ្វើប្រតិបត្តិការអន្តរជាតិ v/-ប្រព័ន្ធវិមជ្ឈការរបស់ធនាគារកណ្ដាលក្នុងការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ និង vi/-ការរឹតបន្តឹងនិងការរៀបចំបទប្បញ្ញត្តិជាក់លាក់សម្រាប់ការទូទាត់លើទំនិញប្រណីត។

គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានធ្វើទស្សនកិច្ចសិក្សា នៅធនាគារជាតិហ្សុីកហ្សុី ក្នុងគោលបំណងស្វែងយល់ និងផ្លាស់ប្តូរបទពិសោធពីការអនុវត្តគោលនយោបាយនិងវិធានការនានារបស់ធនាគារជាតិហ្សុីកហ្សុីក្នុងការជំរុញការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ការលើកកម្ពស់ហិរញ្ញប្បទានបៃតង និងការគ្រប់គ្រងយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនានារបស់ធនាគារជាតិនៃកម្ពុជា។



*ឯកឧត្តម យឹម លាត ទេសាភិបាលរង បានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជាធ្វើទស្សនកិច្ចសិក្សា នាថ្ងៃទី២១-២៣ ខែកក្កដា ឆ្នាំ២០២៤ នៅធនាគារជាតិហ្សុីកហ្សុី*

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន បានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំលើកទី២ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ព្រមទាំងបានផ្លាស់ប្តូរទស្សនាទាន និងបទពិសោធលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច វិស័យធនាគារ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន។



*កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលហ្វីលីពីន នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៤ នៅខេត្ត Bohol ប្រទេសហ្វីលីពីន*

ធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម បានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ ក្នុងគោលបំណងពិភាក្សាលើវឌ្ឍនភាពនិងទិសដៅនៃកិច្ចសហប្រតិបត្តិការ សម្រាប់ឆ្នាំ២០២៥-២០២៦ ដែលរួមមានការបង្កើនវិសាលភាពនៃការទូទាត់ទ្វេភាគី តាមរយៈការជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមកាន់តែច្រើន ការលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកសម្រាប់ការទូទាត់ឆ្លងដែន និងការលើកកម្ពស់តួនាទីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសទាំងពីរ។



*កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ*

មន្ត្រីជំនាញធនាគារកណ្តាលនេប៉ាល់ (សរុប ៦០រូប) បានមកបំពេញទស្សនកិច្ចសិក្សានៅធនាគារជាតិនៃកម្ពុជាចំនួន ២ លើក ដើម្បីដកស្រង់បទពិសោធលើការគ្រប់គ្រងសាច់ប្រាក់ ប្រព័ន្ធទូទាត់ឌីជីថល ការគ្រប់គ្រងធនធានមនុស្ស បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន។



*ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញធនាគារកណ្តាលនេប៉ាល់ នាថ្ងៃទី៨-១១ ខែកញ្ញា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា*

## ៣- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន ជាពិសេសការធ្វើសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងតំបន់ ស្របតាមមូលបទអាស៊ានឆ្នាំ២០២៥ "បរិយាបន្ននិងចីរភាព" ជាមួយនឹងយុទ្ធសាស្ត្រអាទិភាពចំនួន ៤ រួមមាន៖ i/-ការបង្កើនវិនិយោគនិងពាណិជ្ជកម្ម ii/-សមាហរណកម្មនិងការតភ្ជាប់សេដ្ឋកិច្ច iii/-ការជំរុញឱ្យមានអនាគតមួយ ប្រកបដោយបរិយាបន្ននិងចីរភាព និង iv/-ការផ្លាស់ប្តូរសម្រាប់អនាគតឌីជីថល។ សមិទ្ធផលអាទិភាពសេដ្ឋកិច្ច (PED) ចំនួន ៣ ដែលស្ថិតក្រោមដែនសមត្ថកិច្ចធនាគារកណ្តាល រួមមាន៖ i/-ការពន្លឿនកំណើនទីផ្សារមូលធនអាស៊ានប្រកបដោយចីរភាព ii/-ការជំរុញការតភ្ជាប់ប្រព័ន្ធទូទាត់ទាំងក្នុងនិងក្រៅតំបន់ និង iii/-ការជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានបៃតងសម្រាប់ការសម្របនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់ឱ្យធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុក្នុងតំបន់អនុវត្តនិងផ្តោតការយកចិត្តទុកដាក់។

ជាមួយនឹងការបញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០១៦-២០២៥ (SAP) អាស៊ានបានអនុម័តនិងដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៦-២០៣០ ដែលជាផែនការសកម្មភាពរយៈពេល ៥ ឆ្នាំដំបូង ឆ្ពោះទៅរកចក្ខុវិស័យ AEC ២០៤៥ ដោយផ្តោតលើគោលដៅយុទ្ធសាស្ត្រចំនួន ៦ រួមមាន៖ i/-សហគមន៍ដែលគាំទ្រដោយសកម្មភាព (An action-oriented community) ii/-សហគមន៍ប្រកបដោយចីរភាព iii/-សហគមន៍ប្រកបដោយសហគ្រិនភាពនិងនវានុវត្តន៍ iv/-សហគមន៍ប្រកបដោយភាពបត់បែននិងបុរេសកម្ម v/-សហគមន៍ប្រកបដោយភាពរហ័សរហួននិងធន់ និង vi/-សហគមន៍ប្រកបដោយបរិយាបន្ន សហការ និងម្ចាស់ការ។

ទន្ទឹមនេះ អាស៊ានបានបញ្ចប់ការរៀបចំនិងចេញផ្សាយវដ្តករសាស្ត្រអាស៊ានស្តីពី ហិរញ្ញប្បទានប្រកបដោយចីរភាព ច្បាប់ទី៤ (version 4) ដែលនេះគឺជាច្បាប់នៃក្របខណ្ឌនិងសេចក្តីណែនាំចុងក្រោយសម្រាប់តំបន់ក្នុងការធ្វើចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចប្រកបដោយចីរភាពនៅតាមវិស័យនានា។






*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ចូលរួមកិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន (AFMGM) លើកទី១២ កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន (ACGM) និងកិច្ចប្រជុំពាក់ព័ន្ធ កាលពីថ្ងៃទី៧-១០ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី*

## ៤- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន+៣

ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមពង្រឹងកិច្ចសហប្រតិបត្តិការនិងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់អាស៊ាន+៣ ដោយមានប្រទេសម៉ាឡេស៊ី និងចិនជាសហប្រធានប្តូរវេនឆ្នាំ២០២៥។ ក្នុងក្របខណ្ឌនេះ ក្រសួងហិរញ្ញវត្ថុនិងធនាគារកណ្តាលអាស៊ាន+៣ បានសម្រេចបង្កើតឧបករណ៍ពង្រឹងនិងពិនិត្យគោលនយោបាយរចនាសម្ព័ន្ធជាមួយនឹងការផ្តល់ជំនួយបច្ចេកទេស (SPIRIT) និងបន្តកែលម្អយន្តការគំនិតផ្តួចផ្តើមពហុនីយកម្មឈៀងម៉ៃ (CMIM) ជាមួយនឹងការបង្កើតឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស (RFF)។ ម៉្យាងទៀត សមត្ថភាពអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក្នុងការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុតំបន់អាស៊ាន+៣ ក៏ត្រូវបានពង្រឹងនិងបង្កើនប្រសិទ្ធភាព ស្របពេលដែលបណ្តាញអ្នកជំនាញហិរញ្ញវត្ថុអាស៊ាន+៣ (AFTN) ក៏ត្រូវបានពង្រីកជាបន្តបន្ទាប់ ដើម្បីពង្រឹងការចែករំលែកចំណេះដឹងនិងការស្រាវជ្រាវនៅក្នុងតំបន់ឱ្យកាន់តែមានប្រសិទ្ធផល។ ជាមួយគ្នានេះ ការសាកល្បង CMIM លើកទី១៦ ដោយផ្តោតលើយន្តការសម្រេចចិត្តក្នុងការផ្តល់ឥណទានតាមរយៈឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស ដែលមិនភ្ជាប់នឹងឥណទានរបស់ IMF ក៏ត្រូវបានធ្វើតេស្តអនុវត្តប្រកបដោយភាពជោគជ័យ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយអង្គភាព AMRO រៀបចំសិក្ខាសាលាស្តីពី ការវិវត្តនៃយន្តការ CMIM និងការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុអាស៊ាន+៣ ព្រមទាំងបានបញ្ជូនមន្ត្រីជំនាញហាត់ការនៅអង្គភាព AMRO សម្រាប់រយៈពេល ១២ខែ។




*កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៥ នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី*

ជារួម កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីរបស់ធនាគារជាតិនៃកម្ពុជាជាមួយធនាគារ-កណ្តាល ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា កាន់តែមានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងបានតាមរយៈការចុះអនុស្សរណៈយោគយល់ ការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធ ការសិក្សាស្រាវជ្រាវរួមគ្នា ការចូលរួមតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការអនុវត្តគម្រោងជំនួយបច្ចេកទេសជាដើម។ កិច្ចសហប្រតិបត្តិការនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនជាពិសេសការលើកកម្ពស់សមត្ថភាពមន្រ្តីជំនាញនិងស្ថាប័នក្នុងការបំពេញតួនាទីជាធនាគារកណ្តាលស្របតាមនិន្នាការនិងការវិវឌ្ឍរីកចម្រើននៃវិស័យហិរញ្ញវត្ថុនិងបច្ចេកវិទ្យាជាសកល ព្រមទាំងបានរួមចំណែកក្នុងការពង្រីកទំនាក់ទំនងនិងការតភ្ជាប់ និងជាពិសេសពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុរបស់កម្ពុជាផងដែរ។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

**សមាសភាពក្រុមប្រឹក្សាភិបាល**



**លោកជំទាវ ជា សិរី**
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
ជាប្រធាន



**ឯកឧត្តម ស៊ុំ សន្និសិទ្ធ**
ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា
ជាសមាជិក



**ឯកឧត្តម ហួត ពុំ**
តំណាងប្រមុខរាជរដ្ឋាភិបាល
ជាសមាជិក



**ឯកឧត្តម រស់ សីលវ៉ា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាសមាជិក



**លោកស្រី អេង នេត្រា**
តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
ជាសមាជិក



**លោក ឡាយ ម៉េងស៊ុន**
តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
ជាសមាជិក



**លោក មុំ ដារ៉ែត**
តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា
ជាសមាជិក

នាឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើករួមមាន៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៨ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័ត លើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២៤
- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៩ នាថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២៤ និងផែនការឆ្នាំ២០២៥
- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧០ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាពការងារគ្រប់គ្រងទុន-បម្រុងវិនិយោគឆ្នាំ២០២៤ និងវឌ្ឍនភាពនៃការគ្រប់គ្រងទុនបម្រុងវិនិយោគ
- លើកទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧១ នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥ របស់ធនាគារជាតិនៃកម្ពុជា
- លើកទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧២ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍ស្តីពី ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ និងការសិក្សាលើស្ថានភាពនៃពលករខ្មែរដែលវិលត្រលប់ពីប្រទេសថៃ និង
- លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧៣ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២៥ និងទិសដៅការងារ ឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា និងការបោះផ្សាយមូលបត្ររដ្ឋជាប្រាក់ដុល្លារអាមេរិក។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧២ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ*

## ២- ការអភិវឌ្ឍធនធានមនុស្ស

ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា មានការរីកចម្រើនជាលំដាប់ ដោយប្រែក្លាយពីការគ្រប់គ្រងបែបរដ្ឋបាលទៅជាដៃគូយុទ្ធសាស្ត្រដើម្បីជំរុញឱ្យស្ថាប័នទទួលបានជោគជ័យ។ ការរីកចម្រើននេះបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការកើនឡើងទាំងបរិមាណនិងគុណវុឌ្ឍិរបស់មន្ត្រី-បុគ្គលិក បន្ទាប់ពីការអនុវត្តនូវយុទ្ធសាស្ត្រជ្រើសរើសមន្ត្រីជំនាញតាមតម្រូវការជាក់ស្តែង ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងការពង្រឹងរចនាសម្ព័ន្ធចាត់តាំងឱ្យស្របតាមការប្រែប្រួលតួនាទី និងទំហំការងាររបស់ធនាគារជាតិនៃកម្ពុជា។ ទន្ទឹមនេះ ការធ្វើឌីជីថលូបនីយកម្មបានរួមចំណែកសម្រួលនីតិវិធីការងារឱ្យកាន់តែមានភាពងាយស្រួល និងបានពង្រឹងមុខងារគ្រប់គ្រងធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាពល្អប្រសើរ។

## ក- ស្ថិតិមន្ត្រី-បុគ្គលិក

មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាក្នុងក្របខណ្ឌទូទាំងប្រទេសនាឆ្នាំ២០២៥នេះ មានចំនួនសរុប ២.១២៦រូប (ស្រី ១.០៤១រូប) ដែលក្នុងនោះស្នាក់ការកណ្តាលមានចំនួន ១.៦១៨រូប (ស្រី ៧៦៤រូប) និងសាខារាជធានី-ខេត្ត មានចំនួន ៥០៨រូប (ស្រី ២៧៧រូប)។ ក្នុងរយៈពេលមួយឆ្នាំនេះ មន្ត្រី-បុគ្គលិកក្របខណ្ឌធនាគារជាតិនៃកម្ពុជាបានកើនឡើងចំនួន ៨៨រូប ដែលក្នុងនោះ នៅស្នាក់ការកណ្តាលកើនឡើងចំនួន ១០២រូប ខណៈដែលនៅសាខាថយចុះចំនួន ១៤រូប។

ក្រាហ្វ ៨៧៖ ស្ថិតិមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា តាមកម្រិតវប្បធម៌

(ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- ការងារបណ្តុះបណ្តាល

### i/- ការងារបណ្តុះបណ្តាលក្នុងប្រទេស

ការបណ្តុះបណ្តាលក្នុងប្រទេសត្រូវបានកែលម្អឱ្យស្របតាមតម្រូវការចាំបាច់លើការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី-បុគ្គលិកតាមជំនាញបច្ចេកទេសរបស់អគ្គនាយកដ្ឋាននីមួយៗ និងផែនការបណ្តុះបណ្តាល ប្រចាំឆ្នាំ២០២៥។ ធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលលើប្រធានបទសំខាន់ៗ ដូចជា ៖ i/- បទប្បញ្ញត្តិ ii/- ការត្រួតពិនិត្យធនាគារ iii/- នយោបាយរូបិយវត្ថុ iv/- ប្រព័ន្ធទូទាត់សងប្រាក់ និង v/- ជំនាញផ្សេងៗទៀតពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារកណ្តាល ព្រមទាំងបានចាត់បញ្ជូនមន្ត្រី-បុគ្គលិកចូលរួមកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួង-ស្ថាប័ននានាក្រោមរូបភាពជាសិក្ខាសាលា និងវគ្គសិក្សា សរុបចំនួន ៣៧លើក និងមានសិក្ខាកាមសរុប ២.៥៩៤រូប។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តនិងពង្រីក វិសាលភាពលើការអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែសម្បូរបែប ជាពិសេសជំរុញសមត្ថភាពភាសាបរទេស។ បច្ចុប្បន្ន មានមន្ត្រី-បុគ្គលិកសរុបចំនួន ២៨៧រូប កំពុងសិក្សាភាសាបរទេស ដែលក្នុងនោះភាសាអង់គ្លេស ២៧៨រូប បារាំង ៨រូប និងចិន ១រូប។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលស៊ាសិន ការិយាល័យអភិវឌ្ឍន៍សមត្ថភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ (CDOT) និងធនាគារកណ្តាលជប៉ុន ធ្វើជាម្ចាស់ផ្ទះរៀបចំវគ្គសិក្សាលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារកណ្តាលសរុបចំនួន ៩លើក រួមមាន៖ i/- ការគ្រប់គ្រងវិបត្តិ ការរៀបចំផែនការដោះស្រាយ និងស្តារឡើងវិញ ii/- ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ iii/- វិបត្តិ និងបញ្ហាប្រឈមក្នុងម៉ាក្រូសេដ្ឋកិច្ច និងនយោបាយរូបិយវត្ថុ និង iv/- សេរីភាវូបនីយកម្មគណនីមូលធននិងការបង្កើតគោលនយោបាយ ដែលមានសិក្ខាកាមមកពី ១៦ប្រទេសចូលរួម។

### ii/- ការងារបណ្តុះបណ្តាលក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជា បានបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាមួយដៃគូអន្តរជាតិទាំងរយៈពេលខ្លី និងរយៈពេលវែង។ ចំពោះការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជាបានចាត់បញ្ជូនមន្ត្រី-បុគ្គលិកឱ្យចូលរួមសិក្ខាសាលា វគ្គសិក្សា និងទស្សនកិច្ច-សិក្សាផ្សេងៗ ចំនួន ១៦១លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៣៧៩រូប។

ដោយឡែក ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលវែងត្រូវបានរៀបចំឡើងជាពីរទម្រង់ គឺការចាត់បញ្ជូនមន្ត្រី-បុគ្គលិកឱ្យចូលរួមអនុវត្តការងារដោយផ្ទាល់ជាមួយស្ថាប័នអន្តរជាតិនានា និងការអនុញ្ញាតឱ្យមន្ត្រី-បុគ្គលិកបន្តការសិក្សានៅក្រៅប្រទេស។ នាឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជាបានចាត់បញ្ជូនមន្ត្រី-បុគ្គលិកឱ្យបំពេញការងារជាទីប្រឹក្សានៅ SEAV Group នៃ IMF ចំនួន ១រូប ជាអ្នកហាត់ការរបស់ IMF ចំនួន ១រូប និងជាអ្នកហាត់ការរបស់ AMRO ចំនួន ១រូប ព្រមទាំងអនុញ្ញាតឱ្យមន្ត្រីបុគ្គលិកបន្តការសិក្សានៅក្រៅប្រទេសចំនួន ៩១រូប ក្នុងនោះថ្នាក់បណ្ឌិតចំនួន ២រូប និងថ្នាក់អនុបណ្ឌិតចំនួន ៣៩រូប។

### iii/- ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ

ស្របតាមនិន្នាការនៃការរីកចម្រើនបច្ចេកវិទ្យា និងដើម្បីសម្រួលដល់ការសិក្សារៀនសូត្ររបស់មន្ត្រី-បុគ្គលិកដែលមានឆន្ទៈអភិវឌ្ឍសមត្ថភាព ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមរៀបចំឱ្យមានវគ្គសិក្សា តាមប្រព័ន្ធអនឡាញបន្ថែមលើការបណ្តុះបណ្តាលដោយផ្ទាល់ រួមមាន៖ i/- កម្មវិធីបណ្តុះបណ្តាល NBC – FSI Connect ជាវគ្គសិក្សាជំនាញត្រួតពិនិត្យធនាគារដែលបានដំណើរការចំនួន ៨ជំនាន់ ហើយមានសិក្ខាកាមកំពុងសិក្សាចំនួន ២៧៦រូប ii/- កម្មវិធីបណ្តុះបណ្តាល Coursera បានដំណើរការចំនួន ២ជំនាន់ ដែលមានសិក្ខាកាមសរុប ៤០០រូប iii/- កម្មវិធីបណ្តុះបណ្តាលជំនាញគ្រប់គ្រងហានិភ័យ មានចំនួន ១០មុខវិជ្ជា និងមានសិក្ខាកាមជំនាន់ទី១ សរុបចំនួន ២០រូប ក្នុងនោះសិក្ខាកាម ១៥រូប បានប្រឡងបញ្ចប់ និងទទួលបានលទ្ធផលជាប់ជាស្ថាពរ នាខែតុលា ឆ្នាំ២០២៥ iv/- កម្មវិធីបណ្តុះបណ្តាល Chartered Banker មាន ៤មុខវិជ្ជា និងមានសិក្ខាកាមកំពុងសិក្សាសរុបចំនួន ៤០រូប v/- កម្មវិធីសិក្សា Micro-Master របស់វិទ្យាស្ថាន MIT មានចំនួន ៣ជំនាន់ ដែលមានមន្ត្រី-បុគ្គលិកចូលរួមសិក្សាសរុបចំនួន ៥៩រូប និង vi/-កម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតតាមប្រព័ន្ធអនឡាញ ដែលមានមន្ត្រី-បុគ្គលិកចំនួន ១រូប កំពុងសិក្សា និងមានមន្ត្រី-បុគ្គលិកចំនួន ១៨រូប ទៀតកំពុងចុះឈ្មោះ និងបំពេញលក្ខខណ្ឌចាំបាច់របស់សាកលវិទ្យាល័យលំដាប់អន្តរជាតិនានា។

### iv/-ការងារបណ្តុះបណ្តាលផ្នែកសុខុមាលភាព និងសង្គម

ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការលើកកម្ពស់សុខុមាលភាព និងជួយសម្រួលបន្ទុកចំណាយរបស់មន្ត្រី-បុគ្គលិកក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពឱ្យកាន់តែល្អប្រសើរ សមស្របតាមកំណើនសេដ្ឋកិច្ច និងការរីកចម្រើននៃទំហំការងារនាពេលបច្ចុប្បន្ន។

ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំកម្មវិធីបណ្តុះបណ្តាលសុខុមាលភាពផ្លូវចិត្ត ដែលរួមមាន វគ្គសិក្សា Arts of Living ចំនួន ៦លើក (មន្ត្រី-បុគ្គលិកចូលរួមចំនួន ៣០៦រូប) វគ្គសិក្សាវិទ្យាសាស្ត្រ និងសុខុមាលភាពផ្លូវចិត្តវគ្គ២ ចំនួន ៥លើក (២៩៧រូប) វគ្គ Retreat ចំនួន ១លើក នៅរមណីយដ្ឋានវប្បធម៌ធម្មជាតិភ្នំគូលែន (៩០រូប) ដើម្បីបណ្តុះថាមពលផ្លូវចិត្ត និងវគ្គសង្គ្រោះបឋមចំនួន ២លើក (២៥០រូប)។ វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងដោយមានកិច្ចសហការជាមួយគ្រូឧទ្ទេសនាមជាតិ និងអន្តរជាតិដែលមានបទពិសោធខ្ពស់លើការបណ្តុះថាមពលផ្លូវចិត្ត និងរឹតចំណងមិត្តភាពរវាងមន្ត្រី-បុគ្គលិក។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់ចំពោះនិវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយបានសម្របសម្រួលផ្តល់ប្រាក់សោធននិវត្តន៍ជូនមន្ត្រី-បុគ្គលិកដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ចំនួន ៣៩រូប ផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រួសារនិវត្តជនដែលទទួលមរណភាពចំនួន ៣រូប ផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់សោធននិវត្តន៍ជូនគ្រួសារមន្ត្រី-បុគ្គលិកដែលទទួលមរណភាពចំនួន ២រូប ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រី-បុគ្គលិកជាស្ត្រីដែលបានសម្រាលកូនចំនួន ៥២រូប និងបំពេញការងារផ្សេងៗទៀតពាក់ព័ន្ធនឹងសមាគម មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា។

## គ- វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ (វ.ប.ធ.) បាននិងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង ជំនាញគ្រប់គ្រងធនាគារ។ នាឆ្នាំសិក្សា២០២៥នេះ វ.ប.ធ. បានរៀបចំធ្វើការប្រឡងជ្រើសរើសនិស្សិតចូលរៀនចំនួន ២៥៥រូប ក្នុងនោះមាននិស្សិតនិទ្ទេស A ចំនួន ៨៧រូប (ស្រី ៦៥រូប)។ នៅពេលបច្ចុប្បន្ននេះ វ.ប.ធ. មាននិស្សិតកំពុងសិក្សាចំនួន ៥ ជំនាន់ គឺថ្នាក់បរិញ្ញាបត្ររងជំនាញគ្រប់គ្រងធនាគារជំនាន់ទី៣៤ និងទី៣៥ និងថ្នាក់បរិញ្ញាបត្រជំនាន់ទី១ ទី២ និងទី៤ ដែលមាននិស្សិតសរុបចំនួន ៥៨៨រូប (ស្រី ៤៣៨រូប) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី១ មាន ៩៤រូប (ស្រី ៦៧រូប) ជំនាន់ទី២ មាន ១០៧រូប (ស្រី ៧៥រូប) ជំនាន់ទី៤ មាន ១៩៥រូប (ស្រី ១៣៧រូប) និងថ្នាក់បរិញ្ញាបត្ររងជំនាន់ទី៣៤ មាន ១៧៥រូប (ស្រី ១៤៤រូប) និងជំនាន់ទី៣៥ មាន ១៧រូប (ស្រី ១១រូប)។ ស្របពេលជាមួយគ្នានេះដែរ និស្សិតរបស់ វ.ប.ធ. បានចូលរួមជាមួយមន្ត្រីអគ្គនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិក្នុងការធ្វើអង្កេត ស្តីពី ទំនុកចិត្តធុរកិច្ច (Business Confidence Survey) សម្រាប់តាមដានការវិវត្តនៃបរិយាកាសសេដ្ឋកិច្ចនិងវិនិយោគ ដែលជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយ សំដៅគាំទ្រនិរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទន្ទឹមគ្នានេះ វ.ប.ធ. បានអនុវត្តតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ក្នុងការទទួលនិស្សិតផ្ទេរការសិក្សាមកពីប្រទេសថៃចំនួន ៤រូប (ស្រី ៣រូប) ដែលបានរងផលប៉ះពាល់ពីការផ្ទុះអាវុធកម្ពុជា-ថៃ លើកទី១ ត្រូវបានអនុញ្ញាតឱ្យបន្តការសិក្សា និងស្នាក់នៅអន្តេវាសិកដ្ឋានរបស់ វ.ប.ធ. ចំនួន ១រូប (ស្រី ១រូប) តាមការស្នើសុំរបស់និស្សិតផងដែរ។

ក្រាហ្វ ៨៨៖ ស្ថិតិនិស្សិត
(ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ៨៩៖ ស្ថិតិសាស្ត្រាចារ្យ
(ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

មន្ត្រី-បុគ្គលិករបស់ វ.ប.ធ. មានចំនួនសរុប ៤៥រូប (ស្រី ២០រូប) និងសាស្ត្រាចារ្យមានចំនួន ៩៨រូប (ស្រី ២៣រូប) ដែលក្នុងនោះសាស្ត្រាចារ្យក្នុងប្រព័ន្ធធនាគារជាតិនៃកម្ពុជាមានចំនួន ៧២រូប (ស្រី ១៧រូប) និងសាស្ត្រាចារ្យក្រៅប្រព័ន្ធធនាគារជាតិនៃកម្ពុជា មានចំនួន ២៦រូប (ស្រី ៦រូប)។ វ.ប.ធ. បានបន្តសហការជាមួយដៃគូយុទ្ធសាស្ត្រទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិនានា ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ សមាគមបណ្ណារក្សកម្ពុជា សមាគម ACCA វិទ្យាស្ថាន Chartered Banker Institute (CBI) និងដៃគូសហការផ្សេងទៀត ដើម្បីធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ការផ្លាស់ប្តូរបទពិសោធលើការរៀបចំកម្មវិធីសិក្សា និងការបណ្តុះបណ្តាល ដូចជា៖ i/- បច្ចេកទេសក្នុងការបង្រៀន ii/- ការបង្រៀនតាមវិធីសាស្ត្រ Bloom Taxonomy និងiii/-ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ក្នុងវិស័យអប់រំជូនសាស្ត្រាចារ្យ។ ទន្ទឹមនេះ វ.ប.ធ. ក៏បានរៀបចំវគ្គបណ្តុះបណ្តាលពីការបង្ការនិងពន្លត់អគ្គិភ័យ និងការជម្លៀសខ្លួនជូនមន្ត្រី-បុគ្គលិកនិងនិស្សិត ព្រមទាំងចូលរួមរៀបចំសិក្ខាសាលានិងកិច្ចប្រជុំនានាសរុបប្រមាណ ១៣២ កម្មវិធី ដែលមានអ្នកចូលរួមជាង ២៩.០៨១រូបផងដែរ។ ម្យ៉ាងទៀត វ.ប.ធ. បានរៀបចំកម្មវិធីចុះកម្មសិក្សាជូននិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជំនាន់ទី៣២ សរុបចំនួន ៥០រូប (នៅធនាគារជាតិនៃកម្ពុជា ៤៤រូប និងនៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦រូប) ដើម្បីស្វែងយល់ពីការអនុវត្តការងារជាក់ស្តែង បន្ថែមលើការសិក្សាក្នុងថ្នាក់រៀន។

ជាមួយគ្នានេះ វ.ប.ធ. បានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររងជំនាញគ្រប់គ្រងធនាគារ។ ជាក់ស្តែង កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន (ឆ្នាំទី១) នៃថ្នាក់បរិញ្ញាបត្រជំនាញគ្រប់គ្រងធនាគាររបស់ វ.ប.ធ. ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក.) ដែលជាសក្ខីភាព និងជាការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់វិទ្យាស្ថានក្នុងការបន្តពង្រឹងគុណភាពអប់រំឱ្យកាន់តែប្រសើរឡើង ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ ការទទួលស្គាល់គុណភាពអប់រំរបស់គ.ទ.ក.នេះ គឺជាបុរេលក្ខខណ្ឌមួយដើម្បីបើកផ្លូវឱ្យ វ.ប.ធ. ឈានទៅដល់ការទទួលស្គាល់គុណភាពអប់រំកម្មវិធីសិក្សាកម្រិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងកម្រិតគ្រឹះស្ថានទាំងមូល ដែលនេះជាផែនការសកម្មភាពបន្ទាប់របស់ វ.ប.ធ.។



*បទឧទ្ទេសនាម ក្រោមប្រធានបទស្តីពី ទំនាក់ទំនងអន្តរកម្ម និងផលប៉ះពាល់នៃការវិនិយោគ លើបរិស្ថាន សង្គម និងអភិបាលកិច្ច* (ESG) *លើសេដ្ឋកិច្ចគ្មានឧស្ម័នពុល* (Zero Economy) *ក្នុងក្របខណ្ឌអាស៊ាននិងសិង្ហបុរី នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ* (IBS)



*កម្មវិធីបំប៉នចំណេះដឹងមូលដ្ឋានភាសាសញ្ញា នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥*

វ.ប.ធ. បានរៀបចំដាក់បញ្ចូលសៀវភៅសរុបចំនួន ៦៨២ក្បាល ពាក់ព័ន្ធនឹងចំណេះដឹងផ្នែកធនាគារ ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រ ទៅក្នុងបណ្ណាល័យ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។ វ.ប.ធ. ក៏បានចូលជាសមាជិកនៃសមាគមបណ្ណារក្សកម្ពុជា ដើម្បីទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរៀបចំបណ្ណាល័យដែលមានគុណភាពស្តង់ដារួម។ ក្រៅពីមុខវិជ្ជាស្នូល វ.ប.ធ. ក៏បានបញ្ចូលកម្មវិធីសិក្សាបន្ថែមមួយចំនួនទៀត ដើម្បីពង្រីកចំណេះដឹង និងបំនិនជីវិតនានា ដែលជាមូលដ្ឋានគ្រឹះនៃការរស់នៅប្រចាំថ្ងៃ ដូចជា ភាសាសញ្ញា ដំណើរទស្សនកិច្ចសិក្សា ការទស្សនាខ្សែភាពយន្តនិងការសម្តែងសិល្បៈ ថ្នាក់កីឡាតៃក្វាន់ដូ និងការអានអត្ថបទខ្លីៗ។ និស្សិតក៏ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមសន្និសីទ សិក្ខាសាលា កម្មវិធីចែករំលែកចំណេះដឹង និងកម្មវិធីប្រកួតប្រជែងនានា សរុបចំនួន ២២លើក ដើម្បីផ្តល់បន្ថែមនូវពុទ្ធិនិងឱកាសក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកជំនាញក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។



*ការទស្សនាល្ខោននិយាយរឿង៖ "ឃាតករលាក់មុខ (Hidden Killer)" នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ*




*កម្មវិធី IBS រត់ដើម្បីកុមារងាយរងគ្រោះ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ*

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

មុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច គឺជាសសរស្តម្ភមួយនៃអភិបាលកិច្ចក្នុងការគ្រប់គ្រងហានិភ័យ និងរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាឱ្យកាន់តែប្រសើរឡើង តាមរយៈការពង្រឹងការប្រតិបត្តិតាម និងការត្រួតពិនិត្យផ្ទៃក្នុង។

បច្ចុប្បន្ន វិសាលភាពសវនកម្មបានគ្របដណ្តប់លើប្រតិបត្តិការសំខាន់ៗ ដើម្បីការពារហានិភ័យ តាមរយៈការពិនិត្យលើការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីការងារ សេចក្តីណែនាំផ្សេងៗ និងភាពគ្រប់គ្រាន់នៃការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងគណនី ការចុះកិច្ចបញ្ជិកា សន្តិសុខរូបវន្ត និងសុវត្ថិភាពប្រព័ន្ធជាដើម។ ដោយឡែក ការងារសវនកម្មលើផ្នែកព័ត៌មានវិទ្យា និងហិរញ្ញវត្ថុត្រូវបានអនុវត្តដោយសវនករខាងក្រៅ។ ក្នុងគោលដៅពង្រឹងគុណភាពសវនកម្ម នីតិវិធីការងារសវនកម្មត្រូវបានពិនិត្យ និងកែសម្រួលដោយបន្ថែមលក្ខណៈវិនិច្ឆ័យដើម្បីជាមូលដ្ឋានសម្រាប់ជ្រើសរើសនាយកដ្ឋាន-អង្គភាពដែលត្រូវរងសវនកម្ម និងសម្រាប់កសាងផែនការសវនកម្មឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងស្របតាមស្តង់ដារអន្តរជាតិ។ ទន្ទឹមនេះ ការបង្កើនការយល់ដឹងរបស់សវនករត្រូវបានពង្រឹងជាបន្តបន្ទាប់ តាមរយៈការបណ្តុះបណ្តាលផ្សេងៗ រួមទាំងការសិក្សាស្វែងយល់អំពីការងារប្រតិបត្តិការរបស់នាយកដ្ឋាននានា ដូចជា នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងវាយតម្លៃហានិភ័យ នាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុ និងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់។

នាឆ្នាំ២០២៥ ការងារសវនកម្មបានអនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តចំនួន ៦ ដែលរួមមាន ខេត្តស្វាយរៀង កំពង់ចាម កំពង់ធំ បាត់ដំបង រតនគិរី និងព្រះសីហនុ ព្រមទាំងស្នាក់ការកណ្តាល ចំនួន ២ (នាយកដ្ឋានគ្រប់គ្រងទុនបម្រុង និងនាយកដ្ឋានត្រួតពិនិត្យ២)។



កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សវនកម្ម
នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តរតនគិរី

ការងារអធិការកិច្ចគ្របដណ្តប់លើការពិនិត្យផ្ទៀងផ្ទាត់សាច់ប្រាក់ក្នុងឃ្លាំង និងសារពើភ័ណ្ឌទ្រព្យសម្បត្តិ ការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់នៅគ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ព្រមទាំងការចូលរួមពិនិត្យលើដំណើរការរាប់ កាត់កម្ទេច និងដុតបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក។

លទ្ធផលនៃសវនកម្ម និងអធិការកិច្ចបង្ហាញថា ការប្រតិបត្តិរបស់សវនដ្ឋានពុំមានបញ្ហាជាសារវន្តឡើយ ដោយសារការអនុវត្តត្រឹមត្រូវស្របតាមសេចក្តីណែនាំ ស្របពេលដែលប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានភាពរឹងមាំ ដែលអាចបង្ការហានិភ័យជាយថាហេតុ។ ទន្ទឹមនេះ ការតាមដានការអនុវត្តតាមអនុសាសន៍បង្ហាញថា ក្នុងចំណោម អនុសាសន៍ ២០ មានអនុសាសន៍ ៥ ដែលអនុវត្តមិនទាន់បាន ដោយសារសវនដ្ឋានត្រូវការពេលវេលាក្នុងការរៀបចំ។

ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការងារគ្រប់គ្រងហានិភ័យរួមទាំងការធ្វើបច្ចុប្បន្នកម្មផែនការនិរន្តរភាពធុរកិច្ចសម្រាប់ប្រព័ន្ធធនាគារស្នូល និងសៀវភៅកម្រងឯកសារណែនាំ ស្តីពីប្រតិបត្តិការរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដើម្បីឱ្យស្របតាមមុខងារថ្មីៗនៃប្រព័ន្ធធនាគារស្នូល ១៤.៧ និងការផ្លាស់ប្តូរមុខងារ-ភារកិច្ចនៅតាមអគ្គនាយកដ្ឋាន និងនាយកដ្ឋានមួយចំនួន។

នាឆ្នាំ២០២៥ គណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូលបានប្រជុំចំនួន ៩លើក ដោយបានពិភាក្សាលើ៖ i/- បញ្ហាថ្មីៗពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធធនាគារស្នូល ១៤.៧ ii/- ការធ្វើបច្ចុប្បន្នកម្មសៀវភៅកម្រងឯកសារណែនាំស្តីពីប្រតិបត្តិការរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និង iii/- ការធ្វើបច្ចុប្បន្នកម្មផែនការបន្តនិរន្តរភាពធុរកិច្ចប្រព័ន្ធធនាគារស្នូល ១៤.៧។

ក្នុងគោលដៅពង្រឹងការងារគ្រប់គ្រងហានិភ័យ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសិក្សាលើការគ្រប់គ្រងហានិភ័យជាលក្ខណៈស្ថាប័នរួមទាំង ការរៀបចំក្របខណ្ឌខ្សែការពារ ៣ (Three Lines of Defence) សម្រាប់ការងារគ្រប់គ្រងហានិភ័យ ស្របតាមនិន្នាការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រតិបត្តិការធនាគារ និងស្របតាមឧត្តមានុវត្តន៍នៃធនាគារកណ្តាលទាំងក្នុងនិងក្រៅតំបន់ក៏ដូចជា ស្តង់ដាអន្តរជាតិ។



កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូល លើកទី៧៥
នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា

## ៤- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត

ប្រតិបត្តិការនៅតាមសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានបន្តពង្រឹងនិងពង្រីកជាប្រចាំ ដើម្បីចូលរួមគ្រប់គ្រងចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារ ជំរុញបរិយាបន្នហិរញ្ញវត្ថុ ការប្រើប្រាស់ប្រាក់រៀលនិងលើកកម្ពស់ការទូទាត់តាមប្រព័ន្ធបាគង ព្រមទាំងចូលរួមអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្រៅពីនេះ សាខាធនាគារជាតិនៃកម្ពុជាក៏បានចូលរួមតាមដានស្ថានភាពសេដ្ឋកិច្ចក្នុងមូលដ្ឋានដូចជា ការប្រែប្រួលថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងការអង្កេតទំនុកចិត្តធុរកិច្ច សំដៅរួមចំណែកដល់ការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

សាខាធនាគារជាតិនៃកម្ពុជា ក៏បានផ្ដល់សេវាបង់ប្រាក់និងបើកប្រាក់ជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងអង្គភាពរដ្ឋ ព្រមទាំងប្ដូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកជូនសាធារណជន ក្នុងគោលបំណងជួយសម្រួលដល់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែងាយស្រួលនិងការពារការខាតបង់ផលប្រយោជន៍របស់ប្រជាជន ស្របតាមយុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត។

**ក្រាហ្វ ៩០៖ ស្ថិតិមន្ត្រី-បុគ្គលិកសាខារាជធានី-ខេត្ត**
(គិតត្រឹមឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា

គិតត្រឹមចុងឆ្នាំ២០២៥ សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា (ស.ម.ធ) មានសមាជិកសរុប ២.៦២៣រូប ក្នុងនោះនៅស្នាក់ការកណ្ដាលចំនួន ១.៩១៦រូប (និវត្តជន ១៧១រូប) និងនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ៧០៧រូប (និវត្តជន ១៣០រូប)។

**ក្រាហ្វ ៩១៖ ការឧបត្ថម្ភរបស់ ស.ម.ធ**

(គិតជាភាគរយ, ឆ្នាំ២០២៥)




គណៈកម្មាធិការ ស.ម.ធ អាណត្តិទី១០ បានប្រជុំចំនួន ៦លើក ដោយបានពិនិត្យនិងពិភាក្សាលើរបាយការណ៍សកម្មភាពការងារ ការគ្រប់គ្រងមូលនិធិ ស.ម.ធ និងការកែសម្រួលលក្ខន្តិកៈសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា។ ទន្ទឹមនេះ ស.ម.ធ បានទទួលសមាជិកថ្មីចំនួន ១៤៩រូប និងលុបឈ្មោះសមាជិកចំនួន ១៣រូប ដែលបានលាឈប់ពីការងារនិងទទួលមរណភាព។ ស.ម.ធ បានប្រើប្រាស់ថវិកាឧបត្ថម្ភជូនសមាជិកនិងសហព័ទ្ធសមាជិកចំនួន ២១២ករណី ដែលក្នុងនោះសមាជិកនិងសហព័ទ្ធសមាជិកសម្រាលកូនចំនួន ១០៧រូប គ្រោះថ្នាក់ ២៥រូប ជំងឺធ្ងន់ធ្ងរ ៦៨រូប និងមរណភាព ១២រូប ដោយបានចំណាយថវិកាសរុបចំនួន ២១៧,១៤ លានរៀល។ លើសពីនេះ ស.ម.ធ បានចុះសួរសុខទុក្ខជាប្រចាំដល់មន្ទីរពេទ្យ និងគេហដ្ឋាន ចំពោះសមាជិកមានជំងឺផ្សេងៗ និងគ្រោះថ្នាក់ចរាចរណ៍។



*កិច្ចប្រជុំគណៈកម្មាធិការ ស.ម.ធ. ដើម្បីពិនិត្យនិងពិភាក្សាលើលក្ខន្តិកៈ ស.ម.ធ.*

*នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា*

ជារួម ការបន្តអភិវឌ្ឍធនធានមនុស្សនិងអភិបាលកិច្ច គឺជាការងារអាទិភាពសម្រាប់ធនាគារជាតិនៃកម្ពុជា ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងគុណវឌ្ឍិ និងជំនាញរបស់មន្ត្រី-បុគ្គលិក ស្របពេលដែលវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ បានបន្តដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសវិស័យធនាគារនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ការងារសវនកម្ម និងអធិការកិច្ចត្រូវបានបន្តយកចិត្តទុកដាក់ ដើម្បីធានាបាននូវអភិបាលកិច្ចល្អ។

## IX- ទំនាក់ទំនងសាធារណៈ

### ១- ការផ្សព្វផ្សាយតាមបណ្ដាញសង្គម

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារទំនាក់ទំនង ជាមួយស្ថាប័នជាតិនិងអន្តរជាតិ បណ្ដាញសារព័ត៌មាន និងសាធារណជន ដើម្បីផ្សព្វផ្សាយអំពីសកម្មភាពសំខាន់ៗក្នុងការអនុវត្តមុខងារ-ភារកិច្ចស្នូល និងការងារពាក់ព័ន្ធផ្សេងៗ តាមរយៈគេហទំព័រផ្លូវការ វេទិកាសាធារណៈ និងបណ្ដាញសង្គម ដែលរួមមាន Facebook, LinkedIn, Instagram, X, YouTube និង TikTok។ គិតត្រឹមចុងឆ្នាំ២០២៥ មាតិកាសរុបចំនួន ២៥៤ ត្រូវបានផ្សព្វផ្សាយ និងមានចំនួនទស្សនា ៣២,៥ លានដង។ បណ្ដាញសង្គមផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាមានអ្នកតាមដានចំនួន ៩០៨.៣៨៦ គណនី កើនឡើង ៩៦.១០៦ គណនី ធៀបនឹងឆ្នាំ២០២៤ រីឯសារទទួលបាននិងឆ្លើយតបមានចំនួន ១.០០៩សារ។ ទន្ទឹមនេះ សំណើនិងសំណួរពីបណ្ដាញសារព័ត៌មានជាតិនិងអន្តរជាតិ តាមរយៈអ៊ីម៉ែលសម្រាប់បទសម្ភាសន៍ជាមួយថ្នាក់ដឹកនាំក៏ដូចជាបញ្ហានានាក្នុងវិស័យធនាគារ ត្រូវបានសម្របសម្រួលនិងឆ្លើយតប ស្របពេលដែលការរៀបចំអត្ថបទផ្សព្វផ្សាយក៏ត្រូវបានអនុវត្តជាបន្តបន្ទាប់ផងដែរ។




ការផ្សព្វផ្សាយនិងបញ្ជ្រាបចំណេះដឹង ទាក់ទងនឹងហានិភ័យនៃបញ្ហាសន្តិសុខសាយប័រ និងការគំរាមកំហែងនៃបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ត្រូវបានបន្តរៀបចំជាប្រចាំ ដើម្បីបង្ការការរងគ្រោះពីព័ត៌មានក្លែងក្លាយ និងការឆបោកនានាដែលអាចនាំឱ្យខាតបង់ប្រាក់កាស និងទ្រព្យសម្បត្តិ។ ជាក់ស្ដែង សាធារណជនទទួលបានការផ្សព្វផ្សាយឱ្យបង្កើនការយល់ដឹង និងការប្រុងប្រយ័ត្នខ្ពស់ចំពោះល្បិចកលឆបោករបស់ជនទុច្ចរិតដែលបានបន្លំប្រើប្រាស់ឈ្មោះ និមិត្តសញ្ញា រូបភាពថ្នាក់ដឹកនាំ អាសយដ្ឋានអ៊ីម៉ែល និងគណនីបណ្ដាញសង្គមរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីផ្សព្វផ្សាយពីគម្រោងវិនិយោគក្លែងក្លាយ ឬទាក់ទងទៅកាន់សាធារណជនដើម្បីរែអង្គាសប្រាក់ និងបញ្ឆោះបញ្ឆូលឱ្យផ្ទេរប្រាក់ជាដើម។

ក្រៅពីនេះ អ្នកសារព័ត៌មានជាច្រើនស្ថាប័នក៏បានចូលរួមក្នុងសន្និសីទសារព័ត៌មានចំនួន ២លើក ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែទូលំទូលាយ លើប្រធានបទ៖ i/- ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និង ii/- គោលនយោបាយគ្រប់គ្រងទុនបម្រុងអន្តរជាតិ។





*សន្និសីទសារព័ត៌មានក្នុងសិក្ខាសាលាស្តីពី "ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និង ខេអេចឃ្យូអរ" នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ នៅវិមានរដ្ឋសភា*

*ជំនួបជាមួយអ្នកសារព័ត៌មាន ក្រោមប្រធានបទ "គោលនយោបាយគ្រប់គ្រងទុនបម្រុងអន្តរជាតិ" នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ*

## ២- ការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ

ការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ ជាការងារអាទិភាពមួយដែលធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់ជាប្រចាំ។ ការអនុវត្តគោលនយោបាយនានាត្រូវបានធ្វើឡើងដោយស្របតាមផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ តាមរយៈការរៀបចំយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈជាច្រើន ដូចខាងក្រោម៖

**-ការងារផ្សព្វផ្សាយចំណេះដឹងច្បាប់ និងបទប្បញ្ញត្តិ**

កម្មវិធីចែករំលែកចំណេះដឹងស្តីពី "ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ" ត្រូវបានរៀបចំឡើងនៅតាមបណ្តាសាកលវិទ្យាល័យមួយចំនួន និងសាខាធនាគារជាតិនៃកម្ពុជាខេត្តព្រះសីហនុ កំពង់ចាម បាត់ដំបង សៀមរាប ក្រចេះ កំពង់ស្ពឺ និងវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ។ កម្មវិធីចែករំលែកចំណេះដឹងនេះមានគោលបំណងផ្សព្វផ្សាយ និងបង្កើនចំណេះដឹងអំពីច្បាប់និងបទប្បញ្ញត្តិ និងប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យធនាគារ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ប្រភេទគ្រឹះស្ថាននិងសេវាហិរញ្ញវត្ថុផ្លូវការ ស្ថានភាពកម្ចីខុសច្បាប់ និងការឆបោកផ្នែកហិរញ្ញវត្ថុ ប្រាក់រៀលនិងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ប្រព័ន្ធបាគង និងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់សេវាហិរញ្ញវត្ថុ ជូននិស្សិត-សាស្ត្រាចារ្យមកពីគ្រឹះស្ថានឧត្តមសិក្សា និងមន្ត្រី-បុគ្គលិកនៅសាខាធនាគារជាតិនៃកម្ពុជា សរុបប្រមាណ ៥.២០០ រូប។





*កម្មវិធីចែករំលែកចំណេះដឹងស្តីពី "ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ" បានរៀបចំនៅសាកលវិទ្យាល័យមួយចំនួន និងសាខាធនាគារជាតិនៃកម្ពុជា ក្នុងខេត្តកំពង់ចាម ព្រះសីហនុ បាត់ដំបង សៀមរាប ក្រចេះ និងកំពង់ស្ពឺ*

-ការងារពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ

សិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលធាតុចូល ស្តីពី "ការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ" ត្រូវបានរៀបចំឡើងនៅក្នុងឃុំឈូក និងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ក្នុងគោលបំណង៖ i/- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និង អាជ្ញាធរពាក់ព័ន្ធអំពីបញ្ហានៃកម្ចីខុសច្បាប់ ii/- ស្វែងយល់ពីស្ថានភាពរបស់ប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងកម្ចីខុសច្បាប់ iii/-ជំរុញការប្រើប្រាស់ឥណទានផ្លូវការ ប្រកបដោយការទទួលខុសត្រូវ និង iv/-ប្រមូលធាតុចូលសំខាន់ៗ ពាក់ព័ន្ធនឹងការប្រើប្រាស់កម្ចីខុសច្បាប់។ សិក្ខាសាលានេះមានការចូលរួមពីអភិបាល នៃគណៈអភិបាលស្រុកប្រាសាទសំបូរ ប្រធាននិងអនុប្រធានភូមិ ព្រមទាំងប្រជាជនតាមមូលដ្ឋានសរុប ១២៣រូប។



*សិក្ខាសាលាផ្សព្វផ្សាយនិងប្រមូលធាតុចូល ស្តីពី "ការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ" នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥ នៅឃុំសំបូរ និងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ*

គម្រោងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍ បានចូលរួមចំណែកយ៉ាងសំខាន់ដើម្បីពង្រឹងសុវត្ថិភាពក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនៅតាមសហគមន៍ ដែលស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។ ក្នុងទិសដៅនេះ គ្រូបង្គោលចំនួន ៥៩រូប នៅតាមសហគមន៍ ត្រូវបានពង្រឹងសមត្ថភាពបន្ថែម និងមុខវិជ្ជាចំនួន ៥ ត្រូវបានបង្កើតឡើង ហើយការផ្សព្វផ្សាយការលើកកម្ពស់ចំណេះដឹងជាសាធារណៈដំណាក់កាលទី១ ដែលមានរយៈ-ពេលប្រមាណជាង ២ឆ្នាំត្រូវបានរៀបចំឡើងចំនួន ១.២៤២លើក ដោយមានអ្នកចូលរួមសរុប ២៩.៣៥៣រូប (ស្ត្រី ២២.១៣៦រូប) ដែលជាកសិករ និងម្ចាស់អាជីវកម្មខ្នាតតូច។ ដើម្បីតាមដានវឌ្ឍនភាព សមិទ្ធផល ផលប៉ះពាល់



*មន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមសិក្ខាសាលាចុះបញ្ចាំងរបស់គម្រោងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍ នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ*

ដំណោះស្រាយ និងរៀបចំផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់ គណៈកម្មាធិការកណ្តាលត្រូវបានបង្កើតឡើង ក្នុងគោលដៅត្រួតពិនិត្យ និងតាមដានការអនុវត្តជាប្រចាំ ព្រមទាំងសម្របសម្រួល និងបំពាក់បំប៉នគ្រូបង្គោលបន្ថែម។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងរៀបចំកម្មវិធីសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍ ជំហានទី២ នៅទីតាំងគោលដៅចំនួន ៤ រួមមាន៖ i/- ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ii/- ឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង iii/- ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និង iv/- ឃុំល្អក់ ស្រុកអូរជុំ ខេត្តរតនគិរី។

**-ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

ទិវាសន្សំអាស៊ាន លើកទី៦ ក្រោមប្រធានបទ "សន្សំប្រាក់ដោយភាពវៃឆ្លាត សន្សំប្រាក់ដោយក្តីស្រឡាញ់" ត្រូវបានរៀបចំឡើងនៅក្រុងកំពត ខេត្តកំពត ដែលមានអ្នកចូលរួមប្រមាណ ៦៧៤ នាក់។ ទិវាសន្សំអាស៊ានដែលត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនាថ្ងៃទី៣១ ខែតុលា គឺជាការផ្តួចផ្តើម របស់ប្រទេសជាសមាជិកអាស៊ាន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង របស់សាធារណជន អំពីសារៈសំខាន់នៃការសន្សំប្រាក់ សំដៅជំរុញបរិយាបន្នហិរញ្ញវត្ថុ នៅក្នុងប្រទេសជាសមាជិក។ ទិវានេះរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដែលជាប្រយោជន៍ ដល់សិស្សានុសិស្ស និងសាធារណជន ដូចជា៖ i/- ការប្រកួតប្រជែង របស់សិស្សានុសិស្ស មកពីវិទ្យាល័យក្នុងខេត្ត ដើម្បីបំផុសនិងជំរុញវប្បធម៌សន្សំប្រាក់ ii/- កិច្ចពិភាក្សារបស់វាគ្មិនជំនាញ មកពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អំពីសារៈសំខាន់នៃ "ទម្លាប់នៃការសន្សំប្រាក់" និង iii/- ការតាំងពិព័រណ៍អំពីផលិតផលនិងសេវាកម្មសន្សំ របស់គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្លូវការដល់សាធារណជន ដើម្បីជំរុញឱ្យមានទម្លាប់នៃការសន្សំ និងបង្កើនទំនុកចិត្តក្នុងការប្រើប្រាស់សេវាហិញ្ញវត្ថុ ជាពិសេសការសន្សំនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្លូវការ។



*ធនាគារជាតិនៃកម្ពុជា រៀបចំ ទិវាសន្សំអាស៊ាន ក្រោមប្រធានបទ "សន្សំប្រាក់ដោយភាពវៃឆ្លាត សន្សំប្រាក់ដោយក្តីស្រលាញ់" នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ នៅក្រុងកំពត ខេត្តកំពត*

សិក្ខាសាលាស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" ត្រូវបានរៀបចំឡើងនៅតាមមូលដ្ឋានសម្រាប់ថ្នាក់ខេត្តចំនួន ៥ (តាកែវ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ និងកំពង់ឆ្នាំង) ដែលមានអ្នកចូលរួមសរុបចំនួន ៩៩៣រូប និងថ្នាក់ក្រុង-ស្រុកចំនួន ៥ (ក្រុងឧដុង្គម៉ែជ័យ ស្រុកសន្ទុក ស្រុកប្រាសាទសំបូរ ស្រុកក្រគរ និងស្រុកទឹកផុស) ដែលមានអ្នកចូលរួមសរុបចំនួន ១.១៦២រូប។ សិក្ខាសាលានេះ មានគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងកិច្ចការពារអតិថិជន ដោយមានវាគ្មិនជំនាញមកពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ពិភាក្សានិងបកស្រាយពីចម្ងល់ក៏ដូចជាដោះស្រាយបញ្ហាប្រឈមរបស់ភាគីពាក់ព័ន្ធ។ ចំណុចសំខាន់ៗ និងបញ្ហាប្រឈមនៅតាមមូលដ្ឋាន ត្រូវបានប្រមូលចងក្រងជាធាតុចូលសម្រាប់ធ្វើបច្ចុប្បន្នកម្មគោលនយោបាយ ដែលធានាផលប្រយោជន៍របស់អតិថិជន និងគ្រឹះស្ថាន។



*សិក្ខាសាលា ស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" សម្រាប់អាជ្ញាធរពាក់ព័ន្ធនៅតាមមូលដ្ឋា នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ នៅក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ*

ការលើកកម្ពស់ ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងសហគ្រិនភាពស្ត្រី គឺជាការងារអាទិភាពមួយ របស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជា បានរួមចំណែកផ្តល់ធាតុចូល លើការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ ឬក្របខណ្ឌគោលនយោបាយ ស្តីពី "បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" និងបានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី "តោះ!និយាយអំពីហិរញ្ញវត្ថុ និងឌីជីថល" លើកទី៣ ក្រោមប្រធានបទ "ស្ថិរភាពហិរញ្ញវត្ថុ និងការរីកចម្រើនរយៈពេលវែង" ដែលរៀបចំឡើង ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី (WEDC) នៃក្រសួងកិច្ចការនារី ក្នុងគោលបំណងពង្រីកវិសាលភាពចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាពិសេសការត្រៀមខ្លួនក្នុងការរៀបចំហិរញ្ញវត្ថុ សម្រាប់ស្ថិរភាពអាជីវកម្មជូនដល់សហគ្រិនស្ត្រីផងដែរ។




*ធនាគារជាតិនៃកម្ពុជា ចូលរួមក្នុងកម្មវិធី "តោះ! និយាយអំពីហិរញ្ញវត្ថុ និងឌីជីថល" លើកទី៣ នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី*

ក្រោមកិច្ចគាំទ្រពីធនាគារជាតិនៃកម្ពុជា សភាយុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ខេត្តស្វាយរៀង បានបន្តអនុវត្តគម្រោង "រៀនពីលុយ ៣.០" តាមរយៈការចូលរួមរៀបចំខ្លឹមសារមេរៀន ក៏ដូចជាចុះបង្រៀន និងផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធនឹង៖ i/-មុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ii/-ប្រព័ន្ធធនាគារនៅកម្ពុជា iii/-ការការពារខ្លួនពីការឆបោកផ្នែកហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា និង iv/-ផលប៉ះពាល់នៃកម្ចីខុសច្បាប់ ដល់សិស្សានុសិស្សសរុបចំនួន ២០៦រូប មកពីវិទ្យាល័យចំនួន ៩ នៃរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តតាកែវ។ គម្រោងនេះមានគោលដៅរួមចំណែកលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់យុវជន ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងការរៀបចំផែនការហិរញ្ញវត្ថុសម្រាប់អនាគត។





*ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគម្រោង "រៀនពីលុយ ៣.០" តាមរយៈការចូលរួមរៀបចំខ្លឹមសារមេរៀន ក៏ដូចជា ចុះបង្រៀន និងផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធវិស័យធនាគារនិងហិរញ្ញវត្ថុ*

### ៣- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ

ធនាគារជាតិនៃកម្ពុជាបន្តសហការយ៉ាងជិតស្និទ្ធជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងការតាមដាន និងស្វែងយល់អំពីស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា បញ្ហាប្រឈមក៏ដូចជាហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ព្រមទាំងចូលរួមស្វែងរកដំណោះស្រាយនានា ក្នុងវិស័យធនាគារ និងវិស័យពាក់ព័ន្ធ។

### ៤- ការផ្សព្វផ្សាយប្រព័ន្ធបាគង បាគងទេសចរ និងបាគងយុវ័ន

ដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធបាគង បាគងទេសចរ និងបាគងយុវ័ន ឱ្យកាន់តែទូលំទូលាយថែមទៀត ធនាគារជាតិនៃកម្ពុជាបានរៀបចំការតាំងស្តង់ពិព័រណ៍នៅក្នុងកម្មវិធីថ្នាក់ជាតិ-អន្តរជាតិ និងថ្នាក់មូលដ្ឋាន ព្រមទាំងផលិតវីដេអូខ្លីបែបអប់រំរួមផ្សំនឹងការកម្សាន្តជាច្រើន។

*យូអរកូដសម្រាប់ស្កេនចូលទៅទស្សនាវីដេអូផ្សព្វផ្សាយរបស់ "បាគង"*

ជាក់ស្តែង កិច្ចសហការជាមួយក្រសួង-ស្ថាប័ននានា ត្រូវបានអនុវត្តក្នុងការរៀបចំពិព័រណ៍ក្នុងវេទិកាថ្នាក់ជាតិ ដែលរួមមាន៖ i/- ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា លើកទី១៨ ii/- វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥ iii/- ពិព័រណ៍ការងារ និងផលិត-ភាពជាតិ ២០២៥ "ខ្មែរធ្វើបាន៖ ចូលរួមជំរុញ និងគាំទ្រផលិតផលក្នុងស្រុក" iv/- ជំនាញសិក្សា និងការងារឆ្នាំ២០២៥ v/- ការកសាងទំនុកចិត្តក្នុងយុគសម័យបញ្ញាសិប្បនិម្មិត vi/- ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា vii/- Natas Travel 2025 – Singapore និង viii/- ព្រឹត្តិការណ៍សាទរកម្ពុជាជាដើម។

ទន្ទឹមនេះ ការប្រើប្រាស់បាគងទេសចរ និងការបញ្ជាក់អត្តសញ្ញាណ (KYC) ត្រូវបានចុះផ្សព្វផ្សាយបន្ថែមទៀត ដោយមានការសហការពីស្ថាប័នពាក់ព័ន្ធ ភ្នាក់ងារទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ សមាគមន៍សណ្ឋាគារ ក្រុមហ៊ុនអាកាសចរណ៍ និងសមាជិកបាគង។ ធនាគារជាតិនៃកម្ពុជាបានចុះផ្សព្វផ្សាយ និងបញ្ជ្រាបការប្រើប្រាស់កម្មវិធីបាគងយុវ័ន ដល់សិស្សានុសិស្សនៅតាមវិទ្យាល័យក្នុងខេត្តកំពង់ធំ និងបន្តផ្សព្វផ្សាយលើកកម្ពស់ការអប់រំជំនាញឌីជីថលដោយបានផ្តល់វគ្គជំនាញមូលដ្ឋានគ្រឹះនៃការសរសេរកូដ (Computer Programming) ជូនដល់សិស្សានុសិស្សមកពីវិទ្យាល័យ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ និងការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ នៅការិយាល័យច្រកចេញចូលតែមួយ ក្នុងទិសដៅបង្កើនការប្រើប្រាស់ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការយល់ដឹងពីអត្ថប្រយោជន៍នៃប្រព័ន្ធបាគង និងខេអេចយូអរ ដែលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការទូទាត់តាមបែបឌីជីថល សំដៅជួយជំរុញកំណើនសេដ្ឋកិច្ច។ ជាលទ្ធផល ការចុះឈ្មោះប្រើប្រាស់កម្មវិធីទូទាត់បាគងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដល់ប្រមាណ ២៦.៨៤៤ គណនី ក្នុងឆ្នាំ២០២៥។

ដើម្បីរួមចំណែកក្នុងការជំរុញកំណើនទេសចរមកទស្សនាប្រទេសកម្ពុជា និងទទួលបានអត្ថប្រយោជន៍ពីការទូទាត់បែបឌីជីថល ដែលមានលក្ខណៈងាយស្រួល រហ័ស និងសុវត្ថិភាព ធនាគារជាតិនៃកម្ពុជាសហការជាមួយស្ថាប័នពាក់ព័ន្ធ បានចូលរួមផ្សព្វផ្សាយពីការប្រើប្រាស់បាគងទេសចរដល់ភ្ញៀវទេសចរអន្តរជាតិ និងទទួលបានការចុះឈ្មោះប្រើប្រាស់កម្មវិធីទូទាត់បាគងទេសចរចំនួនប្រមាណ ២២.១៣៤ គណនី។ លើសពីនេះ ការផ្សព្វផ្សាយកម្មវិធីទូទាត់បាគង

យុវ័ន និងតម្លើងបាគងយុវ័ន ត្រូវបានរៀបចំឡើងសម្រាប់សិស្សានុសិស្សនៅតាមវិទ្យាល័យមួយចំនួនក្នុងស្រុកសន្ទុក និងក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ព្រមទាំងទទួលបានការចុះឈ្មោះប្រើប្រាស់កម្មវិធីទូទាត់បាគងយុវ័នចំនួនប្រមាណ ១.៧៥៣ គណនីផងដែរ។



ការចូលរួមការតាំងពិព័រណ៍ផលិតផលខ្មែរ "ខ្មែរធ្វើបាន៖ ចូលរួម ជំរុញ និងគាំទ្រផលិតផលក្នុងស្រុក" ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ



ក្រុមការងារបាគង ផ្តល់ការបណ្តុះបណ្តាលលើជំនាញមូលដ្ឋានគ្រឹះនៃការសរសេរកូដ (Computer Programming) ជូនដល់សិស្សានុសិស្សតាមវិទ្យាល័យ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

## ៥- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល

កម្មវិធីផ្សព្វផ្សាយស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ" ត្រូវបានរៀបចំនៅរាជធានី-ខេត្តចំនួន ៦ រួមមាន៖ រាជធានីភ្នំពេញ តាកែវ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ និងកំពង់ឆ្នាំង ដោយមានពិព័រណ៍ស្តីពីប្រវត្តិរូបិយវត្ថុកម្ពុជា ការតាំងបង្ហាញពីប្រព័ន្ធទូទាត់បាគងនិងខេអេចឃ្យូអរ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក យកក្រដាសប្រាក់រៀលថ្មី ការប្រកួតប្រជែងធ្វើបទបង្ហាញរបស់សិស្សានុសិស្សលើមូលបទស្តីពីសារៈសំខាន់នៃប្រាក់រៀល និងការប្រកួតប្រជែងផលិតមាតិកាវីដេអូខ្លីក្រោមប្រធានបទ "តើប្រាក់ ១០.០០០រៀលអាចទិញអ្វីបានខ្លះ?"។ កម្មវិធីនេះមានអ្នកចូលរួមទស្សនាដោយផ្ទាល់និងតាមបណ្តាញសង្គម សរុបជាង ៣៣០ ពាន់នាក់។ នាឱកាសនោះ សាធារណជនក៏បានយកក្រដាសប្រាក់រៀលចាស់ ទក់ រហែក មកប្តូរក្រដាសប្រាក់ថ្មីដោយឥតគិតថ្លៃប្រមាណ ១៦៨,២ លានរៀល។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការផ្សព្វផ្សាយនូវអត្ថបទពាក់ព័ន្ធនឹងសារៈសំខាន់នៃប្រាក់រៀលនៅតាមសារព័ត៌មាននានាផងដែរ។ គួររំលេចថា ការផលិតវីដេអូ "តើប្រាក់ ១០.០០០រៀល អាចទិញអ្វីបានខ្លះ?" បានផ្តល់អត្ថប្រយោជន៍បន្ថែមដូចជា៖ i/-បង្កើនវិសាលភាពក្នុងការផ្សព្វផ្សាយពីប្រាក់រៀលបានកាន់តែទូលំទូលាយ ដោយបានទាក់ទាញវីដេអូប្រកួតប្រជែងចំនួន ១០១ វីដេអូ និងចំនួនចូលទស្សនាសរុបជាង ២,១ លានដង ii/-បំផុសគំនិតសាធារណជនជាពិសេសយុវជនឱ្យយល់ដឹងបន្ថែមទៀតពីសារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និង iii/-បង្ហាញពីស្ថានភាពអតិផរណា និងអំណាចទិញនៃប្រាក់រៀលនៅតាមតំបន់នីមួយៗជាដើម។

ឃ្យូអរកូដសម្រាប់ស្កេនចូលទៅមើលរូបថត កម្មវិធីផ្សព្វផ្សាយស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយរដ្ឋសភា រៀបចំសិក្ខាសាលាស្តីពី "ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ" នៅវិមានរដ្ឋសភា ក្នុងឱកាសអបអរសាទរខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ក្រោមអធិបតីភាព ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ នៃរដ្ឋសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ ព្រឹទ្ធសភា ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និង លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។ សិក្ខាសាលានេះមានគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលនៅក្នុងសង្គមនិងសេដ្ឋកិច្ចកម្ពុជា ព្រមទាំងតួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។







*សិក្ខាសាលាស្តីពី "ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ" ក្នុងឱកាសអបអរសាទរខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា*

## ៦- ការចូលរួមជាវាគ្មិន និងការទទួលពានរង្វាន់លំដាប់អន្តរជាតិ

លោកជំទាវបណ្ឌិត ជា សិរី ត្រូវបានទស្សនាវដ្តីអន្តរជាតិ Global Finance ផ្តល់ចំណាត់ថ្នាក់ A- ជាអ្នកដឹកនាំធនាគារកណ្តាល ប្រកបដោយប្រសិទ្ធភាពនៅលើពិភពលោក ២លើកជាប់គ្នា (ឆ្នាំ២០២៤ និងឆ្នាំ២០២៥) ដោយទទួលបានការវាយតម្លៃខ្ពស់ លើប្រសិទ្ធភាពនៃការងារក្នុងការគ្រប់គ្រងអតិផរណា អត្រាប្តូរប្រាក់ និងការអភិវឌ្ឍប្រព័ន្ធធនាគារ។




*លោកជំទាវបណ្ឌិត ជា សិរី បានទទួលចំណាត់ថ្នាក់ A- ជាអ្នកដឹកនាំធនាគារកណ្តាលមានប្រសិទ្ធភាពនៅលើពិភពលោក ជាលើកទី២ ពីទស្សនាវដ្តីអន្តរជាតិ Global Finance នាខែសីហា ឆ្នាំ២០២៥*

ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសចែករំលែកបទពិសោធ គន្លឹះ នៅក្នុងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ ដូចជា៖ i/- វេទិកាបូអាវសម្រាប់អាស៊ី (Boao Forum for Asia) ចំនួន ២លើក នៅខេត្តហៃណាន ប្រទេសចិន ii/- វេទិកាតុមូលស្តីពី "ប្រព័ន្ធទូទាត់ឆ្លងដែន៖ ពីការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ការប្រើប្រាស់ដោយរលូន របស់អតិថិជន" នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី iii/- វេទិកាហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ឆ្លងដែនលើក ទី៣២ នៅទីក្រុងក្យូតូ ប្រទេសជប៉ុន iv/- កិច្ចពិភាក្សាស្តីពី "តើអាស៊ាន+៣ អាចជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ឱ្យកាន់តែរីកចម្រើនបន្ថែមទៀតយ៉ាងដូចម្តេច?" នៅទីក្រុងក្យូតូ ប្រទេសជប៉ុន v/- សន្និសីទ Banking Summit Asia នៅទីក្រុងហុងកុង ប្រទេសចិន vi/- វេទិកាហិរញ្ញវត្ថុអាស៊ីលើកទី៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន vii/- កិច្ចពិភាក្សាតុមូលស្តីពី "ស្ត្រីដ៏មានឥទ្ធិពល និងស្ត្រីដ៏សកម្ម" នៅវិទ្យាស្ថានបារាំងនៅកម្ពុជា viii/- កិច្ចពិភាក្សានៃកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ix/- កិច្ចពិភាក្សាធុរកិច្ច អាស៊ាន Bloomberg នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី x/- វេទិកាជំនាញសម្រាប់អនាគត នៅប្រទេសសិង្ហបុរី និង xi/- ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី នៅប្រទេសសិង្ហបុរី ជាដើម។




*លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងកិច្ចពិភាក្សាស្តីពី "កិច្ចសន្ទនាគោលនយោបាយសកល៖ ដំណើរឆ្ពោះទៅទសវត្សរ៍នៃការផ្លាស់ប្តូរ និងច្រកបៀងហិរញ្ញវត្ថុថ្មី" ក្នុងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅប្រទេសសិង្ហបុរី*

ប្រធានបទសំខាន់ៗ ដែលបានចែករំលែកក្នុងព្រឹត្តិការណ៍អន្តរជាតិខាងលើ មានដូចជា កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិកហិរញ្ញវត្ថុអន្តរកាល សម្រាប់អនាគតនៃការបន្ថយឧស្ម័នកាបូនិចដល់កម្រិតសូន្យ តួនាទីធនាគារកណ្តាលលើចំណេះដឹងផ្នែកហិរញ្ញវត្ថុ បរិយាបន្នហិរញ្ញវត្ថុ និងបរិវត្តកម្មឌីជីថល ការផ្សារភ្ជាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ ទំនុកចិត្ត និងបទប្បញ្ញត្តិ ការបង្កើនអំណាចដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងតំបន់អាស៊ាន ដើម្បីជំរុញការរីកចម្រើនក្នុងសេដ្ឋកិច្ចឌីជីថល ការផ្តោតលើកិច្ចការធនាគារកណ្តាល៖ អតិផរណា ភាពមានការងារធ្វើ និងរូបិយប័ណ្ណ ស្ត្រីទូទាំងសកលលោកក្នុងសម័យបច្ចេកវិទ្យាសិប្បនិម្មិត និងកិច្ចសន្ទនាគោលនយោបាយសកល៖ ដំណើរឆ្ពោះទៅទសវត្សរ៍នៃការផ្លាស់ប្តូរ និងច្រកបៀងហិរញ្ញវត្ថុថ្មី ជាដើម។

*យូអរកូដសម្រាប់ស្កេនចូលទៅមើលសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាក្នុងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ*

ថ្នាក់ដឹកនាំបានផ្តល់កិច្ចសម្ភាសន៍ដល់ស្ថាប័នសារព័ត៌មានដែលរួមមាន ទូរទស្សន៍ Bloomberg លើប្រធានបទផលប៉ះពាល់នៃពន្ធបដិការមកលើសេដ្ឋកិច្ចកម្ពុជា និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្ម និងលើកកម្ពស់ភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា និងសារព័ត៌មានចិន China Xinhua News ស្តីពីកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសចិន ជាដើម។

## ៧- ការរួមចំណែកក្នុងការងារសង្គម

ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការងារសង្គម សប្បុរសធម៌ និងអភិវឌ្ឍន៍នានា នៅក្នុងវិស័យសំខាន់ៗជាច្រើន។ ជាក់ស្តែង ក្នុងវិស័យអប់រំ ធនាគារជាតិនៃកម្ពុជាបាន សម្ពោធដាក់ឱ្យប្រើប្រាស់អគារបណ្ណាល័យ សម្ពោធផ្លូវបេតុងនៅវិទ្យាល័យហ៊ុន សែន ព្រៃក្តី ក្នុងឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ប្រគល់អគារបន្ទប់ទឹកស្អាតនៅតាមសាលារៀន និងរៀបចំវគ្គបណ្តុះបណ្តាលដល់សិស្សានុសិស្ស ១.២០០រូប លើមូលដ្ឋានគ្រឹះនៃការសរសេរកូដ (Computer Programming) រៀបចំសិក្ខាសាលាអំពីផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ ជាដើម។



*លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី "ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា" នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ នៅស្រុកសន្ទុក ខេត្តកំពង់ធំ*

ទន្ទឹមនេះ នៅក្នុងវិស័យសុខាភិបាល ធនាគារជាតិនៃកម្ពុជា បានសហការជាមួយអង្គការជំនួយមនុស្សធម៌សុខភាព អូស្ត្រាលី (Australian Health Humanitarian Aid - AHA) និង Khmer Sight Foundation ពិនិត្យជម្ងឺទូទៅ ពិនិត្យភ្នែក និងវះកាត់ជំងឺភ្នែកឡើងបាយ និងកន្ទុយថ្លែនដោយឥតគិតថ្លៃ នៅមន្ទីរពេទ្យខ្មែរ-សូវៀត សម្រាប់ប្រជាពលរដ្ឋក្រីក្រ សម្របសម្រួលឱ្យក្រុមគ្រូពេទ្យស្ម័គ្រចិត្តពី Humanitarian with Love (Singapore) Khmer Sight Foundation និង HOPE Cambodia ចុះពិនិត្យ និងព្យាបាលជម្ងឺភ្នែក-ត្រចៀកដោយឥតគិតថ្លៃ នៅស្រុកសន្ទុក ខេត្តកំពង់ធំ ព្រមទាំងសម្ពោធដាក់ឱ្យប្រើប្រាស់អគារមន្ទីរពេទ្យបង្អែកស្ទោង ផងដែរ។



*លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលមកទទួលការវះកាត់ជម្ងឺភ្នែកឡើងបាយ និងកន្ទុយថ្លែនដោយឥតគិតថ្លៃ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមលើកកម្ពស់សាសនា អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផ្សព្វផ្សាយផលិតផល ដែលរួមមានដូចជា ការចូលរួមឧបត្ថម្ភគម្រោងកសាងមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានានៅក្នុងវត្តឧណ្ណាលោម វេរប្រគេនអគារសិក្សាថ្មីដល់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងចូលរួមឧបត្ថម្ភពិព័រណ៌ផលិតផលខ្មែរ ក្រោមប្រធានបទ "ខ្មែរធ្វើបាន៖ ចូលរួមជំរុញ និងគាំទ្រផលិតផលក្នុងស្រុក" ជាដើម។



ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ សម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានានៅក្នុងវត្តឧណ្ណាលោម ក្នុងសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញសំណេះសំណាល អបអរសាទរ និងផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សានុសិស្ស ដែលបានប្រឡងជាប់ជាស្ថាពរ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០២៤-២០២៥ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ នៅស្រុកសន្ទុក ខេត្តកំពង់ធំ



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារបណ្ណាល័យវិទ្យាល័យតាអោក នាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ នៅឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

## ៨- សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្ស៊ីសានវរ័ន (ស.ស.រ.)

ភ្ញៀវអញ្ជើញមកទស្សនាសារមន្ទីរ ស.ស.រ. សរុបមានចំនួន ៤៣.៤៨៥នាក់ (ថយចុះ -១៦% ធៀបនឹងឆ្នាំ២០២៤) ក្នុងនោះភ្ញៀវបរទេសមាន ២១% និងភ្ញៀវជាសិស្សានុសិស្ស និស្សិត និងកុមារមាន ៤២%។ ទន្ទឹមនេះ សារមន្ទីរ ក៏បានទទួលបដិសណ្ឋារកិច្ចឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិដែលរួមមាន៖ i/-ឯកឧត្តម Masato Kanda ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ii/-ឯកឧត្តម យស ផានីត្តា ប្រធានគណៈកម្មការទី២ នៃគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសវនកម្ម នៃព្រឹទ្ធសភា iii/-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី iv/-ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ v/-លោកជំទាវ Nguyen Thi Hong ទេសាភិបាលនៃធនាគាររដ្ឋវៀតណាម vi/-ឯកឧត្តម Aivo H. Andrianarivelo ទេសាភិបាលធនាគារកណ្តាលម៉ាដាហ្គាស្កា vii/-លោកជំទាវ Bounkham Vorachit ទេសាភិបាល ធនាគារកណ្តាលឡាវ viii/-លោកជំទាវ Phonevanh Outhavong អនុរដ្ឋមន្ត្រីក្រសួងផែនការ និងវិនិយោគនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ix/-លោកស្រី Kanni Wignaraja ឧបការីអគ្គលេខាធិការនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងជាប្រធាន UNDP ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក និង x/-ឯកឧត្តម Olivier Richard ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំកម្ពុជា។



*ដំណើរទស្សនកិច្ច ឯកឧត្តម Masato Kanda ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ នៅ ស.ស.រ.*



*ដំណើរទស្សនកិច្ច លោកស្រី Kanni Wignaraja ឧបការីអគ្គលេខាធិការនៃ UNDP និងជាប្រធាន UNDP ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ នៅ ស.ស.រ.*

**ក្រាហ្វ ៩២៖ ចំនួនភ្ញៀវទស្សនាសរុប**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស.ស.រ. បានបន្តកិច្ចសហប្រតិបត្តិការជាមួយនឹងសមាគមធនាគារនៅកម្ពុជា ក្នុងការឧបត្ថម្ភដល់សិស្សានុសិស្សនៃគ្រឹះស្ថានសិក្សារដ្ឋមកទស្សនា សារមន្ទីរមានចំនួនសរុប ៥.៧៤១នាក់ មកពីរាជធានីភ្នំពេញ និងតាមបណ្តាខេត្តដូចជា ខេត្តរតនគិរី ក្រចេះ ស្ទឹងត្រែង និងកំពង់ចាម។ ដោយឡែកចំពោះការងាររៀបចំសារមន្ទីរបាត់ដំបងក៏បានបន្តតាមការគ្រោងទុកផងដែរ។ បន្ថែមពីនេះ ស.ស.រ. បានសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ក្រោមប្រធានបទ "ការលេចត្រដែតឡើងវិញ៖ ការបាត់បង់ និងការរកឃើញឡើងវិញនូវគំនូរក្នុងព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង" ដែលពិព័រណ៍នេះនឹងដាក់តាំងបង្ហាញជូនសាធារណជនរយៈពេល ៥ខែ រហូតដល់ខែកុម្ភៈ ឆ្នាំ២០២៦។ ជាមួយគ្នានេះ សារមន្ទីរ បានសហការរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍ចំនួន ៣ ប្រធានបទ ដែលរួមមាន៖ i/- Tokyo before and after ii/- Threads of Us និង iii/- រូបថត "កម្ពុជា ឆ្នាំ១៩៧២-១៩៧៥" ដោយមានភ្ញៀវចូលទស្សនាសរុបចំនួន ៤.០៤១នាក់។



សកម្មភាពសិស្សានុសិស្សមកពីគ្រឹះស្ថានអប់រំរដ្ឋ ខេត្តក្រចេះទស្សនា នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅស.ស.រ.



ការសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ថ្មីក្រោមប្រធានបទ "ការលេចត្រដែតឡើងវិញ៖ ការបាត់បង់និងរកឃើញឡើងវិញនូវគំនូរក្នុងព្រះវិហារព្រះកែវមរកត" នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ នៅសារមន្ទីរ ស.ស.រ.

នាឆ្នាំ២០២៥នេះ ស.ស.រ. ក៏បានរៀបចំសិក្ខាសាលាចំនួន ៨លើក ដោយមានវាគ្មិនជាសាស្ត្រាចារ្យស្រាវជ្រាវជាតិ និងអន្តរជាតិ ក្រោមប្រធានបទដូចជា៖ i/- ការស្រាវជ្រាវទាក់ទងទៅនឹងកាសព្រះអាទិត្យរះ ii/- ជនជាតិភាគតិចនៅកម្ពុជា iii/- ភាសាខ្មែរ iv/- ទំនប់សមុទ្រ និងកុមារភាពរបស់អ្នកនិពន្ធបារាំង Marguerite Duras v/- ទ្រឹស្តី និងការយល់ឃើញពីអតីតកាល៖ អត្ថបទប្រវត្តិសាស្ត្រ និងបញ្ញវន្តកម្ពុជា ឆ្នាំ១៨៥៥-១៩៧០ vi/- មរតកវប្បធម៌អរូបីនៅកម្ពុជា៖ បញ្ហាប្រឈម និងការប្រែប្រួលជាទូទៅ និងកិច្ចខិតខំក្នុងការការពារ vii/- កម្ពុជាលេចឡើងដំបូងក្នុងផែនទីពិភពលោក ដែលមានអ្នកចូលរួមសរុបចំនួន ៦៦៥នាក់ និង viii/- កំណាកំណើត និងការវិវត្តន៍ ស្មារតីប្រជាជាតិ និងនយោបាយជាតិពន្ធុនៅកម្ពុជា ១៨៥៥-១៩៧៨ ដែលមានអ្នកចូលរួមសរុបចំនួន ៧១១នាក់។

ក្រោមកិច្ចសហការជាមួយសារមន្ទីរនៃធនាគារកណ្តាលម៉ាឡេស៊ី និងបណ្តាសារមន្ទីរនៃធនាគារកណ្តាលអាស៊ាន ពិព័រណ៍ស្តីពី "រូបិយវត្ថុនៃប្រទេសសមាជិកអាស៊ាន" ត្រូវបានរៀបចំឡើងនៅសារមន្ទីរនៃធនាគារកណ្តាលម៉ាឡេស៊ី ដែលជាកិច្ចសហការអន្តរជាតិលើកទី១របស់ ស.ស.រ. ក្នុងការរៀបចំពិព័រណ៍នៅក្រៅប្រទេស។ បន្ថែមលើនេះ ស.ស.រ. ក៏បានអញ្ជើញចូលរួមក្នុងកម្មវិធីមហាសន្និបាតលើកទី២៧ របស់ក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ នៅទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម

ក្រោមប្រធានបទ "អនាគតនៃសារមន្ទីរនៅក្នុងសហគមន៍ ដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស"។ នៅក្នុងកម្មវិធីនេះ លោកសហប្រធានសារមន្ទីរ ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៃក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរផងដែរ។ ជាមួយគ្នានេះដែរ សារមន្ទីរ ស.ស.រ. និងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ បានចុះអនុស្សរណៈយោគយល់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរវាងស្ថាប័នទាំងពីរ។

ស.ស.រ. ក៏បានបោះពុម្ពផ្សាយនូវសៀវភៅក្រោមចំណងជើងដូចជា i/- សៀវភៅកាតាឡុក "វត្តអារាមនៅប្រទេសកម្ពុជា" ជាភាសាខ្មែរ អង់គ្លេស និងបារាំង ii/-សៀវភៅមគ្គុទេសក៍ "ការលេចត្រដែតឡើងវិញ៖ ការបាត់បង់ និងរកឃើញឡើងវិញនូវគំនូរក្នុងព្រះវិហារព្រះកែវមរកត" ជាភាសាខ្មែរ និងអង់គ្លេស និង iii/- សៀវភៅ "យើងទៅទស្សនាសារមន្ទីរ សេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន" ជាភាសាខ្មែរ។

**ជារួម ការងារទំនាក់ទំនងសាធារណៈជាផ្នែកមួយយ៉ាងសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជននិងស្ថាប័នពាក់ព័ន្ធមកលើធនាគារជាតិនៃកម្ពុជា ជាពិសេសការអនុវត្តគោលនយោបាយ និងវិធានការនានាដែលត្រូវបានដាក់ចេញ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានបន្តរៀបចំនិងពង្រឹងជាប្រចាំនូវការលើកម្ពស់ចំណេះដឹងរបស់សិស្សានុសិស្ស និងសាធារណជន តាមរយៈការចូលទស្សនា ស.ស.រ. កម្មវិធីផ្សព្វផ្សាយ សិក្ខាសាលា និងពិព័រណ៍ពាក់ព័ន្ធនឹងសកម្មភាពលើកកម្ពស់ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគងទាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត។**

## សេចក្តីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាបន្តសម្រេចបានកំណើន ប៉ុន្តែទាបជាងឆ្នាំកន្លងទៅដោយសារការប្រឈម នឹងផលប៉ះពាល់ពីកត្តាខាងក្រៅ។ អតិផរណាបន្តមានកម្រិតទាបអាចគ្រប់គ្រងបាន ស្របពេលដែល ប្រាក់រៀលមានស្ថិរភាពល្អប្រសើរជាមួយនឹងនិន្នាការឡើងថ្លៃបន្តិច។ ម្យ៉ាងទៀត ទុនបម្រុងអន្តរជាតិ ត្រូវបានបន្តគរពូនជាលំដាប់ ដែលបានពង្រឹងភាពធន់និងជំនឿទុកចិត្តរបស់វិនិយោគិនមកលើ សេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធធនាគារបន្តរួមចំណែកក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច បើទោះជាត្រូវប្រឈមនឹង ផលប៉ះពាល់ដែលបានកើតឡើងជាបន្តបន្ទាប់។ ទន្ទឹមនេះ ក្របខណ្ឌគ្រប់គ្រងហានិភ័យនិងកិច្ចការពារ អតិថិជនត្រូវបានពង្រឹង ស្របពេលដែលបរិយាបន្នហិរញ្ញវត្ថុត្រូវបានបន្តជំរុញ ជាពិសេសចំពោះ ប្រជាជននៅតាមជនបទ ស្ត្រី និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។ នវានុវត្តន៍ហិរញ្ញវត្ថុត្រូវបាន បន្តអភិវឌ្ឍទៅលើប្រព័ន្ធទូទាត់សងប្រាក់ ហើយការតភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់និង ក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិត្រូវបានពង្រីកជាបន្តបន្ទាប់។ បន្ថែមលើនេះ ហិរញ្ញវត្ថុប្រកបដោយ ចីរភាពត្រូវបានបន្តយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពធន់និងការបង្ការហានិភ័យផ្សេងៗ ចំពោះប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ កិច្ចសហប្រតិបត្តិការ អន្តរជាតិក៏ត្រូវបានបន្តធ្វើឡើងយ៉ាងប្រសើរ ដើម្បីជំរុញសមាហរណកម្មនិងពង្រឹងសំណាញ់សុវត្ថិភាព ហិរញ្ញវត្ថុ ទាំងក្នុងក្របខណ្ឌតំបន់និងពិភពលោក។

ជាមួយគ្នានេះ ក្របខណ្ឌនយោបាយរូបិយវត្ថុត្រូវបានបន្តធ្វើទំនើបកម្មដើម្បីលើកកម្ពស់ ប្រសិទ្ធភាពនៃការអនុវត្តនយោបាយ ជាពិសេសការជះឥទ្ធិពលទៅលើអត្រាការប្រាក់ទីផ្សារ ក្នុងបរិការណ៍ដែលប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយ។ ប្រតិបត្តិការរូបិយវត្ថុ និង ក្របខណ្ឌគ្រប់គ្រងសន្ទនីយភាពក៏ត្រូវបានកែសម្រួលនិងអភិវឌ្ឍជាលំដាប់ ដើម្បីរួមចំណែក សម្រួលដល់ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាត់បន្ថយហានិភ័យ រក្សាស្ថិរភាព អត្រាប្តូរប្រាក់ និងជំរុញការប្រើប្រាស់ប្រាក់រៀល។ បន្ថែមលើនេះ គុណភាពនៃការផ្តត់ផ្គង់សេវា ធនាគារកណ្តាលត្រូវបានលើកកម្ពស់ជាប្រចាំ ដើម្បីបង្កើនប្រសិទ្ធភាពអន្តរការិយកម្មរបស់គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ និងសម្រួលការប្រើប្រាស់គណនីរបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធបានចូលរួម ចំណែកយ៉ាងសកម្ម ក្នុងការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការវិភាគប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ ការពង្រឹង កិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ និងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយនានា។ ទន្ទឹមនេះ ស.ហ.ក. បានបន្តដឹកនាំនិងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធយ៉ាងយកចិត្តទុកដាក់ ក្នុងការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារ ឆ្នាំ២០២៦

## I- ទស្សនវិស័យសេដ្ឋកិច្ច

យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ សេដ្ឋកិច្ចពិភពលោកឆ្នាំ២០២៦ ត្រូវបានព្យាករថាមានកំណើន ៣,១% ទាបជាងឆ្នាំ២០២៥ (៣,២%) ដោយសារភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច ភាពផុយស្រួយនៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ការព្រួយបារម្ភពីចីរភាពសារពើពន្ធ និងការកើនឡើងហានិភ័យពីការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ ប្រទេសអភិវឌ្ឍន៍មានកំណើន ១,៦% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ[១] ៤% និងបណ្ដាប្រទេសអភិវឌ្ឍន៍[២]ផ្សេងទៀត ១,២%។ អត្រាអតិផរណាពិភពលោកត្រូវបានព្យាករថាថយចុះមក ៣,៧% នាឆ្នាំ២០២៦ ធៀបនឹង ៤,២% នាឆ្នាំ២០២៥ ដោយសារតម្រូវការសកលបានថមថយ ការថយចុះថ្លៃទំនិញសកល និងឥទ្ធិពលបន្សល់ទុកនៃការអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតរបស់ធនាគារកណ្ដាលធំៗ។ អតិផរណានៅប្រទេសអភិវឌ្ឍន៍មានកម្រិត ២,១% ហើយប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍមានកម្រិត ៤,៧%។

**កំណើនសេដ្ឋកិច្ចនិងអតិផរណាពិភពលោក តំបន់ និងបណ្ដាប្រទេសមួយចំនួន[៣]**

| | | ពិភពលោក | ប្រទេស អភិវឌ្ឍន៍ | ប្រទេសកំ.លូត លាស់និងអភិ. | អាមេរិក | តំបន់អឺរ៉ូ | ចក្រភព អង់គ្លេស | ចិន | អាស៊ាន[៤] |
|---|---|---|---|---|---|---|---|---|---|
| កំណើន សេដ្ឋកិច្ច | ២០២៦ | ៣,១ ▼ | ១,៦ | ៤ ▼ | ២,១ ▲ | ១,១ ▼ | ១,៣ | ៤,២ ▼ | ៤,៣ ▼ |
| | ២០២៥ | ៣,២ | ១,៦ | ៤,២ | ២ | ១,២ | ១,៣ | ៤,៨ | ៤,៦ |
| អតិផរណា | ២០២៦ | ៣,៧ ▼ | ២,១ ▼ | ៤,៧ ▼ | ២,៤ ▼ | ១,៩ ▼ | ២,៥ ▼ | ០,៨ ▲ | ២,៨ ▲ |
| | ២០២៥ | ៤,២ | ២,៤ | ៥,៣ | ២,៧ | ២,១ | ៣,៤ | ០,៥ | ២,៥ |

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ-ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ២០២៥

ចំពោះទស្សនវិស័យនៅឆ្នាំ២០២៦ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងអាចសម្រេចបានក្នុងអត្រា ៥% ដូចឆ្នាំ២០២៥ ដែរ ។ កំណើននេះត្រូវបានគាំទ្រជាចម្បងដោយ៖ i/- កំណើនវិស័យកម្មន្តសាល ដែលគាំទ្រដោយតម្រូវការខាងក្រៅរបស់ដៃគូពាណិជ្ជកម្ម ជាពិសេសសហរដ្ឋអាមេរិក ការរក្សាបាននូវភាពប្រកួតប្រជែងដោយសារអត្រាពន្ធគយបដិការ ១៩% ដែលមានកម្រិតប្រហាក់-ប្រហែលនឹងដៃគូប្រកួតប្រជែង និងការធ្វើពិពិធកម្មផលិតផលនិងទីផ្សារ ii/- កំណើនវិស័យទេសចរណ៍ដែលគាំទ្រដោយគោលនយោបាយជំរុញវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល ដូចជាការលើកលែងទិដ្ឋាការសម្រាប់ពលរដ្ឋចិន នាពាក់កណ្ដាលខែមិថុនា ឆ្នាំ២០២៦[៥] ការធ្វើពិពិធកម្មទិសដៅទេសចរណ៍

[១] ក្នុងនោះ ប្រទេសចិន ឥណ្ឌា និងតំបន់អាស៊ាន មានកំណើន ៤,២% ៦,២% និង ៤,២% រៀងគ្នា។

[២] លើកលែងប្រទេសក្នុងតំបន់អឺរ៉ូ និងប្រទេសធំទាំង៧ (កាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន អង់គ្លេស និងសហរដ្ឋអាមេរិក)។

[៣] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក, IMF, ខែតុលា ឆ្នាំ២០២៥។

[៤] របាយការណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន+៣, AMRO, ខែតុលា ឆ្នាំ២០២៥។

[៥] សេចក្ដីជូនដំណឹងរបស់ក្រសួងទេសចរណ៍ ស្ដីពីការដាក់ឱ្យអនុវត្តសាកល្បងការលើកលែងទិដ្ឋាការសម្រាប់ភ្ញៀវទេសចរចិន ឆ្នាំ២០២៦ ដែលធ្វើដំណើរពីប្រទេសចិន ដោយផ្ដល់រយៈពេលស្នាក់នៅចំនួន ១៤ថ្ងៃ ក្នុងអំឡុងពេល ៤ខែ គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៦។

និងការបន្តជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍ទាំងក្នុងនិងក្រៅតំបន់ iii/- កំណើនវិស័យកសិកម្ម ដែលគាំទ្រដោយគោលនយោបាយនិងវិធានការគាំទ្ររបស់រាជរដ្ឋាភិបាលរួមមាន៖ ការលើកទឹកចិត្ត ពន្ធដារចំពោះវិស័យកសិកម្ម និងការរៀបចំអភិវឌ្ឍសហគមន៍កសិកម្មទំនើបក្នុងគោលដៅប្រែក្លាយ កសិកម្មកម្ពុជាពីលក្ខណៈគ្រួសារឱ្យទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ មានសមាហរណកម្មខ្ពស់ មានសេដ្ឋកិច្ចមាត្រដ្ឋាន និងមានសមត្ថភាពប្រកួតប្រជែងទាំងបរិមាណនិងគុណភាព និង iv/- ការងើបឡើង សន្សឹមៗនៃវិស័យសំណង់និងអចលនទ្រព្យ។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាអាចបន្តប្រឈមនឹងហានិភ័យមួយចំនួន ជាពិសេសហានិភ័យខាងក្រៅ ដូចជា៖ i/- ភាពតានតឹងនៃភូមិសាស្ត្រនយោបាយដែលធ្វើឱ្យប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់ ii/- ឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុ និង iii/- ការឆបោកតាមប្រព័ន្ធអនឡាញ។ ចំណែកឯហានិភ័យខាងក្នុង រួមមាន៖ i/- ភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ ii/- ផលប៉ះពាល់ពីការអូសបន្លាយនៃ ជម្លោះព្រំដែនកម្ពុជា-ថៃ និង iii/- ការកើនឡើងឥណទានមិនដំណើរការ។

**តារាង ១៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា ដោយរាជរដ្ឋាភិបាលនិងស្ថាប័នអន្តរជាតិនានា**

| | ឆ្នាំ២០២៥ប | ឆ្នាំ២០២៦ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៥,២% | ៥% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៤,៨% | ៤% |
| ធនាគារពិភពលោក (WB) | ៤,៨% | ៤,៣% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៤,៩% | ៥% |
| អង្គភាព AMRO | ៤,៩% | ៥% |

សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

អត្រាអតិផរណានៅឆ្នាំ២០២៦ ត្រូវបានព្យាករថានឹងថមថយបន្តិចមក ២,៣% (ធៀបនឹង ២,៥% នាឆ្នាំ២០២៥) ដែលក្នុងនោះកំណើនថ្លៃក្រុមម្ហូបអាហារនឹងថមថយមក ៣,៣% (ធៀបនឹង ៣,៧%) និងអតិផរណាស្នូលនឹងថមថយមក ១,៧% (ធៀបនឹង ១,៩%) ស្របពេលដែលក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈនឹងបន្តធ្លាក់ថ្លៃ -២,២% (ធៀបនឹង -១,៧%)។ ការថមថយនេះត្រូវបាន ព្យាករក្រោមកត្តាសន្មតដូចជា៖ i/-ភាពប្រសើរឡើងនៃវិស័យកសិកម្ម និងការស្តារឡើងវិញនៃខ្សែច្រវាក់ ផ្គត់ផ្គង់ក្រោយការផ្ទុះអាវុធកម្ពុជា-ថៃលើកទី២ ii/-ប្រាក់រៀលនឹងមានស្ថិរភាពធៀបនឹងដុល្លារអាមេរិក និង iii/-ថ្លៃប្រេងឆៅពិភពលោកនឹងបន្តធ្លាក់ចុះដោយសារកំណើនផលិតកម្មប្រេង[៦]ជាពិសេសពី បណ្តាប្រទេសក្រៅពី OPEC+[៧]។ ទោះយ៉ាងណា កត្តាមួយចំនួននឹងចូលរួមបង្កើនសម្ពាធអតិផរណា មួយផ្នែក ដែលរួមមាន៖ i/-ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសវិស័យទេសចរណ៍ និងវិស័យកម្មន្តសាល ដែលនឹងជំរុញតម្រូវការ ii/-ការកើនឡើងនៃកម្លាំងទិញរបស់ពលករដែលបាន

[៦] កម្រិតថ្លៃប្រេងឆៅជាមធ្យមត្រូវបានរំពឹងទុកថានឹងថយចុះ -២០,១% ពី ៦៩ ដុល្លារអាមេរិក/បារ៉ែល នាឆ្នាំ២០២៥ មកត្រឹម ៥៥,១ ដុល្លារអាមេរិក/បារ៉ែល នៅឆ្នាំ២០២៦។

[៧] ក្នុងនោះ សហរដ្ឋអាមេរិក ប្រេស៊ីល ហ្គីយ៉ាន និងកាណាដារួមចំណែកប្រមាណ ៦០% នៃកំណើនផលិតកម្មប្រេងពិភពលោក នៅឆ្នាំ២០២៦។

វិលត្រឡប់មកពីប្រទេសថៃបន្ទាប់ពីទទួលបានការងារធ្វើ និង iii/-ការរំពឹងទុកនៃការទម្លាក់អត្រាការប្រាក់គោលរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក ដែលអាចជំរុញកំណើនឥណទាន។

**ក្រាហ្វ ៩៣៖ អតិផរណាព្យាករ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, សម្រាប់ឆ្នាំ២០២៦)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនិងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ព=ព្យាករណ៍

## II- ទិសដៅការងារចម្បងៗនៅឆ្នាំ២០២៦

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបន្តអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- បន្តគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ
- បន្តលើកកម្ពស់ការប្រើប្រាស់និងចំណេះដឹងពីប្រាក់រៀល
- បន្តពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមានស្រាប់ និងការអនុវត្តក្របខណ្ឌកូរីដ័រអត្រាការប្រាក់ ព្រមទាំងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ តាមការចាំបាច់ និង
- បន្តលើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពី ក្របខណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

### ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- ត្រៀមរៀបចំសេចក្តីណែនាំការវិនិយោគសម្រាប់ឆ្នាំ២០២៦
- បន្តតាមដានស្ថានភាពទីផ្សារហិរញ្ញវត្ថុសកល បណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសទីផ្សារកំពុងលូតលាស់ ដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រវិនិយោគដែលមានភាពបត់បែនប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងស្វែងរកចំណូលសមស្រប

- បន្តសិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យ និង បង្កើនចំណូល
- បន្តសិក្សារៀបចំសេចក្តីណែនាំការវិនិយោគសម្រាប់គ្រប់គ្រងមូលនិធិសោធននិវត្តន៍ដោយ រៀនសូត្រពីបទពិសោធរបស់បណ្តាធនាគារកណ្តាលផ្សេងៗលើការគ្រប់គ្រងមូលនិធិសោធន-និវត្តន៍
- ស្វែងរកឱកាសវិនិយោគទាំងក្នុង និងក្រៅប្រទេសសម្រាប់ទុនមូលនិធិសោធននិវត្តន៍ និង
- បន្តសិក្សាពីឱកាស និងលទ្ធភាពពង្រីកការវិនិយោគក្រោមក្របខណ្ឌការវិនិយោគប្រកបដោយ ការទទួលខុសត្រូវលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ។

## ៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

- បន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់
- បន្តអភិវឌ្ឍគម្រោងទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនទាំងទ្វេភាគីនិងពហុភាគីជាមួយប្រទេស និងដៃគូសហការក្នុងតំបន់ និងអន្តរជាតិ
- បន្តលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ស្របតាមផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបន្តរៀបចំធ្វើបច្ចុប្បន្នកម្មផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៦-២០៣០
- បន្តរៀបចំការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់ស្របតាមក្របខណ្ឌត្រួតពិនិត្យ ប្រព័ន្ធទូទាត់សងប្រាក់
- បន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែ ទូលំទូលាយ និងបន្តការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ជំហានបន្ទាប់
- បន្តតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក្នុងគោលដៅធានាបានស្ថិរភាព តាមរយៈការត្រួតពិនិត្យលើឯកសារ និងការចុះត្រួតពិនិត្យដល់ទីកន្លែង ព្រមទាំងតាមដាន ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន និង
- បន្តដាក់ចេញនូវក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។

## ៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- អនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យដោយផ្តោតជាពិសេសលើសកម្មភាពដែលអាចមាន ហានិភ័យខ្ពស់ ចំពោះប្រព័ន្ធធនាគារ រួមទាំង ការកំណត់អត្តសញ្ញាណគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ ដែលមានហានិភ័យខ្ពស់និងជាប្រព័ន្ធ វាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ ព្រមទាំងកំណត់សកម្មភាពអាទិភាពផ្នែកត្រួតពិនិត្យផ្អែកលើវិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ "ស្រេប"
- ពង្រឹងការត្រួតពិនិត្យលើឯកសារ ផ្តោតលើការវិភាគជាប្រចាំលើរបាយការណ៍តាមបទប្បញ្ញត្តិ ប្រុងប្រយ័ត្ន (ដើមទុន សន្ទនីយភាព គុណភាពទ្រព្យសកម្ម និងលទ្ធភាពរកប្រាក់ចំណេញ) និង តាមដានការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ពង្រឹងការត្រួតពិនិត្យដល់ទីកន្លែង ដោយផ្តោតលើគុណភាពទ្រព្យសកម្ម ជាពិសេសការគ្រប់គ្រងឥណទានមិនដំណើរការ ពិនិត្យមើលស៊ីជម្រៅលើភាពគ្រប់គ្រាន់នៃដើមទុននិងការគ្រប់គ្រងសន្ទនីយភាព វាយតម្លៃអភិបាលកិច្ច និងការត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងភាពធន់នៃប្រព័ន្ធព័ត៌មានវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បន្តសិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យប្រើប្រាស់បរិវត្តន៍ឌីជីថលក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បន្តតាមដាន និងត្រួតពិនិត្យលើការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិរបស់អ្នកផ្តល់ទិន្នន័យនិងអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន
- រៀបចំឱ្យមានផ្ទាំងព័ត៌មានសង្ខេបសម្រាប់គាំទ្រដល់ការវិភាគ វាយតម្លៃហានិភ័យ និងការដាក់ចេញនូវគោលនយោបាយនានាសម្រាប់ប្រព័ន្ធធនាគារ
- បន្តការកសាងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីត្រួតពិនិត្យលើវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ការធ្វើស្ត្រេសតេស្ត និងវាយតម្លៃហានិភ័យពាក់ព័ន្ធ និង
- បន្តកិច្ចសហការជាមួយស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍នានា។

## ៥- ការរៀបចំបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ

- បន្តរៀបចំនិងកែសម្រួលច្បាប់ និងបទប្បញ្ញត្តិ
- បន្តរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់និងការរៀបចំរបាយការណ៍ផ្សេងៗ ព្រមទាំងផ្សព្វផ្សាយបទប្បញ្ញត្តិថ្មីនិងច្បាប់ពាក់ព័ន្ធនឹងវិស័យធនាគារ និង
- វាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ សម្រាប់ឆ្នាំ២០២៦-២០៣០។

## ៦- ការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព

- ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនទីចង្អុលទិសហិរញ្ញវត្ថុប្រកបដោយចីរភាព
- សិក្សាលើវិស័យអាទិភាពផ្សេងៗ សម្រាប់ការអភិវឌ្ឍប្រព័ន្ធវដ្តករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា សម្រាប់ដំណាក់កាលបន្ទាប់
- រៀបចំគោលការណ៍ស្តីពី ការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គម (Environmental and Social Risk Management Guidelines) យន្តការស្តីពី ការរាយការណ៍ និងតម្លាភាពហិរញ្ញវត្ថុប្រកបដោយចីរភាព (Reporting and Disclosure) និង
- រៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងក្របខណ្ឌវាយតម្លៃ និងការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុដល់វិស័យធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ។

## ៧- ការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ កិច្ចការពារអតិថិជន និងកិច្ចការពារប្រាក់បញ្ញើ

- បន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ដំណាក់កាលទី៣
- រៀបចំសិក្ខាសាលានិងមធ្យោបាយផ្សព្វផ្សាយនានា ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ
- សហការជាមួយអង្គការ Good Return ដើម្បីអនុវត្តយុទ្ធនាការ "តោះ! និយាយពីលុយ" ដំណាក់កាលទី៣
- រៀបចំសិក្សាគម្រោងផលិតមាតិកាអប់រំ ផលប៉ះពាល់នៃកម្ចីខុសច្បាប់ តាមប្រព័ន្ធឌីជីថល
- បន្តសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីរៀបចំកម្មវិធី សុវត្ថិភាពហិរញ្ញវត្ថុសហគមន៍
- បន្តរៀបចំសេចក្ដីព្រាងប្រកាសស្ដីពី កិច្ចការពារប្រាក់បញ្ញើ រចនាសម្ព័ន្ធអភិបាលកិច្ច ការកំណត់បុព្វលាភ និងការផ្ដល់សំណង សម្រាប់យន្តការកិច្ចការពារប្រាក់បញ្ញើ និង
- បន្តរៀបចំសេចក្ដីព្រាងនីតិវិធីនៃការជម្រះបញ្ជីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងដំណោះស្រាយគ្រឹះស្ថានធនាគារដែលមានបញ្ហា។

## ៨- ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ

- តាមដាននិងពង្រឹងការវាយតម្លៃនៃប្រព័ន្ធធនាគារ និងហានិភ័យជាប្រព័ន្ធ
- វិភាគរវាងវិស័យសេដ្ឋកិច្ចរូបវន្តនិងវិស័យហិរញ្ញវត្ថុនៅកម្ពុជា
- បន្តពង្រឹងនិងអភិវឌ្ឍការធ្វើស្ត្រេសតេស្តលើភាពធន់របស់ប្រព័ន្ធធនាគារព្រមទាំងសិក្សាបន្ថែមទៅលើការធ្វើម៉ាក្រូស្ត្រេសតេស្តនិងស្ត្រេសតេស្តលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- រៀបចំនិងអភិវឌ្ឍប្រព័ន្ធព្រមាន (Early Warning System) ដើម្បីអាចកំណត់និងដាក់ចេញវិធានការបុរេសកម្មបានទាន់ពេលវេលា និង
- រៀបចំក្របខណ្ឌវិភាគ និងសូចនាករចាំបាច់ដើម្បីវាយតម្លៃពីទំនាក់ទំនងរវាងបរិយាបន្នហិរញ្ញវត្ថុ កិច្ចការពារអតិថិជនជាមួយស្ថិរភាពហិរញ្ញវត្ថុ។

## ៩- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- សម្របសម្រួលផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពី ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មលើកទី២
- សម្របសម្រួលរៀបចំយុទ្ធសាស្ត្រជាតិស្ដីពី ការប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បន្តតាមដានការអនុវត្តកាតព្វកិច្ចរបស់បុគ្គលរាយការណ៍ស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បន្តរៀបចំឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់វិស័យអចលនវត្ថុ កាស៊ីណូ និងវិជ្ជាជីវៈច្បាប់
- បន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីសម្រួលដល់ការងារវិភាគ និងការងារត្រួតពិនិត្យ

- បន្តតាមដាន និងសិក្សាលើអនុសាសន៍ដែល FATF បានធ្វើបច្ចុប្បន្នកម្ម និងនីតិវិធីវាយតម្លៃអញ្ញមញ្ញសកលជុំទី៥ របស់ APG
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បន្តពង្រឹងសមត្ថភាពមន្ត្រី ស.ហ.ក. ទាក់ទងនឹងការត្រួតពិនិត្យ និងវិភាគប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈការចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា និង
- បន្តសហការជាមួយក្រសួង-ស្ថាប័នក្នុងស្រុក និងអន្តរជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងដល់បុគ្គលរាយការណ៍ និងភាគីពាក់ព័ន្ធ។

## ១០- ការអភិវឌ្ឍទីផ្សាររូបិយវត្ថុ

- បន្តការដាក់ឱ្យដេញថ្លៃប្រតិបត្តិការទទួលទិញវិញ (ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា-LPCO) និងមូលបត្រធនាគារកណ្តាល (មូលបត្រអាចជួញដូរបាន-NCD) តាមកាលវិភាគ
- បន្តអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)
- បន្តអនុវត្តប្រតិបត្តិការទីផ្សារចំហ ដោយការទិញ-លក់សញ្ញាបណ្ណរដ្ឋាភិបាលក្នុងទីផ្សារបន្ទាប់
- បន្តការងារអង្កេតទីផ្សារ តាមរយៈការស្ទង់មតិ និងតាមដាននិន្នាការរំហូរសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ដើម្បីស្វែងយល់អំពីការគ្រប់គ្រងសន្ទនីយភាពរបស់អ្នកចូលរួមក្នុងទីផ្សារ និងបង្កើនប្រសិទ្ធភាពការព្យាករសន្ទនីយភាព
- បន្តរៀបចំការបណ្តុះបណ្តាល និងពង្រឹងការផ្សព្វផ្សាយព័ត៌មាននិងទិន្នន័យ ស្តីពីក្របខណ្ឌប្រតិបត្តិការរូបិយវត្ថុដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីជំរុញប្រសិទ្ធភាពការអនុវត្តនយោបាយរូបិយវត្ថុ
- បន្តការវាយតម្លៃ NBCP និងអនុវត្តនូវអនុសាសន៍ស្របតាមក្របខណ្ឌហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាព
- បង្កើតក្រុមការងារទំនាក់ទំនងទីផ្សារដើម្បីជាវេទិកាពិភាក្សាជាមួយអ្នកចូលរួមក្នុងទីផ្សារ ដើម្បីប្រមូលធាតុចូលក្នុងគោលដៅអភិវឌ្ឍទីផ្សារអន្តរធនាគារ និងពង្រឹងប្រតិបត្តិការរូបិយវត្ថុ
- បន្តអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការសិក្សាលើឧបករណ៍ហិរញ្ញវត្ថុថ្មីៗ និងជំរុញសកម្មភាពប្រតិបត្តិការជួញដូរ និង
- បញ្ចប់គម្រោងក្របខណ្ឌវាយតម្លៃស្ថានភាពទីផ្សាររូបិយវត្ថុ (Money Market Diagnostic Framework) ក្រោមកិច្ចសហការជាមួយស្ថាប័នសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។

## ១១- ការផ្តល់សេវាធនាគារកណ្តាល

- បន្តគាំទ្រការធ្វើសន្ទានកម្មប្រព័ន្ធទូទាត់ បណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធទូទាត់ និងត្រៀមលក្ខណៈចូលរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ថ្មីៗ
- បន្តផ្សព្វផ្សាយ និងបង្កើនប្រសិទ្ធភាពសេវាគ្រប់គ្រងគណនីតាមប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS) ប្រព័ន្ធទទួលចំណូល KHQR និងបញ្ជរទទួលអតិថិជន

- បន្តសិក្សាលទ្ធភាពក្នុងការផ្តល់សេវាធនាគារកណ្តាលតាមប្រព័ន្ធឌីជីថល
- បន្តផ្សព្វផ្សាយជាទៀងទាត់នូវផែនការបោះផ្សាយមូលបត្ររដ្ឋ និងសម្របសម្រួលបោះផ្សាយមូលបត្ររដ្ឋឱ្យសម្រេចបានតាមផែនការនៃការបោះផ្សាយមូលបត្ររដ្ឋឆ្នាំ២០២៦
- បន្តសហការ និងសម្របសម្រួលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ធ្វើប្រតិបត្តិការក្នុង NBCP
- បន្តរៀបចំយន្តការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ តាមរយៈ NBCP សំដៅបង្កើតឱ្យបាននូវទីផ្សារបន្ទាប់ដែលមានលក្ខណៈពេញលេញ សន្ទនីយភាពខ្ពស់ ថ្លៃប្រតិបត្តិការ និងហានិភ័យទាប
- បន្តសហការរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីស្វាបស្ទង់ទីផ្សារជាមួយវិនិយោគិនមូលបត្ររដ្ឋជាប្រចាំ និង
- បន្តចូលរួមសហការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋជាមួយក្រសួង-ស្ថាប័នរដ្ឋពាក់ព័ន្ធ។

## ១២- ការគ្រប់គ្រងសាច់ប្រាក់

- បន្តពង្រឹងសេវាបង់ និងបើកសាច់ប្រាក់បានឆាប់រហ័ស
- ពង្រឹងអនុវត្តការងារដឹកជញ្ជូនធនបត្រឱ្យមានសុវត្ថិភាព
- បង្កើនលទ្ធភាពការរាប់ស្រាល់ជ្រើសក្រដាសប្រាក់ឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែកតាមរយៈប្រព័ន្ធបាគង និងសាច់ប្រាក់
- បន្តលើកកម្ពស់ការងារគ្រប់គ្រងសាច់ប្រាក់ និងការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់
- បន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយ និង
- បន្តរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីគុណភាព និងលក្ខណៈពិសេសរបស់ក្រដាសប្រាក់រៀលជូនដល់សាខារាជធានី-ខេត្ត គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាធារណជន។

## ១៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

- អនុវត្តការងារសវនកម្ម និងអធិការកិច្ច ស្របតាមផែនការឆ្នាំ២០២៦ និងតាមការចាំបាច់
- ពិនិត្យ និងតាមដានការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជា
- ពិនិត្យ និងរៀបចំឡើងវិញនូវនីតិវិធីសវនកម្មនិងអធិការកិច្ច
- បន្តសិក្សា និងរៀបចំលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសវនដ្ឋានសម្រាប់ការធ្វើសវនកម្ម និង
- បន្តពង្រឹងសមត្ថភាពមន្ត្រីសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចបន្ថែមទៀត ដើម្បីបង្កើនគុណភាពការងារស្របតាមនិន្នាការបច្ចុប្បន្ន។

## ១៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត

- បន្តពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាបង់ប្រាក់ បើកប្រាក់ និងការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកជូនសាធារណជន
- បន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការពង្រឹងគុណភាពនិងប្រសិទ្ធភាព ដោះស្រាយបណ្តឹង ក្នុងគោលដៅការពារការខាតបង់ប្រយោជន៍របស់សាធារណជន និង
- បន្តចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រាក់រៀល និងការទូទាត់តាមរយៈប្រព័ន្ធ KHQR ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

## ១៥- ការអភិវឌ្ឍធនធានមនុស្ស

- បន្តរៀបចំគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជា
- បន្តធ្វើបច្ចុប្បន្នកម្មក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខន្តិកៈដោយឡែកមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- បន្តពង្រឹងការងារចាត់តាំងមន្ត្រីបុគ្គលិកស្របតាមគោលនយោបាយគ្រប់គ្រងធនធានមនុស្ស និង តម្រូវការការងារជាក់ស្តែងរបស់ធនាគារជាតិនៃកម្ពុជា
- បន្តកែលម្អយន្តការគ្រប់គ្រង និងតាមដានការគោរពវិន័យការងាររបស់មន្ត្រីបុគ្គលិក ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត
- បន្តរៀបចំយន្តការវិភាគតម្រូវការបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្ស និងរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំឱ្យកាន់តែមានសង្គតិភាព
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈវគ្គសិក្សានានាទាំងតាមប្រព័ន្ធអនឡាញ និងសិក្សាផ្ទាល់លើគ្រប់ជំនាញពាក់ព័ន្ធនឹងធនាគារកណ្តាល និង
- បន្តរៀបចំគោលនយោបាយសង្គមកិច្ចរបស់មន្ត្រីបុគ្គលិក។

## ១៦- កិច្ចសហប្រតិបត្តិការអន្តរជាតិ

- រៀបចំសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលប្រៀងកូហ្វូនលើកទី២៨ នាឆ្នាំ២០២៦ នៅកម្ពុជា
- រៀបចំចុះអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុប៊ូតង់
- ពិនិត្យលទ្ធភាពរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយធនាគារកណ្តាលទីម័រឡេស្តេ
- សិក្សាពីការអភិវឌ្ឍគោលនយោបាយនិងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ
- បន្តកែលម្អយន្តការនៃការគ្រប់គ្រង ប្រមូល និងចងក្រងព័ត៌មាននិងវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយបច្ចេកទេស
- សិក្សាពីវិធីសាស្ត្រអង្កេតថ្មីៗសម្រាប់ផ្សារភ្ជាប់នៃតម្រូវការជំនួយបច្ចេកទេស
- ពង្រីកកិច្ចសហការទ្វេភាគីជាមួយធនាគារកណ្តាលជាដៃគូក្នុងតំបន់
- ពង្រឹងបន្ថែមការធ្វើសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងអាស៊ាន និងតំបន់ផ្សេងៗ
- ពង្រឹងកិច្ចសន្ទនាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ និង
- ពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកលើជំនាញសហប្រតិបត្តិការអន្តរជាតិ។

## ១៧- ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច

- រៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១៣ របស់ធនាគារជាតិនៃកម្ពុជា
- បន្តវិភាគ និងរៀបចំរបាយការណ៍នៃលទ្ធផលអង្កេតទំនុកចិត្តធុរកិច្ចនៅកម្ពុជា (Business Confidence Survey) និងអង្កេតទំនុកចិត្តអ្នកប្រើប្រាស់នៅកម្ពុជា (Consumer Confidence Survey) នៅតាមបណ្តារាជធានី-ខេត្ត ប្រចាំគ្រា សម្រាប់ប្រើប្រាស់ជាធាតុចូលលើការតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច
- បន្តធ្វើបច្ចុប្បន្នភាពសូចនាករគន្លឹះ វាយតម្លៃស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងព្យាករអំពីការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីខាងមុខ (Nowcasting and Near-term Forecasting) សម្រាប់ឆ្នាំ២០២៦ និង២០២៧
- បន្តពង្រឹង និងអភិវឌ្ឍម៉ូដែលថ្មីៗ ដើម្បីធ្វើឱ្យការវិភាគ វាយតម្លៃ និងព្យាករស្ថានភាពសេដ្ឋកិច្ចកាន់តែប្រសើរ
- បន្តសហការជាមួយ JICA ដើម្បីសិក្សាស្រាវជ្រាវលើការប្រើប្រាស់ទិន្នន័យ Alternative Data ក្នុងការវិភាគនិងតាមដានស្ថានភាពសេដ្ឋកិច្ចតាមវិស័យ
- ជ្រើសរើសអត្ថបទសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយក្នុងកម្រងអត្ថបទស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជា (NBC Working Paper Series) និង
- ពង្រឹងគុណភាពសិក្សាស្រាវជ្រាវឱ្យស្របតាមស្តង់ដាអន្តរជាតិ ដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ។

## ១៨- ការពង្រឹងគុណភាពស្ថិតិ

- បោះផ្សាយស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ និងស្ថិតិសូចនាករភាពរឹងមាំវិស័យហិរញ្ញវត្ថុ
- កែសម្រួលឯកសារណែនាំស្តីពីវិធីសាស្ត្ររៀបចំប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ
- ពង្រឹងកិច្ចសហការជាមួយក្រសួងទេសចរណ៍ លើការចែករំលែកលទ្ធផលអង្កេតទេសចរណ៍ឆ្នាំ២០២៥ របស់ក្រសួងទេសចរណ៍
- បន្តរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការយល់ដឹងពីទស្សនទាន ការរៀបចំរបាយការណ៍ និងការពង្រឹងគុណភាពការរាយការណ៍ប្រព័ន្ធរបាយ-ការណ៍ប្រតិបត្តិការអន្តរជាតិ ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ និងសន្ទស្សន៍ថ្លៃលំនៅដ្ឋាន
- រៀបចំសិក្ខាសាលាស្តីពី ទស្សនាទាននិងវិធីសាស្ត្រចងក្រងប្រាក់បង្វែររបស់ពលករទេសន្តរប្រវេសន៍ ដើម្បីពង្រឹងការយល់ដឹងពីសារៈសំខាន់នៃការចងក្រងស្ថិតិ និងបង្កើនកិច្ចសហការក្នុងការចែករំលែកព័ត៌មាន និង
- បន្តអនុវត្តការធ្វើអង្កេតទំនុកចិត្តធុរកិច្ចប្រចាំឆមាស អង្កេតទំនុកចិត្តអ្នកប្រើប្រាស់ប្រចាំត្រីមាស និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ដើម្បីរៀបចំជាសូចនាករតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច។

## ១៩- សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បាសានវង់ន (ស.ស.រ.)

- បញ្ចប់ការងារបោះពុម្ពសៀវភៅ "យើងទៅទស្សនាសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុព្រះស្រីល្បាសានវង់ន ស.ស.រ." ជាភាសាអង់គ្លេស និងភាសាបារាំង
- រៀបចំបោះពុម្ពសៀវភៅកាតាឡុកពិព័រណ៍មិនអចិន្ត្រៃយ៍ "ការលេចត្រដែតឡើងវិញៈ ការបាត់បង់ និងការរកឃើញឡើងវិញនូវគំនូរក្នុងវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង"
- ធ្វើបច្ចុប្បន្នភាពពិព័រណ៍អចិន្ត្រៃយ៍ ម៉ូឌុលទី៨ និងម៉ូឌុលទី៩ ក្នុងសារមន្ទីរ
- រៀបចំកែលម្អអគារធនាគារឥណ្ឌូចិនសម្រាប់ប្រើប្រាស់ស្របតាមយុទ្ធសាស្ត្រសារមន្ទីរ
- បញ្ចប់ការងាររៀបចំសារមន្ទីរ ខេត្តបាត់ដំបង
- ជ្រើសរើសបុគ្គលិកសម្រាប់បម្រើការងារនៅសារមន្ទីរ ខេត្តបាត់ដំបង និង
- បន្តរៀបចំមជ្ឈមណ្ឌលតាំងពិព័រណ៍ខេត្តកំពត។

## ២០- វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

- រៀបចំដំណើរការថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររងជំនាញគ្រប់គ្រងធនាគារ និងថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសម្រាប់ឆ្នាំសិក្សា ២០២៥-២០២៦ ក៏ដូចជារៀបចំកម្មវិធីចុះកម្មសិក្សារបស់និស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ (បរិញ្ញាបត្ររង) ជំនាន់ទី៣៣
- បង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- បន្តធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ និងស្តង់ដាអប់រំជាតិ និងអន្តរជាតិ
- បន្តអភិវឌ្ឍបណ្ណាល័យទាំងរូបវន្ត និងអេឡិចត្រូនិក
